ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខៈ ០០៣/០៨-តុលា-២០២១-អ.វ.ត.ក/អ.ជ.ត.ក (០៥)

Case File/Dossier N°. 003/08-10-2021-ECCC/SC (05)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Dec-2021, 10:34
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Maureen HARDING CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ខែ ១៧ ធ្នូ ឆ្នាំ ២០២១**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.

---

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**ក្នុងសំណុំរឿង ០០៣ ទាំងអស់**

**ជនជាប់ចោទ**

មាស មុត

**សហមេធាវីជនជាប់ចោទ**

អាង ឧត្តម
Michael G. KARNAVAS

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ"អង្គជំនុំជម្រះ" និង "អ.វ.ត.ក"នីមួយៗ) បានទទួល"បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក." ("បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ" ឬ 'សំណើ')[1]។

## ក. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ស្នើសុំឱ្យធ្វើការស៊ើបអង្កេតតាមផ្លូវតុលាការលើ ស៊ូ ម៉េត និង មាស មុត ពីបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[2]។

3. ក្នុងពេលជាមួយគ្នានោះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការខ្វែងយោបល់ចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបានលើកឡើងថា សហព្រះរាជអាជ្ញាជាតិពុំយល់ស្របទៅនឹងការចោទប្រកាន់បទឧក្រិដ្ឋថ្មីដែលបានកំណត់អត្តសញ្ញាណក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[3]។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួនដោយប្រកាសថា អង្គជំនុំជម្រះពុំអាចរកសម្លេងភាគច្រើនយ៉ាងតិចបួនសម្លេងគាំទ្រសេចក្ដីសម្រេចស្ដីពីការខ្វែងយោបល់គ្នានៅចំពោះមុខខ្លួន និងថាកិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិគប្បីត្រូវបានយកទៅអនុវត្ត[4]។

---

[1] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០២១ ឯកសារលេខ 3 ("បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ(ឯកសារលេខ 3)" ឬ "បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ ឯកសារលេខ D1។

[3] កំណត់លាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីអង្គហេតុ និងសំអាងហេតុសម្រាប់ការខ្វែងយោបល់ដោយអនុលោមតាមវិធាន ៧១(២) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ 1។

[4] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនឹងការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន ៧១ នៃវិធាផ្ទៃក្នុង ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ ឯកសារលេខ D1/1.3។

4. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងបានបញ្ជូនសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេត[5]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលមានការចោទប្រកាន់បន្ថែមទៀត[6]។

5. ការខ្វែងយោបល់គ្នាជាសម្ងាត់របស់សហចៅក្រមស៊ើបអង្កេតក្នុងរឿងក្តីនេះត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ និង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៨[7]។

6. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរដោយប្រកាសថា កិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០៣ ត្រូវបានបញ្ចប់សព្វគ្រប់ហើយ[8]។ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលាឈប់[9] ហើយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានចេញដីកាសម្រេចស្តីអំពីការបើកកិច្ចស៊ើបអង្កេតឡើងវិញ នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១[10]។

---

[5] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ ឯកសារលេខ D1/1។

[6] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៣ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ ឯកសារលេខ D120។

[7] ដីកាដំណោះស្រាយ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ ឯកសារលេខ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារលេខ D267)") កថាខណ្ឌ ៥, ៧, ១៥, ២៧។

[8] សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ ឯកសារលេខ D13។

[9] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. "សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត" ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ https://www.eccc.gov.kh/en/articles/statement-international-co-investigating-judge.

[10] ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋម ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ ឯកសារលេខ D28។

7. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានជូនដំណឹង ស៊ូ ម៉េត និង មាស មុត ថា ពួកគាត់គឺជាជនសង្ស័យក្នុងសំណុំរឿង ០០៣ និងថា ពួកគាត់មានសិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើស និងសិទ្ធិចូលមើលឯកសារសំណុំរឿង[11]។

8. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីថា ស៊ូ ម៉េត បានទទួលមរណភាព[12] ហើយកិច្ចដំណើរការនីតិវិធីលើរូបគាត់ជាលទ្ធផលត្រូវបានបញ្ចប់នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥[13]។

9. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មាស មុត ត្រូវបានកោះហៅឱ្យចូលបង្ហាញខ្លួនលើកដំបូងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅ អ.វ.ត.ក. ចុះកាលបរិច្ឆេទនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤[14] ប៉ុន្តែ មាស មុត បានជំទាស់ទៅសហចៅក្រមស៊ើបអង្កេត[15]។ នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤អង្គបុរេជំនុំជម្រះបានទទួលស្គាល់នីត្យានុកូលភាពដីកាកោះ[16]។

10. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាពីរបង្គាប់ឱ្យនាំខ្លួន មាស មុត នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤[17] និងថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ បន្ទាប់ពីគាត់ពុំបានអនុវត្តតាមដីកាកោះនោះ[18]។

---

[11] សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១ (១)(ឃ)] ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ D30 (ពាក់ព័ន្ធ មាស មុត)។ សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១ (១)(ឃ)] ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ D31 (ពាក់ព័ន្ធ ស៊ូ ម៉េត)។

[12] ការជូនដំណឹងអំពីមរណភាពរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៣ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារលេខ D86។

[13] ដីកាលើកលែងចោទប្រកាន់ប្រឆាំងនឹង ស៊ូ ម៉េត ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ D86/3។

[14] ដីកាកោះឱ្យបង្ហាញខ្លួនបឋម ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ A66។

[15] សេចក្តីជូនដំណឹងអំពីការទទួលស្គាល់ឡើងវិញនៃដីកាកោះ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ និង ដាក់ចូលសំណុំរឿង ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ A67/1.1។

[16] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងទៅនឹងដីកាកោះ ដែលចុះហត្ថលេខា ដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ ឯកសារលេខ D117/1/1/2។

[17] ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ និងដាក់ចូលសំណុំរឿង ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ C1។

[18] ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ និងដាក់ចូលសំណុំរឿង ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ C2។

11. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ មាស មុត *ដោយកំបាំងមុខ* ដោយសារការរំលោភបំពានលើមាត្រា ៥០០ (ការធ្វើទារុណកម្ម) មាត្រា ៥០១ និង ៥០៦ (អំពើមនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦") ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[19] និងបានរៀបរាប់លម្អិតនៃបទចោទដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្ដីសម្រេច[20]។

12. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ នៅពេលបង្ហាញខ្លួនដំបូងរបស់ មាស មុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ បទល្មើសបន្ថែមទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[21]។

13. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្ដីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំងនឹង មាស មុត[22]។ ក្នុងពេលទន្ទឹមគ្នានោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចផ្អែកតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង កម្រិតវិសាលភាពនៃកិច្ចស៊ើបសួរដោយដកចេញនូវអង្គហេតុមួយចំនួន[23]។ នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្ដីជូនដំណឹងបញ្ចប់កិច្ចស៊ើបសួរលើកទីពីរ[24]។

14. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញាដើម្បីពិនិត្យ ដោយបានអញ្ជើញឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរផ្អែកតាមវិធាន ៦៦(៤) នៃ

---

[19] សេចក្ដីសម្រេចចោទប្រកាន់ មាស មុត ដោយកំបាំងមុខ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ ឯកសារលេខ D128។

[20] ការជូនដំណឹងបទចោទប្រឆាំង មាស មុត ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្ដីសម្រេចចោទប្រកាន់ មាស មុត *កំបាំងមុខ* (ឯកសារលេខ D128) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ និងដាក់ចូលសំណុំរឿង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ ឯកសារលេខ D128.1។

[21] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ D174 ទំព័រ ២-៩។

[22] សេចក្ដីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D225។

[23] ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D226។

[24] សេចក្ដីជូនដំណឹងលើកទីពីរអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ D252។

វិធានផ្ទៃក្នុង[25]។ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដោយស្នើសុំថា រាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង មាស មុត ត្រូវបដិសេធចោល ដោយសារគាត់ពុំស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[26]។ នៅក្នុងពេលនោះ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរស្នើសុំឱ្យសម្រេចចោទប្រកាន់ មាស មុត និងបញ្ជូនទៅជំនុំជម្រះ[27]។

15. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីថា ដោយសារមានការខ្វែងយោបល់គ្នា សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ដីកាដំណោះស្រាយដែលខ្វែងយោបល់ និងដាច់ដោយឡែកពីគ្នានោះ ត្រូវបានអនុញ្ញាតផ្អែកតាមច្បាប់ជាធរមាន និងទំនងជាផលវិបាកសម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍ ផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[28]។ នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា[29]។

16. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយឱ្យបញ្ជូន មាស មុត ទៅជំនុំជម្រះ[30] ខណៈពេលដែលសហចៅក្រមស៊ើបអង្កេតជាតិ ចេញដីកាលើកលែងការចោទប្រកាន់ប្រឆាំងនឹង មាស មុត[31]។

17. បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី មាស មុត ទៅអង្គបុរេជំនុំជម្រះ ព្រមទាំងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ និងបណ្តឹង

[25] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ D256។

[26] ដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធទៅនឹង មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារលេខ D256/6។

[27] ដីកាសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧, ឯកសារលេខ D256/7។

[28] ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធទៅនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D262។

[29] ដីកាដំណោះស្រាយ (ឯកសារលេខ D267) កថាខណ្ឌ ២៧។

[30] ដីកាដំណោះស្រាយ (ឯកសារលេខ D267)។

[31] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ D266.

ឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[32] អង្គបុរេជំនុំជម្រះបានចេញ *សេចក្ដីពិចារណារបស់ខ្លួន*ស្ដីពីបណ្ដឹងឧទ្ធរណ៍នីមួយៗនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១ ដោយបានបញ្ជាក់ថា អង្គជំនុំជម្រះពុំអាចរកសម្លេងភាគច្រើន ដែលតម្រូវឱ្យសម្រេចលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយនោះ[33]។ *សេចក្ដីពិចារណា*ត្រូវបានជូនដំណឹងជាសាធារណៈក្នុងពេលជាមួយគ្នានោះហើយ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តដំណើរការនីតិវិធីរៀបចំណាត់ការរបស់ខ្លួននៅដំណាក់កាលមុនការជំនុំជម្រះ។ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីតាមរយៈអ៊ីម៉ែលថា អង្គជំនុំជម្រះសាលាដំបូងមិនទទួលការទំនាក់ទំនងណាមួយពីភាគីឡើយ ដោយសារអង្គជំនុំជម្រះពុំត្រូវបានជូនដំណឹងអំពីសេចក្ដីពិចារណានោះ ឬសំណុំរឿង[34]។

18. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើថា សំណុំរឿងត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[35] ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបដិសេធនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១ ដោយបានកត់សម្គាល់ថា ខ្លួនពុំមានយុត្តាធិការពិចារណាលើសំណើសុំនេះ[36] និងបានលើកបន្ថែមថា "ប្រសិនបើពុំមានមធ្យោបាយណាផ្សេងដើម្បីជម្រុញសំណុំរឿងនេះឱ្យទៅជំនុំជម្រះ ឬការបញ្ចប់ [...] [យើង] [...] នៅបើកឱកាសទទួលយក ឬធ្វើការស្នើសុំនូវការបំភ្លឺលើបញ្ហាថាតើ [យើង] មានយុត្តាធិការ

[32] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ D266/27 & ឯកសារលេខ D267/35 ("សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 & ឯកសារលេខ D267/35)") កថាខណ្ឌ ៣០។

[33] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 & ឯកសារលេខ D267/35) ទំព័រ ៥០។

[34] អ៊ីម៉ែលពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង លឹម ស៊ុយហុង "ឆ្លើយតប: សំណើសុំបន្ថែមពេលវេលាដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដោយអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ D271/1.1.41។

[35] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ D270។

[36] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១ ឯកសារលេខ D270/7 ("សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ D270/7)")។

នៅសេសសល់ពិសេសណាមួយដែលជាមធ្យោបាយចុងក្រោយបំផុតក្នុងការបិទបញ្ចប់សំណុំរឿង ដែរយ៉ាងណា”[37]។

19. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២១ មាស មុត បានស្នើអង្គបុរេជំនុំជម្រះឱ្យបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណាសារនូវសំណុំរឿង ០០៣[38]។ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឱ្យអង្គបុរេជំនុំជម្រះបញ្ចប់កិច្ចដំណើរការនីតិវិធីនៅដំណាក់កាលមុនការជំនុំជម្រះក្នុងសំណុំរឿង ០០៣ ដោយផ្អែកលើមូលដ្ឋាននៃការឯកភាពរួមគ្នាមួយអង្គបុរេជំនុំជម្រះ ដើម្បីបញ្ជូន មាស មុត ទៅអង្គជំនុំជម្រះសាលាដំបូង[39]។ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១ អង្គបុរេជំនុំជម្រះបានចាត់ទុកសំណើទាំងពីរនោះពុំអាចទទួលយកបាន[40] និងបានបញ្ជាក់តម្កល់សេចក្តីពិចារណារបស់ខ្លួនថា អង្គជំនុំជម្រះបានបំពេញកាតព្វកិច្ចរបស់ខ្លួនពេញលេញផ្អែកតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[41]។

20. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០២១ សហចៅក្រមស៊ើបអង្កេតជូនដំណឹងភាគីថា លើកលែងតែសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងដាក់សំណើនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យុត្តាធិការសេសសល់របស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ចប់សំណុំរឿងនៅតែមានអត្ថិភាព[42]។ នៅថ្ងៃដដែល

---

[37] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ D270/7) កថាខណ្ឌ ៤២។

[38] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណាសារនូវសំណុំរឿង ០០៣ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២១ ត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២១ និងបានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ D272។

[39] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបញ្ចប់កិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៣ នៅដំណាក់កាលមុនការជំនុំជម្រះ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ D271/1។

[40] សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D271/5 & ឯកសារលេខ D272/3 (“សេចក្តីសម្រេចរួម (ឯកសារលេខ D271/5 & ឯកសារលេខ D272/3)”) កថាខណ្ឌ ៧៨ ផ្នែកសម្រេចសេចក្តី។

[41] សេចក្តីសម្រេចរួម (ឯកសារលេខ D271/5 & ឯកសារលេខ D272/3) កថាខណ្ឌ ៦៤, ៦៨, ៧៦។

[42] ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D273 កថាខណ្ឌ ៥ ដល់ ៧។

នោះ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងសហចៅក្រមស៊ើបអង្កេតអំពីគោលបំណងរបស់ខ្លួនក្នុងការដាក់បណ្ដឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូល[43]។

## ២. សារណា

*ភាពអាចទទួលយកបានតាមទម្រង់*

21. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បណ្ដឹងសាទុក្ខនេះអាចទទួលយកបានដោយផ្អែកតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. មាត្រា ៣៣ ថ្មី និង ៣៧ ថ្មី នៃច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក. និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីប្រើប្រាស់យុត្តាធិការដែលជាអន្ទានុសិទ្ធិក្នុងការការពារអត្ថប្រយោជន៍យុត្តិធម៌ និងរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[44]។

22. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ការខកខានរបស់អង្គបុរេជំនុំជម្រះ និង សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យភាពទាល់ច្រកផ្នែកនីតិវិធីចេះតែបន្តទៅមុខ និងមានហានិភ័យនៃព្យសនកម្មដែលពុំអាចស្រោចស្រង់បានដល់ការគ្រប់គ្រងយុត្តិធម៌ក្នុងសំណុំរឿង ០០៣[45] និងបានអះអាងថា ការស្វែងរកដំណោះស្រាយពីចៅក្រមដែលបានសម្រេចថារឿងក្ដីនេះត្រូវបដិសេធចោលនោះ គឺជាការយល់ខុស និងអាចបណ្ដាលឱ្យមានព្យសនកម្មដែលពុំអាចស្រោចស្រង់បាន និងភាពមិនយុត្តិធម៌[46]។

23. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បើគ្មានកិច្ចអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូលទេ កិច្ចដំណើរការនីតិវិធីនៃរឿងក្ដីនេះនៅតែពុំមានច្រកចេញរួច ដែលនេះ គឺជាយុត្តិនិសេធដោយបានរំលោភបំពានលើអាណត្តិរបស់ អ.វ.ត.ក. និងគោលការណ៍ជាសារវ័ន្ត[47]។

---

[43] សារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតឱ្យប្រកាសថាតើ សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងដាក់ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែរ ឬយ៉ាងណា ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D273/1។

[44] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៤២-៤៥។

[45] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៤៦-៤៨។

[46] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៤៨-៥០។

[47] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៥១។

24. ក្នុងសារណាតប មេធាវីការពារក្តី មាស មុត បានលើកឡើងថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពុំអាចទទួលយកបានតាមទម្រង់ និងគប្បីត្រូវបានបដិសេធចោល ដោយសារពុំបានផ្តល់ហេតុផលដែលជឿជាក់បាន ដូចជាកំហុសនៅក្នុងសំអាងហេតុ ឬការប្រែប្រួលនូវកាលៈទេសៈដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើយុត្តិកម្មក្នុងការសម្រេចក្នុងសំណុំរឿង ០០៣ ផ្សេងពីសំណុំរឿង ០០៤/២ ឡើយ[48]។

## គ. ច្បាប់ជាធរមាន

25. មាត្រា ៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះតុលាការកំពូលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង។

26. ផ្អែកតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលបានកំណត់ក្នុងវិធាន ១០៤(១) និង ១០៥(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកលើមូលដ្ឋានដូចតទៅ៖ ក) កំហុសអង្គច្បាប់ ដែលបណ្តាលឱ្យសាលក្រម ឬសេចក្តីសម្រេចមោឃៈ ឬ ខ) កំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ឬកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

## ឃ. ការពិភាក្សា

*ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខតាមវិធាន ១០៤ និង ១០៥ នៃវិធាផ្ទៃក្នុង*

27. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កម្រងច្បាប់នៃ អ.វ.ត.ក. ពុំបានដាក់បញ្ចូលបទប្បញ្ញត្តិដែលគាំទ្រភាគីឱ្យធ្វើបណ្តឹងសាទុក្ខចេញពីអង្គបុរេជំនុំជម្រះមកអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងកិច្ចដំណើរការនីតិវិធី ជាពិសេសទៅលើយុត្តាធិការនៃបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះនៅដំណាក់កាលមុនការជំនុំជម្រះឡើយ។ យន្តការផ្នែកនីតិវិធីផ្សេងគ្នាដែលបានបង្កើតឡើងក្នុងវិធានផ្ទៃក្នុងប្រាប់ភាគីអំពីវិធីសាស្ត្រក្នុងការដាក់បណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះនេះ។ វិធានផ្ទៃក្នុងបានកម្រិត

[48] សារណាតបរបស់ មាស មុត ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២១ ឯកសារលេខ 3/1 កថាខណ្ឌ ១-១៨។

សមត្ថកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកតាមវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុង។

28. បើទោះបីមានការយល់ច្បាស់អំពីយុត្តាធិការដែលមានកម្រិតរបស់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តដំណើរការនីតិវិធីដាក់'សំណើ'ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៣ ដែលពុំមានការជាប់ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែផ្ទុយទៅវិញជា *បណ្តឹងសាទុក្ខ*ប្រឆាំងនឹង"ការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចដែលតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[49]។

29. ក្នុងការសម្រេចលើភាពអាចទទួលយកបាននៃ *បណ្តឹងសាទុក្ខនេះដែលហៅដោយខ្លួនឯង* អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយលើបញ្ហាថាតើ *សំណើ*របស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាបណ្តឹងសាទុក្ខដែលអាចត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះ ដែរ ឬយ៉ាងណា។ 'សំណើ'នេះតាមការកត់សម្គាល់មានចំណងជើងថា *បណ្តឹងសាទុក្ខ* បានយោងទៅលើមាត្រា ១២(២) នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក. មាត្រា ៣៣ ថ្មី និង ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដែលពុំបានជាប់ពាក់ព័ន្ធទៅនឹងការធ្វើបណ្តឹងសាទុក្ខនៅមុខអង្គជំនុំជម្រះតុលាការកំពូល ដូចនេះ ជាការបញ្ចូលគ្នានូវនីតិវិធីសម្រាប់ធ្វើបណ្តឹងសាទុក្ខ។ ជាក់ស្តែង ការដែលសហព្រះរាជអាជ្ញាអន្តរជាតិពុំបានសំអាងទៅលើបទប្បញ្ញត្តិពាក់ព័ន្ធ ក្នុងការគាំទ្របណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញយ៉ាងច្បាស់អំពីការភាន់ច្រឡំ និងការបែងចែកពុំត្រឹមត្រូវតាមប្រភេទ។ ដោយពុំចាំបាច់លើកបន្ថែមទៀត អង្គជំនុំជម្រះកំណត់ថា *សំណើ*របស់សហព្រះរាជអាជ្ញាអន្តរជាតិពុំមែនជាបណ្តឹងសាទុក្ខដែលស្ថិតក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូលផ្អែកតាមវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុង។ ជាការសមស្រប ដើម្បីជៀសវាងការភាន់ច្រឡំជាសក្តានុពល អង្គជំនុំជម្រះតុលាការកំពូលនឹងចាត់ទុកថា ជា'សំណើ'ក្នុងបរិបទនៃការពិភាក្សាបច្ចុប្បន្ន។

*ភាពអាចទទួលយកបាននៃ'សំណើ' ដើម្បីអត្ថប្រយោជន៍យុត្តិធម៌*

30. បន្ថែមលើនេះ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍ស្តីពីភាពអាចទទួលយកបាន សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិក្នុងការការពារអត្ថប្រយោជ

[49] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3)។

ន៍យុត្តិធម៌ និងរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[50]។ ចុងក្រោយ មេធាវីការពារក្តី មាស មុត ស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធសំណើនេះចោលដោយពុំចាំបាច់ពិនិត្យលើអង្គសេចក្តី។

31. បើទោះបីសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានកំណត់ថា ពុំអាចទទួលយកបានដោយអនុលោមតាមមាត្រា ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សំណើនេះបានសុំនូវការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់លើបញ្ហា ដែលអង្គជំនុំជម្រះជឿជាក់ថា បានដោះស្រាយពីមុនរួចមកហើយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៤/២[51] ដែលសេចក្តីសម្រេចនោះមានការបង្ហាញប្រហាក់ប្រហែលគ្នាទាក់ទងទៅនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះស្តីពីការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត។

32. អង្គជំនុំជម្រះរំឮកថា ម្តងម្កាល អង្គជំនុំជម្រះទទួលយកសំណើរបស់ភាគីសុំការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់[52]។ សំណើសុំការបំភ្លឺ ឬសេចក្តីណែនាំផ្នែកច្បាប់ អាចចេញពីស្ថាប័នតុលាការដទៃទៀត ឬភាគីក្នុងកិច្ចដំណើរការនីតិវិធី[53]។ ក្នុងសំណុំរឿង ០០៤/២ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់បន្ទាប់ពីមានការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត ខុសច្បាប់ ហើយក្នុងសេចក្តីសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០៤/២ អង្គជំនុំជម្រះបានរំឮកពីច្បាប់រ៉ូម៉ាំងម៉ាកស៊ីម (maxim *"ubi jus, ibi remedium*) ថា ទីណាមានសិទ្ធិទីនោះមានសំណង ទីណាច្បាប់បង្កើតសិទ្ធិ ទីនោះគប្បីមានសំណងតបទៅនឹងការរំលោភសិទ្ធិ"[54] និងបានដឹងអំពីកាលៈទេសៈខុសប្រក្រតីដែលកើតមានចំពោះមុខអង្គបុរេជំនុំជម្រះ ដែលឈានទៅ

---

[50] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៤២-៤៥។

[51] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងលើអានុភាពនៃសំណុំរឿង ០០៤/២ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1/1/2 ("សេចក្តីសម្រេចសំណុំរឿង ០០៤/២ (E004/2/1/1/2)")។

[52] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារលេខ E284/2/1/2 សេចក្តីសម្រេចសំណុំរឿង ០០៤/២ (E004/2/1/1/2) សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំចំណាត់ការចាំបាច់ពីអង្គជំនុំជម្រះតុលាការកំពូលក្នុងការធានានូវសិទ្ធិជាសារវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការតំណាងនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២០ ឯកសារលេខ E004/2/6។

[53] សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E138/1/10/1/5/8/2 កថាខណ្ឌ ១២។

[54]សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៥៩។

ដល់ភាពទាល់ច្រក[55]។ ជាលទ្ធផល អង្គជំនុំជម្រះបានសម្រេចថា "កាលៈទេសៈពិសេសនៃរឿងក្តី ០០៤/២ តម្រូវថា សហព្រះរាជអាជ្ញាអន្តរជាតិ អោ អាន ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន មានសិទ្ធិទទួលបានការរំពឹងទុក និងទទួលបានការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់ [...]។ ការទុកឱ្យស្ថិតក្នុងភាពមិនច្បាស់លាស់តាមផ្លូវតុលាការ បានបំពានជាសារវន្តនូវក្តីរំពឹងត្រឹមត្រូវសមស្របនោះ។ ដូច្នេះ អង្គជំនុំជម្រះនេះគឺជាតុលាការចុងក្រោយក្នុងការផ្តល់នូវការបំភ្លឺនេះ"[56]។ ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវ អង្គជំនុំជម្រះបន្តប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងពិចារណាលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

33. ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះនឹងធ្វើចំណាត់ការដោយស្របតាមមាត្រា ៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. ដែលចែងថា អង្គជំនុំជម្រះតុលាការកំពូលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង។ ដោយសារជាអង្គជំនុំជម្រះសម្រេចចុងក្រោយ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះពុំតម្រូវឱ្យលើកបញ្ហាប្រហាក់ប្រហែលគ្នាមកជំនុំជម្រះសាឡើងវិញដែរ ប៉ុន្តែសម្រាប់គោលបំណងដែលមានកម្រិតតិចតួច គឺដើម្បីបញ្ជាក់សាឡើងវិញនូវគោលជំហរមិនប្រែប្រួលរបស់ខ្លួន និងដើម្បីកែតម្រូវ កំហុសឆ្គងក្នុង'សំណើ'របស់សហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះនឹងត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងផ្តល់ការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់ដើម្បីអត្ថប្រយោជន៍យុត្តិធម៌លើ (i) អានុភាពនៃការពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ii) បញ្ហាថាតើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះជាឯកច្ឆន្ទត្រូវបានរកឃើញថា មានសុពលភាព ដែរ ឬយ៉ាងណា[57] និង (iii) ស្ថានភាពនៃសំណុំរឿង ០០៣។

## អង្គសេចក្តី

*អានុភាពនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣*

34. អង្គជំនុំជម្រះពុំពិនិត្យសាឡើងវិញលើអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងកថាខណ្ឌ ៥៣-៦៨ ទាំងមូល ដែលថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាពុំមែនជាការខុសច្បាប់ ដូច្នេះមានសុពលភាព និងថា រឿងក្តីនេះគប្បីបន្តនីតិវិធីទៅជំនុំជម្រះ នោះទេ ដោយសារការធ្វើដូច្នោះគឺតម្រូវឱ្យមានការពិចារណាឡើងវិញលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣។ រំឭកថា កា

---

[55] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៥៩។

[56] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៦០។

[57] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៥៣-៨២។

វពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ ដែលបានចេញនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១ ត្រូវបានប្រកាសជាឯកច្ឆន្ទថា "ការចេញនូវដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ រំលោភបំពានលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[58]។ ក្នុងផ្នែកសម្រេចសេចក្តី អង្គបុរេជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា "ផ្អែកលើវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចបច្ចុប្បន្ននេះបិទផ្លូវតវ៉ា"[59]។ ការពិចារណារបស់អង្គបុរេជំនុំជម្រះដែលបានជូនដំណឹងជាសាធារណៈ និងប្រកាសជាឯកច្ឆន្ទថា បិទផ្លូវតវ៉ា ត្រូវបានចាត់ទុកថា ពេញលេញ។ អង្គជំនុំជម្រះវិញ្ញកបន្ថែមទៀតថា ក្នុងសេចក្តីសម្រេចសំណុំរឿង ០០៤/២ បានបញ្ជាក់ថា ផ្នែកសម្រេចសេចក្តី និងការប្រកាសត្រូវបានយល់ស្របជាឯកច្ឆន្ទដោយចៅក្រមប្រាំរូបនៃអង្គបុរេជំនុំជម្រះដែលបានចុះហត្ថលេខារៀងៗខ្លួន និងបានសន្និដ្ឋានថា ការពិចារណាណាមួយលើសុពលភាពនៃដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នានេះ ពិតណាស់ គឺជាការពុំចាំបាច់[60]។ អង្គជំនុំជម្រះក៏បានសង្កេតផងដែរថា "រឹតតែជាការពុំជាប់ពាក់ព័ន្ធបន្ថែមទៀត នៅពេលដែលអង្គបុរេជំនុំជម្រះពុំបានទទួលមតិភាគច្រើនលើសលុបដែលតម្រូវក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ភាគីប្រឆាំងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា ដោយសារផ្នែកនេះនៃ*សេចក្តីពិចារណា* ក្លាយទៅជារឿងលែងចាំបាច់"[61]។ អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០៣ បានសម្រេចដូចគ្នាក្នុងផ្នែកដែលមានភាពឯកច្ឆន្ទនៃផ្នែកសម្រេចសេចក្តី ដែលមានចុះហត្ថលេខាដោយចៅក្រមប្រាំរូបនៃអង្គបុរេជំនុំជម្រះ។ យោងតាមអានុភាពនេះ គោលជំហររបស់អង្គជំនុំជម្រះតុលាការកំពូលពុំមានការប្រែប្រួលឡើយ។

35. ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ផលវិបាកជាក់លាក់ច្បាស់លាស់នៃការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះដែលថា សេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៣ បិទផ្លូវតវ៉ាដោយផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង បានបង្ហាញថា ជាការបញ្ចប់រឿងក្តីនេះ។ ការប្រកាសជាឯកច្ឆន្ទដោយចៅក្រមប្រាំរូបនៃអង្គបុរេជំនុំជម្រះ បានពង្រឹងការសម្រេចរបស់ខ្លួនដែលធ្វើឱ្យបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ពុំទទួលបានជោគជ័យ ដូច្នេះបញ្ចប់បណ្តឹងឧទ្ធរណ៍ និងបញ្ចប់រឿងក្តី។

---

[58] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 និងឯកសារលេខ D267/35) ផ្នែកសម្រេចសេចក្តី។

[59] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 និងឯកសារលេខ D267/35) ផ្នែកសម្រេចសេចក្តី។

[60] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៥៣។

[61] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៥៣។

36. ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល ព្រមទាំងសំអាងផ្លូវច្បាប់ ពុំគប្បីត្រូវបានធ្វើប៉ះពាល់ដោយការមិនគោរពតាមជាក់ស្តែងលើយុត្តិសាស្ត្រក្នុងរឿងក្តី ០០៤/២ ដែលជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុ និងសេចក្តីសន្និដ្ឋានស្ទើរតែដូចគ្នាទាំងស្រុងរបស់អង្គបុរេជំនុំជម្រះ។ នេះអាចបង្កឱ្យមានការសង្ស័យលើសេចក្តីសម្រេចដ៏សំខាន់របស់អង្គជំនុំជម្រះតុលាការកំពូល ជាពិសេសតាមរយៈការបន្តស្នើសុំឥតឈប់ឈរនូវការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងលើកតែចំណុចណាដែលស្របនឹងគោលជំហររបស់ខ្លួន។ ដូចនេះ សហព្រះរាជអាជ្ញាអន្តរជាតិខកខានក្នុងការបង្ហាញឱ្យអង្គជំនុំជម្រះជឿជាក់ដើម្បីកែប្រែជាផ្លូវការ ឬច្រានចោលយុត្តិសាស្ត្ររបស់ខ្លួនឡើយ។

*បញ្ហាថាតើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានយល់ឃើញជាឯកច្ឆន្ទថា មានសុពលភាព ដែរ ឬយ៉ាងណា*

37. មតិរបស់ចៅក្រមអង្គបុរេជំនុំជម្រះមានដូចតទៅ៖ ចៅក្រមអន្តរជាតិបានបញ្ជាក់អះអាងនូវសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបានសម្រេចថា "អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកសំណុំរឿង ០០៣ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង" និងថា "ដីកាលើកលែងចោទប្រកាន់ ពុំមានសុពលភាពទាំងស្រុង"[62]។ ដោយផ្អែកលើបទប្បញ្ញត្តិដូចគ្នា វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ចៅក្រមជាតិបានប្រកាសថា "ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា និងមានសុពលភាពទាំងពីរ" និងថា"សហចៅក្រមស៊ើបអង្កេតទទួលបានឋានៈស្មើគ្នា និងដោយផ្អែកលើករណីពិសេសនៃសច្ចធារណ៍និរទោស ច្បាប់ជាធរមាន ពុំអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះសម្រេចថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតណាមួយ មានឧត្តមភាពជាងនោះឡើយ។ អាស្រ័យហេតុនេះ ដីកាដំណោះស្រាយទាំងពីរ មានតម្លៃស្មើគ្នា"[63]។ ចៅក្រមជាតិបន្ទាប់មកបានបន្តលើកឡើងថា "សំណុំរឿង ០០៣ ប្រឆាំងនឹងជនត្រូវចោទ មាស មុត គប្បីត្រូវរក្សាទុកក្នុងបណ្ណសាររបស់ អ.វ.ត.ក."[64]។

---

[62] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 និងឯកសារលេខ D267/35) មតិរបស់ចៅក្រម OLIVIER BEAUVALLET និង KANG JIN BAIK ផ្នែកសម្រេចសេចក្តី ទំព័រ ១៤៥។

[63] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 និងឯកសារលេខ D267/35) មតិរបស់ចៅក្រម ប្រាក់ គឹមសា ន័យ ចុល និង ហួត វុទ្ធី កថាខណ្ឌ ១១៥-១១៧។

[64] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ (ឯកសារលេខ D266/27 និងឯកសារលេខ D267/35) មតិរបស់ចៅក្រម ប្រាក់ គឹមសា ន័យ ចុល និង ហួត វុទ្ធី កថាខណ្ឌ ១១៥-១១៨ ទំព័រ ៤២។

38. បន្ទាប់ពីពិចារណាលើមតិខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិធ្វើការបកស្រាយពុំត្រឹមត្រូវថា អង្គបុរេជំនុំជម្រះបានចាត់ទុកជាឯកច្ឆន្ទនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះថា មានសុពលភាព ដូចនេះ មានន័យថា ដីកាចោទប្រកាន់ពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុបឡើយ[65]។ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តដោយពុំត្រឹមត្រូវថា ការដែលចៅក្រមអង្គបុរេជំនុំជម្រះទាំងប្រាំរូបបានយល់ស្របគ្នាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើ មាស មុត មានសុពលភាព បង្កើតបានជាសេចក្តីសម្រេចមតិភាគច្រើនលើសលុបតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[66]។

39. អង្គជំនុំជម្រះរំឭកថា ខ្លឹមសារនៃភាពឯកច្ឆន្ទ គឺផ្ទុះបញ្ចាំងពីភាពចាំបាច់ក្នុងដំណើរការសម្រេចសេចក្តីរបស់តុលាការនៅ អ.វ.ត.ក. ក្នុងមាត្រា ៤ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. មាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. និងវិធាន ៩៨(៤) ១០១(២) ១១១(៦) ១១២(៣) ១២ *ស្ទួនពីរ* (៣) ៣៩(៥) និង ៧១ (៣) នៃវិធានផ្ទៃក្នុង។ មតិជំទាស់ដែលហៅថា *votum separatum* ត្រូវបានរំពឹងទុកផងដែរ ក្នុងករណីដែលមតិភាគច្រើនលើសលុបពុំអាចរកបាន។ មតិរបស់ចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ត្រូវចេញផ្សាយដោយផ្អែកតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.[67]។ ដូច្នេះ ត្រឹមមតិរបស់ចៅក្រមពុំមានអានុភាពផ្លូវច្បាប់ក្នុងរឿងក្តីនេះឡើយ។

40. តាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ក្នុងការអនុវត្តតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. សម្រាប់ឱ្យសេចក្តីសម្រេចមួយមានអានុភាពផ្លូវច្បាប់អាចអនុវត្តបាន ត្រូវតែជាសេចក្តីសម្រេចឯកច្ឆន្ទ ឬត្រូវបានទទួលយល់ព្រមដោយមតិភាគច្រើនលើសលុបទើបមានអានុភាពផ្លូវច្បាប់។

41. ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា មានការទទួលបានឯកច្ឆន្ទតាមដោយការបូកបញ្ចូលគ្នាទៅជាមតិភាគច្រើនលើសលុបដោយផ្អែកលើមតិរបស់ចៅក្រមអង្គបុរេជំនុំជម្រះដូចបានលើកខាងលើ និងចាត់ទុកថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព គឺជាគំនិតមិនស្មោះត្រង់ និងមានវិការៈជាសារវ័ន្ត។ ការអះអាងពុំត្រឹមត្រូវបែបនេះ មានអានុភាពប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ។ ដូចបានបង្ហាញក្នុងសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការបកស្រាយមួយបែបផ្សេង និងមានលក្ខណៈ

---

[65] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៥៣-៨២។

[66] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៦៩។

[67] បទបញ្ញត្តិមួយចំនួននៃវិធានផ្ទៃក្នុង គាំទ្រការចេញផ្សាយមតិក្នុងវិធាន ៧១(៤)(ឃ) ៧២(៤)(ង) ៧៧(១៤) ៧៨ ៧៩ ១០១ (២) និង (៦) និង ១០២(១)។

ផ្ទុយ គឺក្នុងគោលបំណងគាំទ្រគោលជំហររបស់ខ្លួន។ ជាឧទាហរណ៍ ដូចជាការដែលថា សេចក្ដីសន្និដ្ឋានទទួលបានភាពឯកច្ឆន្ទ បើទោះបីជាពុំត្រូវបានដាក់បញ្ចូលក្នុង“ផ្នែកសម្រេចសេចក្ដីរួមគ្នា”នៃសេចក្ដីពិចារណា ឬចៅក្រមចូលរួមក្នុងផ្នែកសម្រេចសេចក្ដីពិតមែន ប៉ុន្តែតាមរយៈសំអាងហេតុមួយបែបផ្សេង[68]។ ទាំងនេះបានធ្វើឱ្យបាត់បង់ភាពគួរជឿជាក់នៃទឡ្ហីករណ៍ដែលអះអាងថា បើទោះបីជាអង្គជំនុំជម្រះនេះសម្រេចថា ពុំមានការសម្រេចជាឯកច្ឆន្ទ*ជាក់ស្ដែង*លើសុពលភាពដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចបញ្ជូនទៅជំនុំជម្រះ ដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប[69]។ ការភាន់ច្រឡំនេះបានធ្វើឱ្យការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិពុំមានមូលដ្ឋានគាំទ្រទាំងស្រុង។

*ស្ថានភាពរបស់សំណុំរឿង ០០៣*

42. ដោយរំឭកនូវសេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន និងជាក់លាក់ ‘សំណើ’របស់សហព្រះរាជអាជ្ញាអន្តរជាតិឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ពុំចាំបាច់ត្រូវពិចារណាតទៅទៀតទេ។

43. អង្គជំនុំជម្រះរំឭកបន្ថែមទៀតថា វិធាន ៧៩(១) នៃវិធានផ្ទៃក្នុងចែងថា “អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលបណ្ដឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ” ប៉ុន្តែក្នុងសំណុំរឿង ០០៣ ពុំមានការបញ្ជូនសំណុំរឿងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នេះបញ្ជាក់ច្បាស់ថា សំណុំរឿង ០០៣ ត្រូវបានបញ្ចប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលមុនការជំនុំជម្រះ។

---

[68] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៧០-៧១។

[69] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារលេខ 3) កថាខណ្ឌ ៧៦។

## ខ. ផ្នែកសម្រេចសេចក្តី

44. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចប្រកាសថា ដោយសារគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន និងជាក់លាក់ សំណុំរឿង ០០៣ ត្រូវបានបញ្ចប់ និង

**បដិសេធ** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

ចៅក្រម Maureen HARDING CLARK មានមតិជំទាស់។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១

ចៅក្រម **គង់ ស្រ៊ីម** ប្រធាន

Judge Chandra Nihal JAYASINGHE

ចៅក្រម **សោម សិរីវឌ្ឍ**

Judge Florence Ndepele MWACHANDE-MUMBA

ចៅក្រម **ម៉ុង មុន្នីចរិយ៉ា**

ចៅក្រម **យ៉ា ណារិន**

# មតិជំទាស់របស់ចៅក្រម MAUREEN HARDING CLARK

## I. កំណត់សម្គាល់បឋម

1. ជាបឋម ចៅក្រមរូបនេះបានសង្កេតឃើញថា សំណើដែលហៅថា បណ្តឹងសាទុក្ខដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពុំមែនជាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងពុំមែនជាបណ្តឹងសាទុក្ខភ្លាមៗផ្អែកតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង និងរំឭកថាវិធានផ្ទៃក្នុងចែងជាក់លាក់ថា ពុំមានបណ្តឹងសាទុក្ខដែលកើតចេញពីសេចក្តីសម្រេចណាមួយរបស់អង្គបុរេជំនុំជម្រះឡើយ[70]។

2. សំណើនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នៅពេលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំការអនុញ្ញាតដាក់សារណាបន្ទាន់ជាភាសាអង់គ្លេស[71]។ សំណើសុំនោះត្រូវបានបដិសេធចោល ដោយសារពុំមានកាលៈទេសៈពិសេសតម្រូវ និងត្រូវគោរពលក្ខខណ្ឌដែលកំណត់ថា រាល់ឯកសារត្រូវដាក់ជាពីរភាសាផ្លូវការរបស់តុលាការ[72]។ នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់“*បណ្តឹងសាទុក្ខស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.*” ជាភាសាខ្មែរ និងអង់គ្លេស។ សំណើនេះត្រូវបានទទួល និងត្រូវបានដាក់លេខបណ្តោះអាសន្នដោយអង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះ ពុំបានដឹងអំពីខ្លឹមសារនៃសំណើ រហូតទាល់ឯកសារនេះ ត្រូវបានដាក់ចូលសំណុំរឿង និងបានជូនដំណឹងដោយពុំមានការប៉ះពាល់ដល់មូលដ្ឋានផ្នែកយុត្តាធិការឡើយ។

3. បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់“បណ្តឹងសាទុក្ខ”បន្ថែមក្នុងលក្ខខណ្ឌប្រហាក់ប្រហែលគ្នា ក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងជនត្រូវចោទ យឹម ទិត្យ[73]។ សហមេធាវីការពារក្តី មាស មុត[74] និង យឹម ទិត្យ[75] បានជំទាស់ទៅនឹងសំណើនេះ។ សេចក្តីលម្អិតដែលមានក្នុងសារណារបស់ភាគី

---

[70] *សូមមើល* វិធាន ១១(៥) និង (៦) ៣៨(៣), ៧១(៤)(គ), ៧២(៤)(ឃ), ៧៧(១៣), ៧៧ ស្ទួន។

[71] សំណើរបស់សហព្រះរាជអាជ្ញាជាតិសុំដាក់សារណាមួយភាសា ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២១។

[72] សេក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាជាតិសុំដាក់សារណាមួយភាសា ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១។

[73] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ឯកសារលេខ ២, ថ្ងៃទី ២០ ខែ តុលា ២០២១ (“សំណើរបស់សហព្រះរាជអាជ្ញាជាតិក្នុងសំណុំរឿង ០០៤”)។

[74] សារណាតបរបស់ មាស មុត។

ទាំងអស់រួមជាមួយនឹងឯកសារដែលយោងនៅក្នុងជើងទំព័រ បង្ហាញក្នុងប្រវត្តិនីតិវិធីទាំងមូល។ រហូតទាល់តែឯកសារទាំងនោះត្រូវបានពិភាក្សា ទើបព័ត៌មានដែលពុំត្រូវបានគេដឹងអំពីការបរាជ័យក្នុងការប៉ុនប៉ងចោទប្រកាន់រឿងក្ដីបន្ថែមទៀតចាប់តាំងពីការជំនុំជម្រះក្នុងសំណុំរឿង ០០១ និង ០០២ នឹងត្រូវបង្ហាញ។ សំណុំរឿង ០០១ និង ០០២ គឺជាសំណុំរឿងដែលត្រូវបានជំនុំជម្រះនៅ អ.វ.ត.ក. តែប៉ុណ្ណោះក្នុងរយៈពេល ១៥ ឆ្នាំ។ ជនជាប់ចោទទីមួយ កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ត្រូវបានជំនុំជម្រះដែលជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ("DK") ចំណែកឯ ជនជាប់ចោទ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ត្រូវបានចោទប្រកាន់ជាមេដឹកនាំជាន់ខ្ពស់[76]។

4. អង្គជំនុំជម្រះតុលាការកំពូលមានតួនាទីឆ្លើយតប បូករួមជាមួយនឹងសេចក្តីសង្កេតរបស់ខ្លួន និងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ គួរឱ្យសោកស្តាយ ខ្ញុំមានតែម្នាក់ឯងដែលជាមតិភាគតិចសរសេរសេចក្តីសម្រេចជំទាស់ស្តីពីសំណើដែលមានលក្ខណៈសំខាន់។ សហសេវិកជាទីគោរពរបស់ខ្ញុំបានកំណត់ថា សហព្រះរាជអាជ្ញាអន្តរជាតិពុំអាចទទួលបានជោគជ័យក្នុងសំណើរបស់ខ្លួន ដោយសារតាមទស្សនៈរបស់ពួកគាត់ អង្គជំនុំជម្រះពុំមានយុត្តាធិការពិចារណាលើសំណើ និងពិតប្រាកដណាស់ពុំមានយុត្តាធិការផ្តល់សំណងណាមួយឡើយ ដែលនេះជាការឆ្លើយតបទៅនឹងសំណើ មាស មុត និង យឹម ទិត្យ។ បើទោះបីជាយើងមានការសន្និដ្ឋានដូចគ្នាក៏ដោយ ក៏ប៉ុន្តែយើងបានដើរតាមផ្លូវផ្សេងៗគ្នា។

5. នេះគឺជាមតិជំទាស់តែមួយគត់នៃអង្គជំនុំជម្រះ។

---

[75] សារណាតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ឯកសារលេខ ២/១ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២១ ("សារណាតបរបស់ យឹម ទិត្យ ក្នុងសំណុំរឿង ០០៤")។

[76] មាត្រា ១ នៃកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធទៅនឹងការចោទប្រកាន់តាមច្បាប់កម្ពុជាលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ("កិច្ចព្រមព្រៀង អ.វ.ត.ក.")។ មាត្រា ១, ២*ថ្មី* ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ នស/រកម/*១០០៤/០០៦* ដែលបានធ្វើវិសោធថ្ងៃទី *២៧ ខែ តុលា ឆ្នាំ ២០០៤* ("ច្បាប់ អ.វ.ត.ក.") ។

## II. ការត្រួតពិនិត្យមើលស្ថានការណ៍ក្រោយព្រឹត្តិការណ៍

6. សំណើនេះពុំមែនជាសំណើដែលអាចដោះស្រាយបានតាមធម្មតានោះទេ។ ជាការចាំបាច់ដែល ត្រូវស្វែងយល់អំពីការខ្វែងយោបល់គ្នាជាសារវ័ន្តរវាងសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតចៅក្រមអង្គបុរេជំនុំជម្រះជាមុនសិន។ ប្រវត្តិនីតិវិធីដំបូងមានសារៈសំខាន់ ហើយអ្វីដែលកើតឡើងបន្តបន្ទាប់មកនោះនឹងត្រូវបង្ហាញលម្អិតជាងធម្មតា។ ដោយសារប្រវត្តិនីតិវិធីមានការបំភ្លឺខ្លះៗផងដែរ ទើបមតិជំទាស់នេះតាមដានស្ថានការណ៍ដែលបានកើតឡើងក្រោយព្រឹត្តិការណ៍នោះ។

7. ជាការលំបាកកំណត់ឱ្យដឹងថា តើចំណុចចាប់ផ្តើមនៃបញ្ហាស្មុគ្រស្មាញទាំងនេះដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនោះ ស្ថិតនៅត្រង់ណា។ ត្រឹមតែដឹងច្បាស់ថា បញ្ហាវិវាទដំបូងដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៣ និង ០០៤ ពុំបានចាប់ផ្តើមឡើងដោយតែភាពទាល់ច្រកផ្នែកច្បាប់ ឬពុំមានភាពច្បាស់លាស់ផ្នែកច្បាប់ដែលកើតចេញពីដីកាដំណោះស្រាយផ្ទុយគ្នា ឬដោយសារអង្គបុរេជំនុំជម្រះគ្មានលទ្ធភាពអាចស្វែងរកមតិស្របគ្នា ដែលមានសំអាងហេតុសមស្របតាមផ្លូវតុលាការ និងអាចឱ្យដីកាដំណោះស្រាយនោះ យកជាបានការនោះទេ។ ដើមហេតុនៃបញ្ហាបច្ចុប្បន្នកើតឡើងនៅមុនសំណើទាំងនេះអស់រយៈពេលជាច្រើនឆ្នាំ និងត្រូវត្រឡប់ទៅរកការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាក្នុងឆ្នាំ ២០០៨ ដែលមានផលវិបាកបន្តរហូតមកដល់សព្វថ្ងៃនេះ។ ការខ្វែងយោបល់គ្នាដែលជាមូលដ្ឋាននោះបានកើតមានឡើង និងគប្បីត្រូវបានស្គាល់ដោយការិយាល័យច្បាប់របស់អង្គការសហប្រជាជាតិ(“UN”) ឬតាមរយៈអ្នកសម្របសម្រួលដែលមានការប្រុងប្រយ័ត្នតាក់តែងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. និងកិច្ចព្រមព្រៀង អ.វ.ត.ក. ដែលច្បាប់នេះជាមូលដ្ឋានក្នុងការបង្កើត អ.វ.ត.ក.។ ដំណើរការមិនប្រក្រតី ត្រូវបានបង្ហាញឱ្យឃើញជាសាធារណៈក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[77] ក្នុងសេចក្តីថ្លែងការណ៍សាធារណៈរបស់

---

[77] *សូមមើល ឧ.* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ ឯកសារលេខ D1/1.3 ថ្ងៃទី ១៨ ខែ សីហា ២០០៩ (“សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាង សហព្រះរាជអាជ្ញា (D1/1.3)”។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេល និងសុំចំណាត់ស៊ើបសួរក្នុងសំណុំរឿង ០០៣ ឯកសារលេខ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១។ សំណុំរឿងលេខ ០០៣/១៦-១២-២០១១-អ.វ.ត.ក./អ.ប.ជ មតិរបស់ចៅក្រមអង្គបុរេជំនុំជម្រះ DOWNING និង CHUNG ស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២។ សេចក្តីសម្រេចស្តីពីបណ្តឹងលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីសុពលភាពនៃដីកាកោះចេញដោយចៅក្រមស៊ើបអង្កេតតែម្នាក់ ឯកសារលេខ D212/1/2/2 ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិ

សហចៅក្រមស៊ើបអង្កេត(បម្រុង)អន្តរជាតិ ដែលភ្ជាប់ជាមួយនឹងលិខិតសុំលាឈប់របស់គាត់[78] និងផ្អែកលើការយល់ដឹងនូវស្ថានការណ៍ក្រោយព្រឹត្តិការណ៍ ប្រសិនបើបញ្ហានេះពិតជាត្រូវបានរារាំងដោយពិតប្រាដកនោះ មិនអាចកើតមានឡើយ។

8. ពុំមានការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលត្រូវបានជំទាស់ដោយសហព្រះរាជអាជ្ញាជាតិចាប់តាំងពីឆ្នាំ ២០០៨ បានឈានដល់ការជំនុំជម្រះនោះទេ។ ការស៊ើបអង្កេតរយៈពេលដប់បីឆ្នាំដែលបានបន្តដោយសារតែយន្តការស្វ័យប្រវត្តិ ត្រូវបានធ្វើឡើងដោយពុំមានការចូលរួមពីសហព្រះរាជអាជ្ញាជាតិ និងអស់រយៈពេលជាច្រើនឆ្នាំដោយពុំមានការចូលរួមពីសហចៅក្រមស៊ើបអង្កេតជាតិ។ ទាំងនេះបាននាំយើងឱ្យមានបញ្ហាដូចសព្វថ្ងៃ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបង្ខំចិត្តត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នូវកិច្ចខិតខំប្រឹងប្រែងចុងក្រោយក្នុងការនាំជនត្រូវចោទ មាស មុត និង យឹម ទិត្យ ទៅជំនុំជម្រះ។

9. ដំបូងត្រូវពិនិត្យលើមូលហេតុដែលនាំឱ្យមានភាពទាល់ច្រកបែបនេះ។ សំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត កម្មវត្ថុនៃសេចក្តីសម្រេចបច្ចុប្បន្ន និងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ គឺបង្ហាញពីភាពខុសគ្នាៗនៃជាតិ វប្បធម៌ និងនយោបាយរវាងបុគ្គលដែលបំពេញតួនាទីជាសហព្រះរាជអាជ្ញាជាតិ សហចៅក្រមស៊ើបអង្កេតជាតិ និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ និងដទៃទៀតដែលជាសហតួនាទីស្មើ

---

សេចសំណើររបស់គាត់សុំព័ត៌មានពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ D208/1/1/2 ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ សេចក្តីពិចារណាលើសបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ មាស មុត កំបាំងមុខ D128/1/9 ថ្ងៃទី ០៣០ ខែ មីនា ឆ្នាំ ២០១៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចចេញសាឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើររបស់ មាស មុត សុំបដិសេធដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិអន្តរជាតិ ឯកសារលេខ D120/3/1/8 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦។

[78] *សូមមើលឧ.* សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ [Siegfried BLUNK]" ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-international-co-investigating-judge។ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ [Laurent KASPER-ANSERMET]" ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតជាតិ [យូ ប៊ុនឡេង]" ថ្ងៃទី ១២ ខែ តុលា ២០១១ គេហទំព័រ https://www.eccc.gov.kh/en/node/17495។

គ្នាជាមួយភាគីអន្តរជាតិ។ តាមរយៈភាពខុសគ្នាៗនោះ ត្រូវបានរកឃើញថា មានវិធីសាស្ត្រពីរដែលផ្ទុយគ្នាទាំងស្រុង និងនាំទៅដល់ការបែកបាក់ និងការពុំស្របគ្នាដែលមានអត្ថិភាពរហូតដល់បច្ចុប្បន្ននេះ។ ចៅក្រមអន្តរជាតិ គឺជាចៅក្រមជនជាតិបរទេសដែលមកពីប្រទេសផ្សេងៗ ដែលជារឿយៗ ប៉ុន្តែមិនជានិច្ចកាលតែងតែ ចូលរួមចំណែកក្នុងប្រព័ន្ធច្បាប់ជាមួយកម្ពុជា[79]។ យើង គឺជាភ្ញៀវក្នុងប្រទេសកម្ពុជា ដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងត្រូវបានឯកភាពដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា។ យើងពុំចេះភាសាខ្មែរ ដូច្នេះធ្វើឱ្យមានការបាត់បង់អត្ថន័យនៃច្បាប់ដែលមានភាពសំខាន់ខ្លះ ប៉ុន្តែយើងពុំទទួលរងផលប៉ះពាល់ដោយសារវិវាទដូចបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនេះដែរ។ អាស្រ័យហេតុនេះ ដើម្បីឱ្យងាយស្រួលជាងនេះចៅក្រមអន្តរជាតិត្រូវដកថយហើយពិនិត្យជាសត្យានុម័តលើដំណើរការនីតិវិធី និងភស្តុតាងដែលមានអត្ថិភាពក្នុងក្របខ័ណ្ឌនៃច្បាប់បង្កើតឱ្យមាន អ.វ.ត.ក. កិច្ចព្រមព្រៀង អ.វ.ត.ក. និងវិធាននៃផ្ទៃក្នុង និងត្រូវកំណត់អត្តសញ្ញាណបទដ្ឋានអន្តរជាតិដែលជាធរមាន។ ចៅក្រមជាតិ ដែលបម្រើការក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា និងបទដ្ឋានជាតិអាចចាត់ទុកច្បាប់ដែលបង្កើតឱ្យមាន អ.វ.ត.ក. ថាត្រូវបានបង្កើតឡើងតាមរយៈគោលនយោបាយជាតិរួមទាំងការភ័យខ្លាចនូវអសន្តិសុខជាតិ។ ការលំបាកទាំងនេះ ត្រូវបានព្យាករណ៍ទុកដោយអ្នកសម្របសម្រួលនៃច្បាប់បង្កើត អ.វ.ត.ក. និងកិច្ចព្រមព្រៀង អ.វ.ត.ក. នៅពេលដែលដំណើរការនីតិវិធីស្វ័យប្រវត្តិពិសេសដែលលំអៀងទៅរកការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះ ជាជាងតាមការចង់បានរបស់ជាតិ និងនយោបាយដែលអាចយល់បាន និងត្រូវបានដាក់បញ្ចូលក្នុងកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះ និងការជំនុំជម្រះចំពោះមុខ អ.វ.ត.ក.[80]។ ទោះជាយ៉ាងណាក្តី វិសាលភាពនៃតួនាទី និងអានុភាពនៃបរិយាកាសជាតិ និងគោលនយោបាយពុំត្រូវបានស្វាគមន៍ឡើយ។

---

[79] កន្លងមក មានចៅក្រម១រូបពីប្រទេសអូស្ត្រាលី ១រូបពីមកពីប្រទេសអៀរឡង់ ១រូបមកពីជប៉ុន ១រូបមកពីហូឡង់ ១រូបមកពីនូវែលសេឡង់ ១រូបមកពីស្រីលង្កា ១រូបមកពីស៊ុយអែត ១រូបមកពីសំប៊ី ២រូបមកពីអាល្លឺម៉ង់ ២រូបមកពីសាធារណរដ្ឋកូរ៉េ ២រូបមកពីសហរដ្ឋអាមេរិក ៤រូបមកពីបារាំង និងអយ្យការ១រូបមកពីកាណាដា ២រូបមកពីសហរដ្ឋអាមេរិក។

[80] *សូមមើល* លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ផ្ញើទៅអង្គការសហប្រជាជាតិ បានផ្សាយក្នុងទស្សនាវដ្ដី *ការស្វែងរកការពិត* ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១ ឧបសម្ព័ន្ធ ៣ ភ្ជាប់ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ (ឯកសារលេខ ១០) ឯកសារលេខ ១០.៣ ("លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅនឹងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣)") លេខ ERN ០០២៩៥០១៧ (ភាសាអង់គ្លេស)។ អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បោះពុម្ពផ្សាយក្នុងទស្សនាវដ្តី *ការស្វែងរកការពិត* ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ឧសម្ព័ន្ធ ៤ ភ្ជាប់ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹង *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះ* ២៣/៧៦ *ក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.*

10. បញ្ហាដែលបានបង្កមកលើ អ.វ.ត.ក. ប្រហែលជាត្រូវបានបង្កើតឡើងនៅមុខថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ដែលបានស្នើសុំបើកកិច្ចស៊ើបសួរលើ ស៊ូ ម៉េត និង មាស មុត សម្រាប់ឧក្រិដ្ឋក្នុងយុត្តាធិការរបស់តុលាការនេះ[81] និងនៅថ្ងៃដដែលនោះ ក៏បានដាក់"អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាដោយអនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង"[82]នៅចំពោះមុខអង្គបុរេជំនុំជម្រះដោយបានអះអាងថា សហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងការចោទប្រកាន់ឧក្រិដ្ឋកម្មថ្មី ដែលបានកំណត់អត្តសញ្ញាណក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[83]។ តាមការបង្ហាញឃើញថា បញ្ហានេះពុំគួរទុកឱ្យកើតមានឡើង ដោយសារគ្មានការយល់ដឹងច្បាស់លាស់នៅមុនថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ថា ពុំមានកិច្ចសហការ ឬត្រូវបានដកខ្លួននោះទេ។

11. នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាបានចេញសេចក្តីថ្លែងការណ៍រួម ("សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា") ដែលបង្ហាញពីការខ្វែងយោបល់គ្នា ដែលត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ[84]។ នៅក្នុងសេចក្តីថ្លែងការណ៍នោះ សហព្រះរាជអាជ្ញាបានរៀបរាប់យ៉ាងច្បាស់លាស់គួរឱ្យសរសើរ និងតម្លាភាពនូវជំហររៀងៗខ្លួនថាៈ

> សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយយោងតាមសហព្រះរាជអាជ្ញាថា មានមូលហេតុអាចជឿ

ការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ (ឯកសារលេខ ១០) ឯកសារលេខ ១០.៤ ("អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤)") លេខ ERN ០០២៩៥០១៩, ០០២៩៥០២៨ (ភាសាអង់គ្លេស)។ អត្ថបទរបស់វិទ្យាស្ថានឈ្មោះ Open Society ស្តីពីការជ្រៀតជ្រែកផ្នែកនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខែ កក្កដា ឆ្នាំ ២០១០ ទំព័រ ៥។

[81] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា ឯកសារលេខ D1ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[82] អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាជាតិអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុសម្រាប់ការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ឯកសារលេខ ១ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ("អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាជាតិអន្តរជាតិ")។

[83] អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាជាតិអន្តរជាតិ។

[84]សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា" ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៩ គេហទំព័រ https://www.អ.វ.ត.ក..gov.kh/sites/default/files/media/Statement_OCP_០៥-០១-០៩_EN.pdf ("សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៩")។

ជាក់បានថា (១) ឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងសេចក្តីសន្និដ្ឋាននោះ ត្រូវបានប្រព្រឹត្តឡើង (២) ឧក្រិដ្ឋកម្មនោះស្ថិតក្នុងយុត្តាធិការរបស់តុលាការ និង (៣) ឧក្រិដ្ឋកម្មនោះគប្បីត្រូវបានស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត។ សហព្រះរាជអាជ្ញាអន្តរជាតិជឿជាក់ថា នេះគឺជាសំណុំរឿងចុងក្រោយដែលត្រូវចោទប្រកាន់ ដោយតុលាការនេះ និងនាំទៅរកការទទួលខុសត្រូវពេញលេញសម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ និងពុំជឿជាក់ថា ការចោទប្រកាន់នេះបានធ្វើឱ្យមានប៉ះពាល់ដល់សន្តិសុខ និងស្ថិរភាពសង្គមឡើយ។

សហព្រះរាជអាជ្ញាជាតិជឿជាក់ថា ការស៊ើបអង្កេតទាំងនោះពុំគប្បីត្រូវបានធ្វើឡើងដោយសារ (១) អស្ថិរភាពអតីតកាលរបស់កម្ពុជា និងតម្រូវការចាំបាច់បន្តដើម្បីការផ្សះផ្សាជាតិ (២) ស្មារតីរបស់កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (“កិច្ចព្រមព្រៀង”) និងស្មារតីនៃច្បាប់ដែលបង្កើតឱ្យមានតុលាការនេះ(“ច្បាប់បង្កើត អ.វ.ត.ក.”) និង (៣) អាណត្តិ និងថវិកាសម្រាប់តុលាការនេះ។ សហព្រះរាជអាជ្ញាជាតិយល់ថា តុលាការនេះគប្បីផ្តល់អាទិភាពដល់ការជំនុំជម្រះជនសង្ស័យទាំងប្រាំរូបដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងរួចហើយ ជាពិសេស ផ្អែកតាមសហព្រះរាជអាជ្ញាថា នៅពេលកិច្ចព្រមព្រៀង និងច្បាប់បង្កើត អ.វ.ត.ក. បានចែងត្រឹមតែការជំនុំជម្រះក្នុងចំនួនតូចប៉ុណ្ណោះ និងអះអាងថា អាណត្តិរបស់តុលាការនេះអាចត្រូវបានបំពេញគ្រប់គ្រាន់តាមរយៈការចោទប្រកាន់លើជនសង្ស័យដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងរួចរាល់ហើយ[85]។

12. មានការប្រែប្រួលតិចតួចក្នុងរយៈពេលដប់ពីរឆ្នាំកន្លងមកនេះ។ ក្រៅតែពីសារណារបស់សហព្រះរាជអាជ្ញាជាតិនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩[86] ដែលត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិចាត់ទុកថាជា“គំនិតគិតទុកជាមុនច្បាស់ក្រឡែត”[87] និងការអះអាងបន្ថែមថា ចំណាត់ការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ(ដែលត្រូវបានជំទាស់) ក្នុងការបើកការស៊ើបសួរដោយពុំបានឱ្យគាត់ដឹងនោះ គឺជាការស៊ើបសួរ

---

[85] សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៩។

[86] សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការបង្គាប់របស់អង្គបុរេជំនុំជម្រះឱ្យផ្តល់ភាពជាក់លាក់បន្ថែមទៀត ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ឯកសារលេខ ១៧ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩ (“សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការបង្គាប់របស់អង្គបុរេជំនុំជម្រះ”)។

[87] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសារណាតបសហព្រះរាជអាជ្ញាជាតិទៅនឹងការបង្គាប់របស់អង្គបុរេជំនុំជម្រះឱ្យផ្តល់ភាពជាក់លាក់បន្ថែម ឯកសារលេខ ៨ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ៧។

ដែលពុំត្រឹមត្រូវតាមច្បាប់[88] ពុំមានមូលហេតុបង្ហាញសម្រាប់ការបដិសេធមិនចោទប្រកាន់រឿងក្តីបន្ថែមទៀតឡើយ។

13. ការខ្វះចន្លោះក្នុងការយល់ដឹងរបស់ខ្ញុំអំពីចំណុចចាប់ផ្តើមដំបូងនៃការខ្វែងយោបល់គ្នារវាងវិធីសាស្ត្ររបស់ជាតិ និងអន្តរជាតិចំពោះរឿងក្តីទាំងពីរនេះ ដែលត្រូវបានចំណាត់ថ្នាក់សម្ងាត់ និងពុំត្រូវបានដាក់ចូលសំណុំរឿង ដោយអនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ត្រូវបានបំភ្លឺតាមរយៈសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ដែលបានដាក់នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២១[89]។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនដោយបានប្រកាសថា អង្គជំនុំជម្រះពុំអាចរកសម្លេងគាំទ្រយ៉ាងតិចពីថៅក្រមបួនរូបលើការសម្រេចស្តីពីការខ្វែងយោបល់គ្នានៅចំពោះមុខខ្លួនឡើយ[90]។ អាស្រ័យហេតុនេះ ចំណាត់ការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ផ្អែកតាមអានុភាពច្បាប់ ត្រូវតែយកទៅអនុវត្ត ស្របតាមយន្តការស្វ័យប្រវត្តិដែលថា ការចោទប្រកាន់ត្រូវតែបន្តទៅមុខ[91]។

14. ដោយសារសេចក្តីសម្រេចនេះគឺជាចំណុចរបត់មានសារៈក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ការពិនិត្យលម្អិតមានដូចតទៅ៖ វិវាទជាចម្បងរវាងសហព្រះរាជអាជ្ញា គឺពាក់ព័ន្ធទៅនឹងបញ្ហាថាតើ បុព្វកថានៃ

---

[88] សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការបង្គាប់របស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៨៦(គ) ("កិច្ចស៊ើបសួរបឋមដែលបានធ្វើឡើងឯកតោភាគីដោយសហព្រះរាជអាជ្ញាអន្តរជាតិ គឺជាការរំលោភលើច្បាប់ អ.វ.ត.ក. កិច្ចព្រមព្រាង និងវិធានផ្ទៃក្នុង ដែលតម្រូវឱ្យមានសហព្រះរាជអាជ្ញាពីរធ្វើការជាមួយគ្នាដោយសហការគ្នាបំពេញកិច្ចនីមួយៗ")។

[89] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៣ ឯកសារលេខ D266/28 និង D267/36 ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២១។

[90] ការកែកំហុសនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ឯកសារលេខ D1/1.2 ថ្ងៃទី ០៣១ ខែ សីហា ២០០៩ ("ការកែកំហុសនៃសេចក្តីពិចារណាទាក់ទងទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (ឯកសារលេខ D1/1.2)") កថាខណ្ឌ ៤៥។

[91] *សូមមើល* មាត្រា ២០ថ្មី នៃច្បាប់ អ.វ.ត.ក.។ វិធាន ៧១(៤)(គ) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ការកែកំហុសនៃសេចក្តីពិចារណាទាក់ទងទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា(ឯកសារលេខ D1/1.2) កថាខណ្ឌ ៤៥ ("ដោយសារអង្គបុរេជំនុំជម្រះពុំទទួលបានការសម្រេចស្តីពីការខ្វែងយោបល់គ្នានៅចំពោះមុខខ្លួន វិធាន ៧១(៤)(គ) នៃវិធានផ្ទៃក្នុងចែងថា ចំណាត់ការរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវយកទៅអនុវត្ត។ ក្នុងរឿងក្តីបច្ចុប្បន្ន នេះមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវតែ អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង បញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ")។

កិច្ចព្រមព្រៀង អ.វ.ត.ក. បានកំណត់ការប្រតិបត្តិការនៃគោលបំណងរបស់កិច្ចព្រមព្រៀង ដែរ ឬយ៉ាងណា។ អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បានលើកទឡ្ហីករណ៍ថា អង្គហេតុដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ត្រូវបានគ្របដណ្តប់រួចរាល់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយ។

15. បើទោះបីជាចៅក្រមទាំងអស់របស់អង្គបុរេជំនុំជម្រះបញ្ជាក់ថា ខ្លួននឹងសម្រេចលើការខ្វែងយោបល់នេះដោយផ្អែកតែលើសារណាបឋមដែលជាអំណះអំណាងលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានដាក់ចូលសំណុំរឿង ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងសារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[92] ដែលបានដាក់នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨[93] ប៉ុណ្ណោះ និងថា ពួកគាត់នឹងពុំអើពើលើអំណះអំណាងថ្មីរបស់សហព្រះរាជអាជ្ញាជាតិ អំពីកិច្ចស៊ើបសួរបឋមឯកតោភាគីដែលបានលើកឡើងក្នុងសារណាតបរបស់ខ្លួនតាមការបង្គាប់របស់អង្គបុរេជំនុំជម្រះ ដែលបានដាក់នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩[94] ប៉ុន្តែបញ្ហានេះច្បាស់ណាស់នៅតែជាក្តីកង្វល់របស់ពួកគាត់។ ចៅក្រមជាតិបានកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាថា និយ័តភាពនៃកិច្ចស៊ើបសួរបឋមអាចត្រូវបានជំទាស់ដោយផ្អែកតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងនៅមុខសហចៅក្រមស៊ើបអង្កេត[95]។

16. ផ្អែកតាមមតិរបស់ចៅក្រមជាតិ អំណះអំណាងដែលផ្ទុយគ្នាស្តីពី"បញ្ហាថ្មី" គឺជាចំណុចសំខាន់ចម្បង។ ចៅក្រមជាតិបានដោះស្រាយពេញលេញ និងលើកលម្អិតពីអំណះអំណាងរបស់សហព្រះរាជអាជ្ញាជាតិដែលថា គាត់ពុំបានចូលរួមក្នុងកិច្ចស៊ើបសួរបឋមរបស់សហសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីទទួលបានភស្តុតាងពាក់ព័ន្ធទៅនឹងជនសង្ស័យថ្មី ឬបានផ្តល់ប្រតិភូកម្មដល់បុគ្គលិករបស់ខ្លួនក្នុងការចូលរួមកិច្ច

[92] សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាជាតិអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុសម្រាប់ការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ឯកសារលេខ ៧ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាជាតិអន្តរជាតិ")។

[93] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) កថាខណ្ឌ ២៥។

[94] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ចុល និង ហួត វុទ្ធី កថាខណ្ឌ ១៤។ មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ៧។

[95] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ចុល និង ហួត វុទ្ធី កថាខណ្ឌ ១១, ១៣។ ពុំមែនមានចំណាត់បែបនេះត្រូវបានធ្វើឡើយ។

ស៊ើបសួរនោះឡើយ និងថា គាត់នៅតែពុំបានដឹងអំពីកិច្ចស៊ើបសួរនោះរហូតដល់ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨[96]។ ចៅក្រមជាតិបន្ទាប់មកបានរៀបរាប់ការជំទាស់លម្អិតដូចគ្នា ព្រមទាំងរួមបញ្ចូលការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីពីកិច្ចសហការរួមគ្នាពីមុនៗ ដែលមានការព្រមព្រៀងលើបញ្ជីឈ្មោះជនសង្ស័យជាសក្ដានុពល រួមទាំងជនសង្ស័យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងទីបី[97]។ សហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញជំហរថា នៅចុងខែ កញ្ញា ឆ្នាំ ២០០៦ បញ្ជីឈ្មោះពីររបស់ជនសង្ស័យត្រូវបានឯកភាព[98] និងថា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបឋមដែលបានធ្វើឡើងចាប់តាំងពី ខែ កក្កដា ឆ្នាំ ២០០៧ ដល់ខែ វិច្ឆិកា ឆ្នាំ ២០០៨ ក្រុមការងារជាតិ និងអន្តរជាតិនៃការិយាល័យសហព្រះរាជអាជ្ញាបានបន្តវិភាគលើភស្តុតាង[99]។

17. ការចងចាំផ្ទុយគ្នាគឺពុំត្រឹមត្រូវទាំងពីរ ហើយពុំមានដំណោះស្រាយរបស់តុលាការអាចផ្ដល់ ដោយគ្មានការស៊ើបអង្កេតបន្ថែមនៃសំណុំរឿង និងការដាក់កិច្ចឱ្យបំពេញនោះដែរ។ ដូចនេះ ត្រូវអនុវត្តគោលការណ៍នៃ*ការស្ដាប់ទាំងសងខាង*។ ទោះជាយ៉ាងណាក្ដី ដោយពុំបានស្ដាប់ ឬស្វែងរកភស្តុតាងបន្ថែម ចៅក្រមជាតិបានបង្កើតការយល់ឃើញផ្នែកអង្គហេតុដែលលម្អៀងទៅរកការបកស្រាយ ដោយសហព្រះរាជអាជ្ញាជាតិ។ សហចៅក្រមស៊ើបអង្កេតជាតិ និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់ដដែលរហូតមក និងបានយល់ឃើញថា៖

> កិច្ចស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិដោយពុំបានជូនដំណឹងមុនឬពិភាក្សាពាក់ព័ន្ធនឹងកិច្ចសហការជាមួយសហព្រះរាជអាជ្ញាជាតិ គឺជាការរំលោភបំពានលើច្បាប់បង្កើត អ.វ.ត.ក. កិច្ចព្រមព្រៀង

---

[96] សេចក្ដីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ផុល និង ហួត វុទ្ធី កថាខណ្ឌ ១-៤។

[97] សេចក្ដីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3), មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ផុល និង ហួត វុទ្ធី កថាខណ្ឌ ៥-១១។

[98] សេចក្ដីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ផុល និង ហួត វុទ្ធី កថាខណ្ឌ ៧។

[99] សេចក្ដីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ផុល និង ហួត វុទ្ធី កថាខណ្ឌ ១០។

និងវិធានផ្ទៃក្នុង។ ផលវិបាកនៃការរំលោភបំពាននោះអាចមានអត្ថិភាពក្នុងកិច្ចដំណើរការនីតិវិធីក្រោយៗទៀត ហើយពុំគប្បីត្រូវបានយកមកពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នាឡើយ[100]។

18. នៅក្នុងសំណៅផ្សេងនៃការយល់ឃើញផ្នែកអង្គហេតុដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានប្រើប្រាស់ចំណុចនេះជាសំអាងហេតុរបស់ខ្លួនសម្រាប់ការច្រានចោលនូវនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបន្ថែមចាប់តាំងពីឆ្នាំ ២០០៨។

19. ការយល់ឃើញដែលមានអនុភាពរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះនោះគឺថា៖

> គ្រប់អង្គហេតុ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងទីបីចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដែលត្រូវបានផ្តួចផ្តើមដោយសហព្រះរាជអាជ្ញាអន្តរជាតិ មានរួចស្រេចហើយក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយ។ [...] ផ្អែកលើការបកស្រាយខាងលើយើងយល់ឃើញថា ពុំមានហេតុផលណាមួយសម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងទីបី [...]។ [...] ដោយពិចារណាលើការយល់ឃើញនេះ យើងយល់ឃើញថា ជាការពុំចាំបាច់ដែលត្រូវផ្តល់សំអាងហេតុលើអំណះអំណាងដទៃទៀតដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ[101]។

20. គួរកត់សម្គល់ថា ពុំមានការយោងត្រូវបានធ្វើឡើងទៅលើតួនាទីនៃបុព្វកថា ឬបញ្ហាសន្តិសុខជាតិ ឬការផ្សះផ្សា។ ចៅក្រមអងន្តរជាតិ ក្នុងផ្នែកសំអាងហេតុរបស់ខ្លួន បានកត់សម្គាល់លើសំណៅផ្សេងៗនៃអង្គហេតុពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរបឋម[102] ប៉ុន្តែបានសង្កេតថា ផ្អែកលើការអះអាងបញ្ជាក់ផ្ទាល់របស់សហព្រះរាជអាជ្ញាជាតិ សហព្រះរាជអាជ្ញាជាតិប្រាកដជាបានដឹងអំពីបញ្ហានៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨ នៅពេលដែល សហព្រះរាជអាជ្ញាជាតិបានដាក់សារណាតបរបស់ខ្លួនទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលតាមការពិពណ៌នានៃព្រឹត្តិការណ៍ឃើញថា

---

[100] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ផុល និង ហួត វុទ្ធី កថាខណ្ឌ ១៩។ កំណត់សម្គាល់នោះទាយច្បាស់ថានឹងកើតឡើយ។ អនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋម ដើម្បីឱ្យបើកការស៊ើបសួរ ត្រូវបានលើកឡើងដដែលដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះរហូតមក។

[101] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ផុល និង ហួត វុទ្ធី កថាខណ្ឌ ៣០។

[102] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ៩។

សហព្រះរាជអាជ្ញាជាតិអាចបានដឹងមុនអំពីកិច្ចស៊ើបសួរបឋមនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ តាមរយៈកិច្ចប្រជុំមួយត្រូវបានធ្វើដើម្បីពិភាក្សាលើការដាក់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី និងទទួលបានសេចក្តីលម្អិតអំពីបញ្ហានៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលនៅពេលនោះអំណះអំណាងជាលាយលក្ខណ៍អក្សរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានជូនដំណឹង[103]។ ដោយសារការអះអាងទាំងនេះដែលពាក់ព័ន្ធទៅនឹងអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋម ត្រូវបានធ្វើឡើងយឺតពេលនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩ ទើបពុំអាចត្រូវបានចាត់ទុកថាជាផ្នែកនៃការខ្វែងយោបល់ដែលអង្គបុរេជំនុំជម្រះទទួលយកពិចារណា ដូចនេះ ការពិភាក្សាស្តីពីការដឹងរបស់សហព្រះរាជអាជ្ញាជាតិអំពីកិច្ចស៊ើបសួរបឋមនោះពុំចាំត្រូវធ្វើទៀតឡើយ[104]។

21. ចំពោះការខ្វែងយោបល់គ្នាជាចម្បងទាក់ទងនឹងដីកាសន្និដ្ឋាន ចៅក្រមអន្តរជាតិបានយល់ឃើញថាមានអង្គហេតុមួយចំនួនថ្មី និងមួយចំនួនត្រួតគ្នា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី និងបានកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មថ្មីជាក់លាក់ និងទីតាំងឧក្រិដ្ឋកម្ម[105]។ ចៅក្រមអន្តរជាតិបានពិនិត្យលើពាក្យពេចន៍ក្នុងវិធាន ៥៣(១) នៃវិធានផ្ទៃក្នុងដែលចែងថា "ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿជាក់ថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. បានកើតមានពិត សហព្រះរាជអាជ្ញា*ត្រូវ*បើកការ<u>ស៊ើបសួរ</u>" ហើយវិធាន ៥០(១) នៃវិធានផ្ទៃក្នុង ដែលបានប្រើប្រាស់ពាក្យពេចន៍ផ្ទុយគ្នាថា "សហព្រះរាជអាជ្ញា*អាច*ដឹកនាំ<u>ការស៊ើបសួរបឋម</u> ដើម្បីកំណត់ភស្តុតាង ដែលបង្ហាញពីការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក."[106]។ បន្ថែមលើនេះ ចៅក្រមបានសង្កេតឃើញថា ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយសហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលបានដាក់រួមគ្នាដោយសហព្រះរាជអាជ្ញា គោលជំហររបស់សហព្រះរាជអាជ្ញាជាតិ ពុំស៊ី

---

[103] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ៤។

[104] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និងDOWNING កថាខណ្ឌ ៤។

[105] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ១៨-២២។

[106] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ២៣។

សង្វាក់គ្នាជាមួយនឹងការអនុវត្តកន្លងមក ដែលបានអនុម័តរួមគ្នាដោយសហព្រះរាជអាជ្ញាទាំងពីរ ដោយច្បាប់បង្កើត អ.វ.ត.ក. និងវិធានផ្ទៃក្នុង[107]។

22. ចៅក្រមអន្តរជាតិបានអះអាងថាៈ

> ក្នុងរឿងក្តីបច្ចុប្បន្ន នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងចង់បើកកិច្ចស៊ើបសួរបឋម ក្នុងអង្គហេតុថ្មី និងត្រួតគ្នាជាមួយនឹងកិច្ចស៊ើបសួរដែលកំពុងបន្ត ដើម្បីគ្របដណ្តប់ពេញលេញលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់*ជនសង្ស័យថ្មី* ពុំមានបទបញ្ញត្តិណាមួយដែលរារាំងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនេះឡើយបើទោះបីជាអង្គហេតុមួយចំនួនដែលមានចំណុចខ្លះ កំពុងត្រូវបានស៊ើបអង្កេតនៅក្នុងរឿងក្តីមួយផ្សេងទៀតក៏ដោយ[108]។

23. ដោយហេតុថា អង្គបុរេជំនុំជម្រះពុំអាចរកសម្លេងមតិភាគច្រើនលើសលុបដែលតម្រូវបានក្នុងការសម្រេចពាក់ព័ន្ធទៅនឹងការខ្វែងយោបល់របស់សហព្រះរាជអាជ្ញាស្តីពីការដាក់ចូលសំណុំរឿងនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី យន្តការស្វ័យប្រវត្តិដែលលម្អៀងទៅរកការបន្តការចោទប្រកាន់ ត្រូវបានជម្រុញដោយអនុលោមតាមមាត្រា ២០ *ថ្មី* នៃច្បាប់បង្កើត អ.វ.ត.ក. និងវិធាន ៧១(៤)(គ) នៃវិធាផ្ទៃក្នុង។ ការសម្រេចនេះបានត្រួសត្រាយគន្លងផ្លូវនាពេលអនាគតសម្រាប់ អ.វ.ត.ក.។

24. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងបានបញ្ជូនសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេត ផ្អែកតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង[109]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់សេចក្តី

---

[107] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ១០-១៤។ នេះបានចោទជាសំណួរថា សហព្រះរាជអាជ្ញាជាតិអាចភាន់ច្រឡំថា ខ្លួន និងក្រុមរបស់ខ្លួនពុំបានដឹងអ្វីសោះអំពីការស៊ើបសួរលើជនសង្ស័យបន្ថែម ដែលជាកម្មវត្ថុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងទីបី។

[108] សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3) មតិរបស់ចៅក្រម LAHUIS និង DOWNING កថាខណ្ឌ ២៧ (សេចក្តីបញ្ជាក់បន្ថែម)។

[109] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ឯកសារលេខ D1/1 ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលមានការចោទប្រកាន់បន្ថែម[110]។ សហព្រះរាជអាជ្ញាជាតិពុំបានជាប់ពាក់ព័ន្ធនឹងដំណើរការនេះទេ។

25. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងអំពីសេចក្តីសន្និដ្ឋានដោយប្រកាសថា កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ត្រូវបានបញ្ចប់[111]។

26. នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលាឈប់[112] ហើយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានចេញដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញនៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១[113]។

27. ការខ្វែងយោបល់គ្នាជាសម្ងាត់របស់សហចៅក្រមស៊ើបអង្កេតក្នុងរឿងក្តីនេះត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ និង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៨[114]។

28. នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ BLUNK បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ជូនដំណឹងអំពីការលាឈប់របស់គាត់ និងបានកត់សម្គាល់ថា:

> បើទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានដាក់ខ្លួនគាត់ស្ថិតក្រោមឥទ្ធិពលនៃ[សេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា]ក៏ដោយ ក៏សមត្ថភាពរបស់គាត់ក្នុងការទប់ទល់នឹងសម្ពាធពីមន្ត្រីរដ្ឋាភិបាល និងការបំពេញតួនាទីដោយឯករាជ្យ អាចទទួលរងការមន្ទិលសង្ស័យ ហើយនេះអាចធ្វើឱ្យមានមន្ទិលសង្ស័យដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងមូលក្នុងសំណុំរឿង ០០៣ និង ០០៤។

---

110 ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៣ ឯកសារលេខ D120 ថ្ងៃទី ០៣១ ខែ តុលា ២០១៤។

111 សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ឯកសារលេខ D13 ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

112 *សូមមើល* សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-international-co-investigating-judge។

113 ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋម ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ ឯកសារលេខ D28។

114 ដីកាដំណោះស្រាយ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ ឯកសារលេខ D267 ("ដីកាបញ្ជូនទៅជំនុំជម្រះ (ឯកសារលេខ D267)") កថាខណ្ឌ ៥, ៧, ១៥, ២៧។

ដោយសារសេចក្តីថ្លែងការណ៍ផ្សេងៗទាំងនេះ ដែលត្រូវបានគេយល់ថា ជាការជ្រៀតជ្រែកដោយចេតនាពីមន្ត្រីរដ្ឋាភិបាលក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំដាក់លិខិតលាឈប់ [...][115]។

29. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានជូនដំណឹងដល់ ស៊ូ ម៉េត និង មាស មុត ថា ពួកគាត់គឺជាជនសង្ស័យក្នុងសំណុំរឿង ០០៣ និងថា ពួកគាត់មានសិទ្ធិទទួលបានមេធាវីតំណាងតាមការជ្រើសរើស និងសិទ្ធិចូលមើលសំណុំរឿង[116]។

30. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ KASPER-ANSERMET បានចេញសេចក្តីប្រកាសព័ត៌មានសាធារណៈ ជូនដំណឹងអំពីការលាឈប់របស់គាត់ និងបានបញ្ជាក់ថា៖

សិទ្ធិអំណាចរបស់ចៅក្រម Laurent Kasper-Andermet ក្នុងការស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ ត្រូវបានជំទាស់ជាដរាបដោយសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បើទោះបីជាមានមតិចេញដោយចៅក្រម Downing និង Chung នៃអង្គបុរេជំនុំជម្រះបញ្ជាក់នូវ[សិទ្ធិអំណាចក្នុងការអនុវត្តសមស្របក៏ដោយ]។

ការជំទាស់យ៉ាងសកម្មរបស់ចៅក្រម យូ ប៊ុនឡេង ទៅនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ បាននាំទៅរកស្ថានការណ៍ពុំអាចប្រតិបត្តិការតាមធម្មតាបាននៅ អ.វ.ត.ក.។ [...] បន្ថែមលើនេះ កិច្ចស៊ើបសួរផ្ទៃក្នុង ត្រូវបានបើកចំហរដោយចៅក្រម Laurent Kasper-Ansermet តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងសម្រាប់"ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ"។

---

[115] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ [Siegfried BLUNK]", ១០ ខែ តុលា ២០១១ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-international-co-investigating-judge។

[116] សេចក្តីជូនដំណឹងអំពីសិទ្ធរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] D30 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ (ពាក់ព័ន្ធទៅនឹង មាស មុត)។ សេចក្តីជូនដំណឹងអំពីសិទ្ធរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] D31 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ (ពាក់ព័ន្ធទៅនឹង ស៊ូ ម៉េត)។

ចៅក្រម Laurent Kasper-Ansermet ថ្មីៗនេះបានបើកកិច្ចប្រជុំក្រៅផ្លូវការជាមួយចៅក្រម យូ ប៊ុនឡេង ដែលក្នុងពេលនោះ ចៅក្រម យូ ប៊ុនឡេង បដិសេធពុំពិភាក្សាសំណុំរឿង ០០៣ និង ០០៤។ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ចៅក្រម យូ ប៊ុនឡេង បានចេញដីកាបង្គាប់ជាលាយលក្ខណ៍អក្សរទៅចៅក្រម Laurent Kasper-Ansermet ទាមទារឱ្យគាត់បញ្ឈប់ជាបន្ទាន់នូវ"សកម្មភាពខុសច្បាប់របស់គាត់"។ ឧសានវាទនេះ ត្រូវបានបញ្ជាក់ជាថ្មីម្តងទៀតកាលពីសប្តាហ៍មុន។

ផ្អែកតាមទស្សនៈនៃសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានកិច្ចស៊ើបអង្កេត ដែលត្រូវបានធ្វើឡើងដោយត្រឹមត្រូវ និងបើទោះបីជាមានការតាំងចិត្តដូច្នោះក៏ដោយ ក៏ចៅក្រម Laurent Kasper-Ansermet ពិចារណាថា កាលៈទេសៈបច្ចុប្បន្នលែងអនុញ្ញាតឱ្យគាត់បំពេញតួនាទីសមស្រប និងដោយសេរីឡើយ។ គាត់បានដាក់លិខិតលាឈប់ [...][117]។

31. កិច្ចស៊ើបសួរបានបន្ត។ នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីថា ស៊ូ ម៉េត បានទទួលមរណភាព[118]ហើយកិច្ចដំណើរការនីតិវិធីលើរូបគាត់ត្រូវបានបញ្ចប់នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥[119]។

32. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មាស មុត ត្រូវបានចេញដីកាកោះដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការបង្ហាញខ្លួនបឋមនៅ អ.វ.ត.ក. ដែលចុះកាលបរិច្ឆេទនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ

---

[117] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង [Laurent KASPER-ANSERMET]" ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge។

[118] សេចក្តីជូនដំណឹងអំពីមរណភាពរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៣ ឯកសារលេខ D86 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣។

[119] ដីកាលើកលែងចោទប្រកាន់លើ ស៊ូ ម៉េត ឯកសារលេខ D86/3 ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥។

២០១៤[120] ដែល មាស មុត បានជំទាស់ទៅនឹងសហចៅក្រមស៊ើបអង្កេត[121]។ នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានតម្កល់នីត្យានុកូលភាពនៃដីកាកោះនោះ[122]។

33. មាស មុត ពុំបានបង្ហាញខ្លួនតាមដីកាកោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលអនុវត្តតែម្នាក់ឯង បានចេញដីកាពីរបង្គាប់ឱ្យនាំខ្លួន មាស មុត នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤[123] និងថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ បន្ទាប់ពីគាត់ពុំបានអនុវត្តតាមដីកាកោះនោះ[124]។

34. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ មាស មុត *ដោយកំបាំងមុខ* ដោយសារការរំលោភបំពានលើមាត្រា ៥០០ (ការធ្វើទារុណកម្ម) មាត្រា ៥០១ និង ៥០៦ (អំពើមនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦") ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ [125] និងបានរៀបរាប់លម្អិតនៃបទចោទដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្ដីសម្រេច[126]។

35. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ មាស មុត បានបង្ហាញខ្លួនចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង ដែលបានចោទប្រកាន់គាត់ពីបទប្រល័យពូជសាសន៍ បទល្មើសបន្ថែមទៀតនៃ

---

[120] ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ឯកសារលេខ A66 ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[121] សេចក្ដីជូនដំណឹងអំពីការមិនទទួលស្គាល់ដីកាកោះ ឯកសារលេខ A67/1.1 ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ និងបានដាក់នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤។

[122] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើសុំរបស់ជនសង្ស័យពាក់ព័ន្ធទៅនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ឯកសារលេខ D117/1/1/2 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤។

[123] ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ និងដាក់ចូលសំណុំរឿង ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ C1។

[124] ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ និងដាក់ចូលសំណុំរឿង ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ C2។

[125] សេក្ដីសម្រេចចោទប្រកាន់ មាស មុត ដោយកំបាំងមុខ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ ឯកសារលេខ ឯកសារលេខ D128។

[126] ការជូនដំណឹងបទចោទប្រឆាំង មាស មុត ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្ដីសម្រេចចោទប្រកាន់ មាស មុត *កំបាំងមុខ* (ឯកសារលេខ ឯកសារលេខ D128) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ និងដាក់ចូលសំណុំរឿង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ ឯកសារលេខ ឯកសារលេខ D128.1។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[127]។

36. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំងនឹង មាស មុត[128]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចផ្អែកតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង កម្រិតវិសាលភាពនៃកិច្ចស៊ើបសួរដោយដកចេញនូវអង្គហេតុមួយចំនួនចេញ[129]។ នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងបញ្ចប់កិច្ចស៊ើបសួរលើកទីពីរ[130]។ សហព្រះរាជអាជ្ញាជាតិពុំបានជាប់ពាក់ព័ន្ធក្នុងចំណាត់ការ ឬដំណើរទាំងនេះ។ គោលការណ៍នៃការបន្តកិច្ចស៊ើបសួរ និងការចោទប្រកាន់ត្រូវបានគាំទ្រដោយយន្តការស្វ័យប្រវត្តិនៃក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.[131]។

37. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញាដើម្បីពិនិត្យ ដោយបានអញ្ជើញឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរផ្អែកតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង[132]។ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដោយស្នើសុំថា រាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង មាស មុត ត្រូវបដិសេធចោល ដោយសារគាត់ពុំស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[133]។ នៅថ្ងៃដដែលនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកា

---

[127] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ ឯកសារលេខ D174 ទំព័រ ២-៩។

[128] សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D225។

[129] ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D226។

[130] សេចក្តីជូនដំណឹងលើកទីពីរអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ D252។

[131] *សូមមើល* មាត្រា ២០ថ្មី ២៣ថ្មី នៃច្បាប់ អ.វ.ត.ក.។ វិធាន ៧១(៤)(គ) និង ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[132] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ D256។

[133] ដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធទៅនឹង មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារលេខ D256/6។

សន្និដ្ឋានស្ថាពរស្នើសុំឱ្យសម្រេចចោទប្រកាន់ មាស មុត និងបញ្ជូនទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាច្រើន ដែលបានចោទប្រកាន់[134]។

38. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីក្នុងសំណុំរឿង ០០៣ តាមរយៈ"ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធទៅនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣"ថា ដោយសារមានការខ្វែងយោបល់គ្នា សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ដីកាដំណោះស្រាយដែលខ្វែងយោបល់ និងដាច់ដោយឡែកពីគ្នានោះ ត្រូវបានអនុញ្ញាតផ្អែកតាមច្បាប់ជាធរមាន និងទំនងជាផលវិបាកសម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍ ផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[135]។ ពុំមានការឆ្លើយតប ត្រូវបានធ្វើឡើងដោយភាគី។ មួយឆ្នាំក្រោយមក នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា[136]។

39. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដីកាដំណោះស្រាយត្រូវបានដាក់ក្នុងពេលតែមួយជាមួយគ្នាៈ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបញ្ជូនទៅជំនុំជម្រះលើ មាស មុត[137] ខណៈពេលដែលសហចៅក្រមស៊ើបអង្កេតជាតិ ចេញដីកាលើកលែងការចោទប្រកាន់ប្រឆាំងនឹង មាស មុត[138]។

40. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៩ សហមេធាវីការពារក្តី មាស មុត ("សហមេធាវី")[139] និងសហព្រះរាជអាជ្ញាជាតិ[140]បានធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនទៅជំនុំជម្រះទៅអង្គបុរេជំនុំជម្រះ។

---

[134] ដីកាសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧, ឯកសារលេខ D256/7។

[135] ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធទៅនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D262 យោងទៅលើសេចក្តីសម្រេចលើសំណើរបស់ អោ អាន សុំការបំភ្លឺ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D262.1។ សេចក្តីសម្រេចស្តីពីសំណើបន្ទាន់របស់ អោ អាន សុំបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នា ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D262.2។ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងសំណុំរឿង ០០៤/២។

[136] ដីកាបញ្ជូនទៅជំនុំជម្រះ (ឯកសារលេខ D267) កថាខណ្ឌ ២៧។

[137] ដីកាបញ្ជូនទៅជំនុំជម្រះ (ឯកសារលេខ D267)។

[138] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ D266។

[139] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឯកសារលេខ D267/4 ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៩។

សហព្រះរាជអាជ្ញាអន្តរជាតិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់[141]។ បន្ទាប់ពីមានការអាននូវរបាយការណ៍ជាសាធារណៈនៃសំណុំរឿង និងបណ្តឹងឧទ្ធរណ៍[142] អំណះអំណាងផ្ទាល់មាត់ស្តីពីបណ្តឹង ឧទ្ធរណ៍ ត្រូវបានស្តាប់*ដោយសម្ងាត់* នៅថ្ងៃទី ២៧ ២៨ និង ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩[143]។ នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនស្តីពីបណ្តឹងឧទ្ធរណ៍នីមួយៗ ដោយបានអះអាងថា អង្គជំនុំជម្រះខ្វះសម្លេងមតិភាគច្រើនលើសលុបតម្រូវក្នុងការសម្រេចលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[144]។ ចៅក្រមទាំងប្រាំរូបបានពិចារណាថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺខុសច្បាប់[145]។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានយល់ឃើញថា ដីកាបញ្ជូនទៅជំនុំជម្រះ និងដីកា

---

[140] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ឯកសារលេខ D267/3 ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៩។

[141] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់លើ មាស មុត (D266) ឯកសារលេខ D266/2 ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៩។

[142] សំណុំរឿង ០០៣ របាយការណ៍នៃសំណុំរ និងបណ្តឹងឧទ្ធរណ៍ឯកសារលេខ D266/15 និង D267/20 ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩។

[143] សវនាការសាធារណៈបានរួមបញ្ចូលសេចក្តីផ្តើម និងការអានរបាយការណ៍សំណុំរឿងនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ព្រមទាំងសំណួររបស់ចៅក្រមសួរទៅភាគី នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩។ *សូមមើល* សំណុំរឿង ០០៣ ប្រតិចារឹកសវនាការបណ្តឹងឧទ្ធរណ៍ ឯកសារលេខ D266/16.1 និង D267/21.1 ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩ និងបានដាក់នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០ (CS)។ សំណុំរឿង ០០៣ ប្រតិចារឹកសវនាការបណ្តឹងឧទ្ធណ៍ក្នុងសំណុំរឿង ០០៣ ឯកសារលេខ D266/17.1 និង D267/22.1 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩ និងបានដាក់នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០ (CS)។ រឿងក្តី ០០៣ ប្រតិចារឹកសវនាការបណ្តឹងឧទ្ធរណ៍ឯកសារលេខ D266/18.1 និង D267/23.1 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ និងបានដាក់ នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០ (CS)។ សំណុំរឿង ០០៣ ប្រតិចារឹកសវនាការបណ្តឹងឧទ្ធរណ៍ឯកសារលេខ D266/18.2 និង D267/23.2 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ និង បានដាក់ នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០។

[144] សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D266/27 & D267/35 ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១(“សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ (D266/27 និង D267/35)”) ទំព័រ ៤០។

[145] សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ (D266/27 & D267/35) ទំព័រ ៤០។

លើកលែងចោទប្រកាន់ មានតម្លៃស្មើគ្នា និងមានសុពលភាព[146] ខណៈពេលចៅក្រមអន្តរជាតិបានតម្កល់ដីកាបញ្ជូនទៅជំនុំជម្រះ និងចាត់ទុកដីកាលើកលែងចោទប្រកាន់ជាមោឃៈ[147]។

41. សេចក្តីពិចារណាត្រូវបានជូនដំណឹងជាសាធារណៈនៅថ្ងៃដដែលនោះ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ ដែលធ្វើចំណាត់ការដោយផ្អែកលើមូលដ្ឋានថា ពុំមានសម្លេងភាគច្រើនលើសលុបដែលសម្រេចតម្កល់ដីកាលើកលែងចោទប្រកាន់ បានបន្តនីតិវិធីរួមជាមួយនឹងការរៀបចំដាក់ឯកសារនៅដំណាក់កាលមុនការជំនុំជម្រះ។ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ តាមការអនុវត្តកន្លងមក ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីតាមរយៈអ៊ីម៉ែលថា អង្គជំនុំជម្រះសាលាដំបូងនឹងពុំទទួលការទំនាក់ទំនងណាមួយពីភាគី ដោយសារអង្គជំនុំជម្រះពុំបានជូនដំណឹងអំពី*សេចក្តីពិចារណា* ឬបានទទួលសំណុំរឿងឡើយ[148]។

42. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង[149]។ សហចៅក្រមស៊ើបអង្កេតបដិសេធសំណើនេះនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១ ដោយបានអះអាងថា ខ្លួនពុំមានយុត្តាធិការពិចារណាលើសំណើនេះ ដោយសាររឿងក្តីនេះ កំពុងស្ថិតនៅមុខអង្គបុរេជំនុំជម្រះសម្រាប់បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសំណុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលតាមវិធាន ៨០(១) ទៅអង្គជំនុំជម្រះសាលាដំបូង[150]។ ទោះជាយ៉ាងណាក្តី សហចៅក្រមស៊ើបអង្កេតបានផ្តល់អនុសាសន៍ដល់ភាគីថា "ប្រសិន

---

[146] សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឯកសារលេខ (D266/27 & D267/35) មតិរបស់ចៅក្រម ប្រាក់ គីមសាន ន៉យ ថុល និង ហួត វុទ្ធី កថាខណ្ឌ ១១៥-១១៨។

[147] សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឯកសារលេខ (D266/27 & D267/35) មតិរបស់ចៅក្រម BEAUVALLET និង BAIK ទំព័រ ១៤៥។

[148] អ៊ីម៉ែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង លឹម ស៊ុយហុង "Re: សំណើសុំការពន្យារពេលដាក់បញ្ជីឈ្មោះសាក្សីតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង និងអ្នកជំនាញ" ឯកសារលេខ D271/1.1.41 ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១។

[149] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅសហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿងលេខ ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ D270 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២១។

[150] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ D270/7 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១ ("សេចក្តីលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ D270/7 កថាខណ្ឌ ៤០។

បើពុំមានមធ្យោបាយណាផ្សេងដើម្បីជម្រុញសំណុំរឿងនេះឱ្យទៅជំនុំជម្រះ ឬការបញ្ចប់ [...] [យើង] [...] នៅបើកឱកាសទទួលយក ឬធ្វើការស្នើសុំនូវការបំភ្លឺលើបញ្ហាថាតើ [យើង] មានយុត្តាធិការនៅសេសសល់ពិសេស ដែលជាមធ្យោបាយចុងក្រោយបំផុតក្នុងការបិទបញ្ចប់សំណុំរឿង”[151]។

43. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២១ សហមេធាវីការពារក្តី មាស មុត បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវសំណុំរឿង ០០៣[152]។ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឱ្យអង្គបុរេជំនុំជម្រះបញ្ចប់កិច្ចដំណើរការនីតិវិធីនៅដំណាក់កាលមុនការជំនុំជម្រះក្នុងសំណុំរឿង ០០៣ ដោយផ្អែកលើមូលដ្ឋាននៃការឯកភាពរួមគ្នាមួយអង្គបុរេជំនុំជម្រះ ដើម្បីបញ្ជូន មាស មុត ទៅអង្គជំនុំជម្រះសាលាដំបូង[153]។ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១ អង្គបុរេជំនុំជម្រះបានចាត់ទុកសំណើទាំងពីរនោះពុំអាចទទួលយកបាន[154]និងបានបញ្ជាក់តម្កល់សេចក្តីពិចារណារបស់ខ្លួនថា អង្គជំនុំជម្រះបានបំពេញកាតព្វកិច្ចរបស់ខ្លួនពេញលេញផ្អែកតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[155]។

44. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០២១ សហចៅក្រមស៊ើបអង្កេតជូនដំណឹងភាគីថា លើកលែងតែសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងដាក់សំណើនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យុត្តាធិការសេសសល់របស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ចប់សំណុំរឿង នៅមានអត្ថិភាព[156]។ នៅថ្ងៃដដែល

---

[151] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ(ឯកសារលេខ D270/7) កថាខណ្ឌ ៤២ *សូមមើលផងដែរ* កថាខណ្ឌ ៣៥ ដល់ ៣៧។

[152] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវសំណុំរឿង ០០៣ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២១ ត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២១ និងបានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ D272។

[153] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបញ្ចប់កិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៣ នៅដំណាក់កាលមុនការជំនុំជម្រះ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ D271/1។

[154] សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D271/5 និង D272/3 (“សេចក្តីសម្រេចរួម ឯកសារលេខ (D271/5 និង D272/3)”) កថាខណ្ឌ ៧៨ ផ្នែកសម្រេចសេចក្តី។

[155] សេចក្តីសម្រេចរួម ឯកសារលេខ (D271/5 និង D272/3) កថាខណ្ឌ ៦៤ ៦៨ ៧៦។

[156] ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D273 កថាខណ្ឌ ៥ ដល់ ៧។

នោះ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងសហចៅក្រមស៊ើបអង្កេតអំពីគោលបំណងរបស់ខ្លួនក្នុងការដាក់បណ្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូល[157]។ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១ សហចៅក្រមស៊ើបអង្កេតតាមរយៈអ៊ីម៉ែលបានជូនដំណឹងភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ ថា៖

> សហចៅក្រមស៊ើបអង្កេត (CIJs) ដោយស្របតាមទស្សនៈដែលបានលើកឡើងរបស់ខ្លួនស្តីពីយុត្តាធិការសេសសល់ដែលខ្លួនមាន ជូនដំណឹងភាគីនៃសំណុំរឿង ០០៣ និង ០០៤ ថា ខ្លួននឹងមិនបន្តសម្រេចទាក់ទងទៅនឹងបញ្ហាថាតើ ត្រូវបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវសំណុំរឿងនេះ រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូល (SCC) បានសម្រេចក្នុងកិច្ចដំណើរការនីតិវិធីនេះដែលបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះ។
>
> បន្ថែមលើនេះ ប្រសិនបើ SCC ពុំសម្រេចលើអង្គសេចក្តី ហើយសំណុំរឿងបង្វិលទៅ CIJs ការអះអាងថ្មីៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ICP) ក្នុងសំណុំរឿង ០០៤ ដែលបានចាត់ទុក CIJs មានភាពពលម្អៀងនោះ ហាក់បីដូចជាចង់បញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងដាក់បណ្តឹងជំទាស់ចៅក្រមតាមវិធាន ៣៤ នៅមុខអង្គបុរេជំនុំជម្រះក្នុងស្ថានការណ៍នោះ។ ក្នុងករណីចាំបាច់ ស្ថានការណ៍ដូចគ្នានេះនឹងអនុវត្តចំពោះសំណុំរឿង ០០៣[158]។

45. ដូចបានបញ្ជាក់លម្អិតខាងលើក្នុងប្រវត្តិនីតិវិធី រឿងក្តីនេះត្រូវបានតាមញាំញីដោយការខ្វែងយោបល់គ្នាចាប់តាំងពីដំបូងក្នុងឆ្នាំ ២០០៨។ រឿងក្តីនេះត្រូវបានធ្វើឱ្យជាប់គាំងដោយសារមតិផ្ទុយគ្នាពីរដែលបង្ហាញនូវស្នាមប្រេះស្រាំជ្រៅចំពោះការបកស្រាយអំពីគោលបំណងជាសារវ័ន្តរបស់ អ.វ.ត.ក.។ ខាងភាគីជាតិ រឿងក្តីនេះត្រូវបានយល់ថា ពុំស្របច្បាប់ចាប់តាំងដំបូង និងផ្ទុយពីប្រវត្តិនយោបាយ ដែលពុំស្របតាមការបកស្រាយនៃឯកសារមូលដ្ឋានបង្កើត អ.វ.ត.ក. ។ ខាងភាគីអន្តរជាតិ ច្បាប់បង្កើត អ.វ.ត.ក. និងកិច្ចព្រមព្រៀង អ.វ.ត.ក. ត្រូវបានបកស្រាយថា កិច្ចព្រមព្រៀងអន្តរជាតិដែលមានលក្ខណៈច្បាស់លាស់ ចងកាតព្វកិច្ចលើភាគីទាំងពីរ ដែលបញ្ហានយោបាយ ឬគោលនយោបាយ ពុំមែនជាផ្នែកនៃវិធានអន្តរជាតិស្តីពីការបកស្រាយឡើយ។ គប្បីអនុវត្តគោលការណ៍ *គោរពតាមកិច្ចព្រមព្រៀង* ដូច្នេះខាងភាគីអន្តរជាតិយល់ថា ការចោទប្រកាន់ប្រឆាំងនឹង មាស មុត ជារឿងត្រឹមត្រូវតាមច្បាប់សម្រាប់ការជំនុំជម្រះ។

---

[157] សារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតឱ្យប្រកាសថាតើ សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងដាក់ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែរ ឬយ៉ាងណា ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D273/1។

[158] សេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតដល់ភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១។

## III. ភាពអាចទទួលយកបានតាមទម្រង់

### ក. សារណា

46. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បណ្តឹងសាទុក្ខនេះអាចទទួលយកបានតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. មាត្រា ៣៣ ថ្មី និង ៣៧ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក. និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិដើម្បីការពារអត្ថប្រយោជន៍យុត្តិធម៌ និងរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[159]។

47. សហព្រះរាជអាជ្ញាអន្តរជាតិបានផ្អែកអំណះអំណាងរបស់ខ្លួនសម្រាប់ការចូលអន្តរាគមន៍ដោយអង្គជំនុំជម្រះតុលាការកំពូល លើមូលដ្ឋានមួយចំនួនថាៈ ការខកខានពីសំណាក់អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យភាពទាល់ច្រកផ្នែកនីតិវិធីចេះតែបន្តទៅមុខ និងមានហានិភ័យនៃព្យសនកម្មដែលពុំអាចស្រោចស្រង់បានដល់ការគ្រប់គ្រងយុត្តិធម៌ក្នុងសំណុំរឿង ០០៣[160]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ផ្អែកលើបទពិសោធន៍កន្លងមក ការខិតខំប្រឹងប្រែងបង្វិលរឿងក្តីទៅសហចៅក្រមស៊ើបអង្កេតស្វែងរកដំណោះស្រាយពីចៅក្រមដែលបានសម្រេចថា រឿងក្តីនេះត្រូវបដិសេធចោលនោះ គឺជាការយល់ខុស និងអាចបណ្តាលឱ្យមានព្យសនកម្មដែលពុំអាចស្រោចស្រង់បាន និងភាពមិនយុត្តិធម៌[161]។

48. មេធាវីការពារក្តី មាស មុត បានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា បណ្តឹងសាទុក្ខនេះពុំអាចទទួលយកបាន និងថា អង្គជំនុំជម្រះតុលាការកំពូលគួរបដិសេធចោលដោយពុំចាំបាច់ពិនិត្យលើរាល់អំណះអំណាងនោះទេ[162] ដោយសារៈ

(១) ការចេញដីកាដំណោះស្រាយពីផ្ទុយគ្នា គឺជាការខុសច្បាប់ និងថា សហព្រះរាជអាជ្ញាអន្តរជាតិពុំបានបង្ហាញហេតុផលដែលគួរឱ្យជឿជាក់ និងកំហុសក្នុងសំអាងហេតុ ការប្រែប្រួល

---

[159] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤២-៤៥។

[160] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៦-៤៨។

[161] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៨-៥០។

[162] សារណាតបរបស់ មាស មុត ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ឯកសារលេខ 3/1 ថ្ងៃទី ២៥ ខែ តុលា ២០២១ ("សារណាតបរបស់ មាស មុត") កថាខណ្ឌ ១ និង ១៨។

នៃកាលៈទេសៈដែលធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្សេងពីសេចក្តីសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០៤/២[163]។

(២) ដីកាដំណោះស្រាយនេះ មោឃៈ និងថា សហព្រះរាជអាជ្ញាអន្តរជាតិបានលើកកត្តាដែលពុំជាប់ពាក់ព័ន្ធសម្រាប់អង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណា ក្នុងសំណុំរឿង ០០៣[164]។

(៣) សហព្រះរាជអាជ្ញាអន្តរជាតិបានបកស្រាយពុំត្រឹមត្រូវនូវ*សេចក្តីពិចារណា*របស់ អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ ដោយបានអះអាងថា អង្គបុរេជំនុំជម្រះបានតម្កល់ដីកាបញ្ជូនទៅជំនុំជម្រះជាឯកច្ឆន្ទក្នុងសំណុំរឿង ០០៣[165]។

(៤) សំណុំរឿង ០០៣ ពុំអាចបន្តនីតិវិធីទៅជំនុំជម្រះដោយសារពុំមានដីកាបញ្ជូនទៅជំនុំជម្រះសុពលភាព[166]។

49. សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងអង្គជំនុំជម្រះតុលាការកំពូលថា ខ្លួនពុំមានបំណងដាក់សារណាតបទៅនឹងសារណារបស់ មាស មុត ឡើយ[167]។

## ខ. ការពិភាក្សា

## ១. ច្បាប់ជាធរមាន

50. មាត្រា ១ និង ២ *ថ្មី* ច្បាប់បង្កើត អ.វ.ត.ក. និងមាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. បានចែងថា គោលបំណងចម្បងរបស់តុលាការ *គឺដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត*ក្នុងអំឡុងពេលនៃចន្លោះចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

---

[163] សារណាតបរបស់ មាស មុត កថាខណ្ឌ ១-៥។

[164] សារណាតបរបស់ មាស មុត កថាខណ្ឌ ៦-១០។

[165] សារណាតបរបស់ មាស មុត កថាខណ្ឌ ១១-១៣។

[166] សារណាតបរបស់ មាស មុត កថាខណ្ឌ ១៤-១៧។

[167] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីបំណងរបស់ខ្លួនដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់ មាស មុត ឯកសារលេខ 3/1 ថ្ងៃទី ២៧ ខែ តុលា ២០២១ ឯកសារលេខ 3/1/1។

51. មាត្រា ៩ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះតុលាការកំពូលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផង និងសម្រេចសេចក្ដីចុងក្រោយផង។

52. ពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា វិធាន ៧១ នៃវិធានផ្ទៃក្នុងចែងអំពីនីតិវិធីដំណោះស្រាយដូចខាងក្រោម៖

វិធាន ៧១. ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា

១. ក្នុងករណីមានការខ្វែងយោបល់គ្នា សហព្រះរាជអាជ្ញាណាមួយ ឬទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ហើយត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហព្រះរាជអាជ្ញាណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈការបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល។ ការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅឲ្យចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅឲ្យសហព្រះរាជអាជ្ញាម្ខាងទៀត ...។ ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងឡើយ លើកលែងតែក្នុងរឿងក្ដីនោះ [ការខ្វែងយោបល់នោះ ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចដែលភាគីនៃកិច្ចដំណើរការនីតិវិធីមានសិទ្ធិប្ដឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតាមវិធាននេះ]។ ក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅឲ្យអង្គបុរេជំនុំជម្រះភ្លាម ។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហព្រះរាជអាជ្ញាត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា ។ កិច្ច ឬសេចក្ដីសម្រេច ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ត្រូវតែយកទៅអនុវត្ត លើកលែងតែបញ្ហានៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ខ-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋថ្មី

គ-ដីកាសន្និដ្ឋានស្ថាពរ ឬ

ឃ-សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការប្តឹងឧទ្ធរណ៍

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅនឹងការខ្វែងគំនិតគ្នាត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានសម្រេចឡើង ឬ រយៈពេល ៣០ (សាមសិប)ថ្ងៃ ត្រូវបានកន្លងផុត ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ

4. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ ដូចខាងក្រោម ៖

[...]

គ-សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរកបានសម្លេងគាំទ្រភាគច្រើនតាមការតម្រូវទេ ដោយអនុលោមតាមមាត្រា ២០ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រភាគច្រើនមានន័យថាកិច្ច ឬសេចក្តីសម្រេចដែលបានធ្វើដោយសហព្រះរាជអាជ្ញាណាម្នាក់ត្រូវមានសុពលភាព ឬមានន័យថាកិច្ច ឬ សេចក្តីសម្រេច ដែលបម្រុងនឹងធ្វើដោយសហព្រះរាជអាជ្ញាម្នាក់ត្រូវតែយកមកអនុវត្ត [...]។

53. មាត្រា ២០ *ថ្មី* នៃច្បាប់បង្កើត អ.វ.ត.ក. ចែងថា "ប្រសិនបើ ពុំមានមតិភាគច្រើនដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត"។

54. ទាក់ទងទៅនឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត វិធាន ៧២ នៃវិធានផ្ទៃក្នុងបញ្ញាក់នីតិវិធីដោះស្រាយដូចខាងក្រោម៖

វិធាន ៧២. ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត

១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើប

អង្គេតណាម្នាក់ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត។ [...] ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែ[ការខ្វែងយោបល់នោះ ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចដែលភាគីនៃកិច្ចដំណើរការនីតិវិធី មានសិទ្ធិប្ដឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតាមវិធាននេះ]។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងចតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម ។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬ សេចក្ដីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ត្រូវតែអនុវត្តលើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក-សេចក្ដីសម្រេចណាមួយដែលអាចនាំឲ្យជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើបណ្ដឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ។

ខ-ការជូនដំណឹងអំពីបទចោទប្រកាន់ ។ ឬ

គ-ដីកាបង្គាប់ឲ្យចាប់ខ្លួន ។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬរយៈពេល៣០(សាម

សិប)ថ្ងៃបានកន្លងហួស ឬអង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ ។

4. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម ៖

[...]

ឃ-សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍ ។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសម្លេងគាំទ្រភាគច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រមានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ត្រូវមានសុពលភាព ឬមានន័យថា ដីកា ឬ កិច្ចស៊ើបសួរ ដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត ។ [...]

55. មាត្រា ២៣ *ថ្មី* នៃច្បាប់បង្កើត អ.វ.ត.ក. ចែងថា “ប្រសិនបើពុំមានមតិភាគច្រើនដូចដែលត្រូវឱ្យមានចំពោះសេចក្តីសម្រេចការស៊ើបអង្កេតត្រូវធ្វើបន្តទៀត”។

56. វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងក្នុងផ្នែកពាក់ព័ន្ធ ចែងថា៖

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា ។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖

[...]

ខ) ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ។

57. ផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បិទផ្លូវតវ៉ា។

58. វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។

59. យោងតាមវិធាន ៦៩ នៃវិធានផ្ទៃក្នុងក្រោយពីការជូនដំណឹងនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដោយអនុលោមតាមវិធាន ៧៧(១៣) និង (១៤) ក្រឡាបញ្ជីនៃការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងដោយផ្អែកតាមវិធាន ៦៩(២)(ក) នៃវិធានផ្ទៃក្នុង។

60. ទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែងថា៖

> អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តីឬ សេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម ៖

ក. កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈ សាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ។ ឬ

ខ. កំហុសនៃអង្គហេតុ ដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។

បន្ថែមពីនេះ បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងទៅនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ ។

ក្នុងគោលបំណងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ ។

## ២. យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល

61. នៅពេលចាត់ទុកថា ជាបណ្តឹងសាទុក្ខ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិជាក់ស្តែងពុំបានសំដៅលើសេចក្តីសម្រេច ឬសំអាងហេតុរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ ឬ ០០៤ ប៉ុន្តែទៅលើការខកខានក្នុងការបញ្ជូនរឿងក្តី ០០៣ និង ០០៤ ទៅជំនុំជម្រះ*ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.*។ ពុំមានបញ្ហាលើយុត្តាធិការត្រូវបានលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហាថាតើ បណ្តឹងសាទុក្ខនេះប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែរ ឬយ៉ាងណានោះទេ។ សំណើនេះជាមូលដ្ឋានគឺជាការស្នើសុំបំភ្លឺៈ ថាតើការដែលថា ចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះបានលើកឡើងថា ដីកាបញ្ជូនទៅជំនុំជម្រះមានសុពលភាពនោះ មានន័យថា រឿងក្តី ០០៣ ត្រូវតែបញ្ជូនទៅជំនុំជម្រះពិតមែនឬទេ? ប្រសិនបើការបកស្រាយដែលសហព្រះរាជអាជ្ញាអន្តរជាតិបានផ្តោតទៅលើ<u>ផលវិបាក</u>នៃសំអាងហេតុ និងផ្នែកសម្រេចសេចក្តីនៃការកំណត់នូវដីកាដំណោះស្រាយពីរផ្ទុយគ្នា បានជោគជ័យ ដីកាបញ្ជូនទៅជំនុំជម្រះចាត់ទុកជាបានការ ហើយការជំនុំជម្រះគប្បីបន្តកើតមាន។ ប្រសិនបើគាត់ពុំទទួលជោគជ័យក្នុងការបង្ហាញនេះ អំណះអំណាងនេះពុំបានសម្រេច ហើយរឿងក្តីគប្បីត្រូវបញ្ចប់។ ទោះក្នុងករណីណាមួយក៏ដោយ ភាគីមានបំណងឱ្យអង្គជំនុំជម្រះតុលាការកំពូលផ្តល់ការបំភ្លឺ និងការបញ្ជាក់ចុងក្រោយ។ នៅពេលផ្តល់ការបំភ្លឺ និងការបញ្ជាក់ចុងក្រោយនេះ មតិជំទាស់នេះជ្រើសរើសយកវិធីសាស្ត្រផ្សេងពីជម្រើសទាំងនោះ និងផ្សេងពីសិទ្ធិអំណាចដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូល។

62. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានទទួល និងបន្ទាប់មកបានផ្តល់ការបញ្ជាក់ចុងក្រោយប្រហាក់ប្រហែលគ្នានេះក្នុងសំណើមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងរឿងក្តី ០០៤/២ ពាក់ព័ន្ធនឹងជនត្រូវចោទ អោ អាន[168]។

---

[168] សំណុំរឿង០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក./អ.ជ.ស.ជ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងនូវអានុភាពនៃសំណុំរឿង ០០៤/២ ឯកសារលេខ E004/2/1/1/2 ថ្ងៃទី ១០ ខែ សីហា ២០២០ ("សេចក្តីសម្រេចសំណុំរឿង ០០៤/២ លើបណ្តឹងសាទុក្ខភ្លាមៗ (E004/2/1/1/2)" )។

01683066



63. រឿងក្តីពីរនេះមានលក្ខណៈខុសគ្នា។ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងរឿងក្តី ០០៤/២[169] ពុំបានផ្អែកលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០៤/២ ប៉ុន្តែប្រឆាំងទៅនឹងសេចក្តីថ្លែងការណ៍រួមជាសាធារណៈដែលចេញដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០ ដែលកត់សម្គាល់ថា "ការចេញសេចក្តីសម្រេចផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង ពុំអាចធ្វើទៅបានឡើយ" ដោយសារការខ្វែងយោបល់គ្នារវាងសហចៅក្រមជាតិ និងអន្តរជាតិលើការទទួលយកសំណុំរឿង និងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០៤/២[170]។ ចៅក្រមជាតិបានបញ្ជាក់ថា ពុំមានការជំនុំជម្រះលើ អោ អាន ក្នុងពេលបច្ចុប្បន្ន ឬក្នុងពេលអនាគត[171]។

64. សហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងទៅលើការយល់ឃើញក្នុងករណីនោះ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនស្តីពីយុត្តាធិការជាឆន្ទានុសិទ្ធិ និងជាពិសេសនៅពេលដែលអង្គជំនុំជម្រះនេះបានបញ្ជាក់ថា កាលៈទេសៈពិសេសនៃសំណុំរឿង *០០៤/២ តម្រូវថា សហព្រះរាជអាជ្ញាអន្តរជាតិ អោ អាន ដើមបណ្តឹងរដ្ឋប្បវេណី និង សាធារណជន មានសិទ្ធិទទួលបានការរំពឹងទុក និងទទួលបានភាពប្រាកដប្រជា និងច្បាស់លាស់ក្នុងរឿងក្តីនេះ* និងថា *ការទុកឱ្យស្ថិតក្នុងភាពមិនច្បាស់លាស់តាមផ្លូវតុលាការបានបំពានជាមូលដ្ឋាននូវក្តីរំពឹងត្រឹមត្រូវតាមច្បាប់ទាំងនោះ*[172]។ ដូច្នេះ អង្គជំនុំជម្រះបានកំណត់ថា ក្នុងនាមជាអង្គជំនុំជម្រះចុងក្រោយនៃ អ.វ.ត.ក. អង្គជំនុំជម្រះមានយុត្តាធិការជាឆន្ទានុសិទ្ធិក្នុងការទទួលសំណើ ដោយសារអង្គជំនុំជម្រះមានកាតព្វកិច្ចផ្តល់ការបំភ្លឺ និងការបញ្ជាក់ចុងក្រោយចំពោះស្ថានការណ៍នោះ និងបានកត់សម្គាល់ថា *ការជាប់គាំងផ្នែកច្បាប់ សឱ្យឃើញពីភាពបរាជ័យនៃប្រព័ន្ធតុលាការ*[173]។ អង្គជំនុំជម្រះនេះបានកំណត់ថា រឿងក្តីនេះពុំគួរដាក់ឱ្យស្ថិតក្នុងភាពមិនច្បាស់ផ្នែកច្បាប់ ដែលពុំអាចបន្តទៅការជំនុំជម្រះ ឬត្រូវបដិសេធ

---

[169] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក./អ.ជ.ស.ដ/អ.ជ.ត.ក បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងនូវអានុភាពសំណុំរឿង ០០៤/២ ឯកសារលេខ E004/2/1 ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ ("បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង ០០៤/២ (E004/2/1)")។

[170] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ទាក់ទងទៅនឹងសំណុំរឿង ០០៤/២ ដែលពាក់ព័ន្ធនឹង អោ អាន" ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao ។

[171] សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. "សេចក្តីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ទាក់ទងទៅនឹងសំណុំរឿង ០០៤/២ ដែលពាក់ព័ន្ធនឹង អោ អាន" ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao។

[172] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ លើបណ្តឹងសាទុក្ខភ្លាមៗ (E004/2/1/1/2) កថាខណ្ឌ ៦០។

[173] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ លើបណ្តឹងសាទុក្ខភ្លាមៗ (E004/2/1/1/2) កថាខណ្ឌ ៦៤។

ចោល ឬរក្សាទុកក្នុងបណ្ណាសារ។ អង្គជំនុំជម្រះបានកំណត់ផងដែរថា យើងអង្គជំនុំជម្រះតុលាការកំពូលមានកាតព្វកិច្ច និងករណីយកិច្ចផ្តល់សេចក្តីបំភ្លឺ និងការបញ្ជាក់ចុងក្រោយនៅក្នុងវិវាទដែលពុំទាន់បានដោះស្រាយ លើផ្នែកអង្គច្បាប់ ឬអង្គហេតុ។

65. ដោយបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់យើងរួចហើយក្នុងរឿងក្តី ០០៤/២ យើងគប្បីបន្តធ្វើដូច្នោះទៀតក្នុងរឿងក្តីនេះសម្រាប់ហេតុផលមួយចំនួន ជាសំខាន់ផងនោះ គឺការពន្យល់ដល់ជនរងគ្រោះ ដែលបានដាក់បណ្តឹងទាមទាររបស់ខ្លួន បានផ្តល់កំណត់ហេតុស្តាប់ចម្លើយនៅមុខចៅក្រមស៊ើបអង្កេត និងបានត្រៀមលក្ខណៈផ្តល់សក្ខីកម្មផ្ទាល់ក្នុងតុលាការ និងដល់សហគមន៍អន្តរជាតិដែលបានសង្កេតកិច្ចដំណើរការនីតិវិធីទាំងនេះដោយយកចិត្តទុកដាក់ ដើម្បីអាចទុកធ្វើជារូបមន្តមួយសម្រាប់វិវាទផ្ទៃក្នុងនាពេលអនាគត នៅពេលដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាមដែលគួរឱ្យភ័យតក់ស្លុត និងក្នុងទ្រង់ទ្រាយធំដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទីពីរ គួររំឭកថា អាណត្តិរបស់តុលាការគឺផ្តល់យុត្តិធម៌ និងអនុវត្តគោលការណ៍នីតិរដ្ឋ ដែលមានន័យថា ដោយឥតលម្អៀងវិជ្ជមាន ឬអវិជ្ជមានទៅរកភាគីណាមួយ និងដោយគ្មានការភ័យខ្លាចអំពីផលវិបាកចេញពីប្រភពខាងក្រៅណាមួយឡើយ។ ដោយសារជាផ្នែកមួយនៃការផ្តល់យុត្តិធម៌ តុលាការជាន់ខ្ពស់នៅគ្រប់រដ្ឋ សុទ្ធតែអាចផ្តល់សំណងបាន នៅពេលមានការខកខានរបស់តុលាការជាន់ទាបជាងក្នុងការអនុវត្តច្បាប់ ការអនុវត្តន៍ច្បាប់ពុំបានត្រឹមត្រូវ ការបំភ្លៃអង្គហេតុ និងសេចក្តីសម្រេចត្រូវបានធ្វើឡើងតាមអំពើចិត្ត ដូចជាពុំបានផ្តល់សំអាងហេតុ ឬសម្រាប់មូលដ្ឋានទៀត ដែលបានបង្ហាញថា មានកំហុសអង្គច្បាប់។ ប្រព័ន្ធគតិយុត្តិទាំងអស់ដែលប្រតិបត្តិក្នុងលទ្ធិប្រជាធិបតេយ្យ ត្រូវផ្តល់យុត្តិធម៌ផ្នែកច្បាប់ បើទោះបីជាតាមរយៈបណ្តឹងសើរើ ឬបណ្តឹងសាទុក្ខ នៅពេលដែលកង្វះយុត្តាធិកា ឬការប្រើប្រាស់ហួសដែនយុត្តាធិការក្នុងចំណាត់ការរបស់ចៅក្រមនៃតុលាការជាន់ទាបត្រូវបានកំណត់អត្តសញ្ញាណនោះ[174]។ សំណងទាំងនោះអនុវត្តស្មើគ្នាទៅនឹងសេចក្តីសម្រេចរដ្ឋបាល ដែលស្ថិតនៅក្រៅប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ និងមានអត្ថិភាពក្នុងការធានាថា ច្បាប់អនុវត្តលើបុគ្គលគ្រប់រូបដោយពុំគិតពីឋានៈ និងថា សេចក្តីសម្រេចដែលពុំមានតុលាការសមស្របណាមួយអាចធ្វើទៅបាននោះ នឹងត្រូវបដិសេធចោល។ ជាការសមស្របយ៉ាងពិសេសដែលថា មានតុលាការចុងក្រោយឯករាជ្យពីឥទ្ធិពលខាងក្រៅដែលតុលាការនេះអាចពិនិត្យលើចំណាត់ការតុលាការជាន់ទាប ដែលពុំអនុញ្ញាតសិទ្ធិតាមបទបញ្ញត្តិ

---

[174] សម្រាប់តួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូលជា“អង្គជំនុំជម្រះឧទ្ធរណ៍ និងចុងក្រោយ” *សូមមើល* សាលដីកាសំណុំរឿង ០០១ ឯកសារលេខ F28 ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៣ និង ២៨-៣១។ សាលដីកាសំណុំរឿង ០០២/០១ ឯកសារលេខ F36 ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ១៩៩។

ឬផ្នែកនីតិវិធីធ្វើបណ្តឹងសាទុក្ខបាន។ ក្នុងកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានផ្តល់សំណងបែបនេះ ក្នុងមាត្រា ៤១៩។ ក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ដីកាបង្គាប់*ឱ្យតុលាការជាន់ទាបផ្តល់កំណត់ត្រាសម្រាប់ការពិនិត្យ* មានអត្ថិភាពបដិសេធសេចក្តីសម្រេចរបស់តុលាករជាន់ទាប ដែលបានធ្វើឡើងដោយប្រើប្រាស់ហួសពីដែនកំណត់នៃយុត្តាធិការរបស់ខ្លួន ការកង្វះយុត្តាធិការ ឬការរំលោភកិច្ចដំណើរការនីតិវិធី។ សំណងទាំងនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាស្ទើរតែទាំងស្រុងទៅនឹងសំណងដែលមានចែងក្នុងមាត្រា ៤១៩ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

66. ក្នុងរឿងក្តីនេះ គួរឱ្យសោកស្តាយ បើទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិយល់ត្រឹមត្រូវក្នុងអំណះអំណាងរបស់ខ្លួន ថា បើពុំមានការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល ភាពទាល់ច្រកនៅតែបន្តយ៉ាងណាក៏ដោយ[175]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ខ្លួនពុំអាចធ្វើអ្វីលើសពីនេះបាន និងបានបញ្ជាក់ថា ខ្លួនពុំមានតួនាទីបន្ថែមទៀតទេ[176]។

67. គួររំឭកថា អង្គជំនុំជម្រះទាំងមូលបានសម្រេចជាឯកច្ឆន្ទថា ការចេញដីកាដំណោះស្រាយជាពីររបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ រំលោភបំពានក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.[177]។ ទោះជាយ៉ាងណាក្តី ចៅក្រមទាំងអស់បានបន្តពិចារណាលើសុពលភាពនៃដីកាដែលរងការជំទាស់នោះដូចតទៅ៖ ចៅក្រមជាតិ និងចៅក្រមអន្តរជាតិបានខ្វែងយោបល់គ្នា។ ដោយមានលក្ខណៈពុំស៊ីសង្វាក់គ្នា និងពុំស្របគ្នាក្នុងផ្នែកខ្លះ ចៅក្រមជាតិបានយល់ស្របលើសុពលភាពនៃដីកាលើកលែងចោទប្រកាន់ និងដីកាបញ្ជូនទៅជំនុំជម្រះ ខណៈពេលចៅក្រមអន្តរជាតិបានតម្កល់ដីកាបញ្ជូនទៅជំនុំជម្រះ និងបដិសេធដីកាលើកលែងចោទប្រកាន់[178]។ សេចក្តីសម្រេចមានលក្ខណៈទីទើរ និងពុំសមស្របនេះគប្បីត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះតុលាការកំពូល។

---

[175] សណើររបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥១។

[176] សេចក្តីសម្រេចរួម (D271/5 និង D272/3) កថាខណ្ឌ ៦៩-៧៨។

[177] សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) ទំព័រ ៤០។

[178] *សូមមើល* សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) មតិរបស់ចៅក្រម ប្រាក់ គឹម សាន ន័យ ធុល និង ហួត វុទ្ធី កថាខណ្ឌ ១១៥ ១១៨ ("ដីកាដំណោះស្រាយពីរមានតម្លៃស្មើគ្នា និងមានសុពលភាព")។ សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) មតិរបស់ចៅក្រម BEAUVALLET និង BAIK ទំព័រ ១៤៥ ("យល់ឃើញថា ដីកាលើកលែងចោទប្រកាន់ មោឃៈទាំងស្រុង តម្កល់ដីកាបញ្ជូនទៅជំនុំជម្រះ")។

68. មានទិដ្ឋភាពផ្សេងគ្នាសម្រាប់សេចក្តីពិចារណានេះ។ ការវិភាគលម្អិតអំពីដីកាដំណោះស្រាយដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានធ្វើឡើងដោយប្រុងប្រយ័ត្ន និងរ៉ាយរ៉ាប់ពន្យល់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងតួនាទីផ្សេងៗរបស់ មាស មុត ក្នុងនាមជាមេបញ្ជាការយោធាក្នុងតួនាទីជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈផ្ទុយទៅនឹងដីកាលើកលែងចោទប្រកាន់ដែលខ្លី និងជាល្បះឃ្លានៃភស្តុតាងជារួមបង្ហាញដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះផ្អែកលើមូលដ្ឋានថា មាស មុត ពុំមែនជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរ។ គួររំឭកថា ការស៊ើបអង្កេតដែលបានធ្វើចំណាត់ការដោយសហព្រះរាជអាជ្ញាម្នាក់ និងសហចៅក្រមអន្តរជាតិបីរូប ដែលធ្វើចំណាត់ការម្នាក់ៗឯង បានចាប់ផ្តើមដំណើរការមុន ដោយផ្អែកលើហេតុផលគួរជឿជាក់បាន និងលើតុល្យភាពនៃមូលដ្ឋានភវនីយភាព បានរកឃើញថា មាស មុត គឺជាបុគ្គលមានសិទ្ធិអំណាច និងជិតស្និទ្ធជាមួយ តា ម៉ុក និងកាន់តួនាទីជាមេបញ្ជាការកងពលលេខ ១៦៤ ក្នុងឆ្នាំ ១៩៧៥[179] ជាសមាជិករបស់អគ្គសេនាធិការ[180] ជាជំនួយការក្នុងឆ្នាំ ១៩៧៥ និងសមាជិកបម្រុងនៃគណៈមជ្ឈិមនៅចុងឆ្នាំ ១៩៧៨ ដែលត្រូវបានគេយល់ថា ជាអ្នកតំណាងឱ្យគណៈមជ្ឈិមក្នុងអំឡុងពេលនៃបេសកកម្មមួយចំនួនក្រៅតំបន់ស្វយ័តកំពង់សោម[181] លេ

[179] កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុនណា (ឯកសារលេខ D114/65) លេខ ERN (ភាសាអង់គ្លេស) ០១១៨០៨៥១ (A6, A9)។ កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ុន ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D2/8 លេខ ERN (ភាសាអង់គ្លេស) ០០៦១៣០១១ (A27) ០០៦១៣០១២ (A32)។

[180] *សូមមើល ឧ.* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការវិភាគ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារលេខ D234/2.1.52 លេខ ERN (ភាសាអង់គ្លេស) ០០១៤២៨៥២។ លុន សេង ឯកសារលេខ D54/110 លេខ ERN (ភាសាអង់គ្លេស) ០១៣៣១៦៤៣ (A10)។ កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុច (ឯកសារលេខ D114/158) លេខ ERN (ភាសាអង់គ្លេស) ០១២១៣៤១៣ (A24)។ កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុច (ឯកសារលេខ D114/159) លេខ ERN (ភាសាអង់គ្លេស) ០១២១៣៤២៣ (A23)។ ប្រតិចារឹកសំណុំរឿង ០០២ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេចអ៊ាវ *ហៅ* ឌុច) ឯកសារលេខ D53/2.1.42 លេខ ERN (ភាសាអង់គ្លេស) ០០៧៩៩៩០៤ កថាខណ្ឌ ៨-១៣។ នៅពេល ឌុច បានបញ្ជាក់ក្នុងចម្លើយរបស់គាត់មួយថា មាស មុត គឺជាសមាជិកអគ្គសេនាធិការ។ សាក្សីភាគច្រើនដទៃទៀត អះអាងថា មាស មុត គឺជាសមាជិកនៃគណៈនោះ។

[181] កំណត់ហេតុស្តាប់ចម្លើយ ឈាង ជួ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ D114/52 ("កំណត់ហេតុស្តាប់ចម្លើយ ឈាង ជួ (ឯកសារលេខ D114/52)") លេខ ERN (ភាសាអង់គ្លេស) ០១០៧៦៧៥០ (A40) ០១០៧៦៧៥៣ (A54)។ កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ឿន ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ D4.1.810 លេខ ERN (ភាសាអង់គ្លេស) ០០៤១២១៨០ (A26, A27)។

ខាតំបន់ស្វយ័តកំពង់សោម[182] និងចុងក្រោយជាអនុលេខារបស់ សុន សេន ដែលជាមេបញ្ជាការកងបដិវត្តន៍កម្ពុជា។ ការច្រានចោលការរកឃើញទាំងនេះ តម្រូវឱ្យមានទឡ្ហីករណ៍ជំទាស់ដែលបានផ្អែកលើអង្គហេតុ។ ជាការកត់សម្គាល់ថា បើទោះបីជាមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតលើបញ្ហាថាតើ មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែរ ឬយ៉ាងណាក៏ដោយ ក៏មានការជំទាស់តិចតួចក្នុងចំណោមចៅក្រមទៅលើបញ្ហាថាតើ ឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើងដែរ ឬយ៉ាងណា។

69. នៅពេលដែលអង្គបុរេជំនុំជម្រះបានស្តីបន្ទោសចំៗទៅលើសហចៅក្រមស៊ើបអង្កេត ដោយសារអសមត្ថភាពក្នុងការផ្តល់ដីកាដំណោះស្រាយរួមមួយ អង្គជំនុំជម្រះពុំបានគិតពីការពិតថា ខ្លួនឯងក៏មានការខ្វែងយោបល់ដូចគ្នាដែរ។

70. អង្គបុរេជំនុំជម្រះ ក្នុងផ្នែកសម្រេចសេចក្តីនៃ*សេចក្តីពិចារណា*៖

- **បង្គាប់**ឱ្យដាក់បញ្ចូលគ្នានូវនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ
- **សម្រេច**ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ អាចទទួលយកបាន
- **សម្រេច**ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ អាចទទួលយកបាន
- **សម្រេច**ថា បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី មាស មុត មិនអាចទទួលយកបាន
- **ប្រកាស**ថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ រំលោភបំពានលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.

[182] កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ D114/95 លេខ ERN (ភាសាអង់គ្លេស) ០១១៣៧២១០ (A195, A196, A197, A198, A199)។ កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ សាន កន ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៧ D54/106.2 លេខ ERN (ភាសាអង់គ្លេស) ០១៥០៩១៨៧។ កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ D114/96 លេខ ERN (ភាសាអង់គ្លេស) ០១១៤២៦១៩ (A10-11)។ កិច្ចសម្ភាសន៍របស់សហព្រះរាជអាជ្ញាជាមួយ សៀង ថ្ងៃទី ១២ ខែ សីហា ២០០៨ ឯកសារលេខ D1.3.13.11 លេខ ERN (ភាសាអង់គ្លេស) ០០២១៧៥៦៤។

- **ប្រកាស**ថា អង្គជំនុំជម្រះពុំអាចរកសម្លេងគាំទ្រយ៉ាងតិចពីរពីចៅក្រមបួនរូប ដើម្បីចេញសេចក្តីសម្រេចដែលមានសំអាងហេតុរួមបានមួយទៅលើអង្គសេចក្តី ឡើយ[183]។

71. ការពិនិត្យលើសំអាងហេតុដែលជាកាតព្វកិច្ចត្រូវបំពេញដោយសារពុំមានសេចក្តីសម្រេចឯកច្ឆន្ទ បានបង្ហាញឱ្យឃើញពីភាពមិនស៊ីសង្វាក់គ្នាផ្ទៃក្នុង ដោយសារមានការយល់ឃើញថា ចំណាត់ការក្នុងការចេញដីកាពីរផ្ទុយគ្នា គឺជាការខុសច្បាប់ ហើយចៅក្រមទាំងប្រាំរូបបានយល់ឃើញថា ដីកាបញ្ជូនទៅជំនុំជម្រះមានសុពលភាព ខណៈពេលចៅក្រមបីរូបយល់ឃើញថា ដីកាលើកលែងចោទប្រកាន់មានសុពលភាពដូចគ្នា។ ដោយសារពុំមានបណ្តឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញពុំសមស្របនេះ ទើបសំណងតែមួយគត់ដែលអាចមានសម្រាប់អង្គជំនុំជម្រះនេះផ្តល់ គឺត្រូវប្រើប្រាស់សិទ្ធិអំណាចដែលជាឆន្ទានុសិទ្ធិ និងសិទ្ធិអំណាចដែលស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាស្តីពីបណ្តឹងសាទុក្ខ ឬបណ្តឹងសើរើ ដើម្បីបដិសេធដីកាបង្គាប់របស់អង្គបុរេជំនុំជម្រះ និងណែនាំឱ្យធ្វើការពិចារណាឡើងវិញលើដីកាដំណោះស្រាយផ្ទុយដល់ចៅក្រមអង្គបុរេជំនុំជម្រះក្នុងការចេញសេចក្តីសម្រេចមួយដែលត្រឹមត្រូវតាមច្បាប់។

72. តាមបទពិសោធន៍បានបង្ហាញថា ដំណោះស្រាយផ្លូវច្បាប់សាមញ្ញនេះ អាចជាការឥតប្រយោជន៍។ កំណត់ត្រាអតីតកាលនៃការប្រកាន់ខ្ជាប់ទស្សនៈរឹងរូសដដែលៗសម្រាប់ការបដិសេធកិច្ចស៊ើបសួរបន្ថែមណាមួយ ឬការជំនុំជម្រះក្នុងរឿងក្តី ០០៣ រឿងក្តី ០០៤/១ និងដំបូងឡើយក្នុងរឿងក្តី ០០៤/២ ចាប់តាំងមានការខ្វែងយោបល់ដំបូងក្នុងឆ្នាំ ២០០៨ លើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងទីបីដែលបានពិភាក្សាពេញលេញ បានរារាំងសេចក្តីសុទិដ្ឋិនិយមដែលសង្ឃឹមថា អ្វីៗនឹងប្រែប្រួល។ មានហេតុផលសង្ឃឹមដូចគ្នាសម្រាប់ចៅក្រមជាតិថា៖ (១) កិច្ចស៊ើបសួរបឋម មោឃៈ និងពុំស្របច្បាប់ និង (២) លោក សុខ អាន បានកំណត់គោលនយោបាយសាធារណៈថាមានតែការជំនុំជម្រះលើមេដឹកនាំជាន់ខ្ពស់ប្រាំរូបប៉ុណ្ណោះ (៣) ជនសង្ស័យពុំស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។ ជាការពិត ទាំងនេះបានរារាំងនូវក្តីសង្ឃឹមសមហេតុផលណាមួយលើដំណើរការទៅមុខស្តីពីបញ្ហានេះ។ ប្រហាក់ប្រែលគ្នានេះដែរ ប្រសិនបើសន្មតថា តាមនីតិវិធីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិអាចត្រូវបានបដិសេធចោល ក៏នៅតែមានលទ្ធភាពតិចតួចថា យោបល់រួមគ្នាអាចនឹងទទួលបានណាស់។ ដូច្នេះ ជាការជៀសពុំរួចដែលថាស្ថានការណ៍ដូចគ្នាដដែលនឹងកើតឡើងម្តងហើយម្តងទៀត ដោយពុំបានទទួលលទ្ធផល។

---

[183] សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) ទំព័រ ៤០។

73. បញ្ហានេះបាននាំខ្ញុំទៅរកស្ថានការណ៍បច្ចុប្បន្នដែលសហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងនូវការខកខានពីសំណាក់ចៅក្រមអង្គបុរេជំនុំជម្រះ ក្នុងការអនុវត្តច្បាប់ដូចដែលបានតម្រូវដោយកិច្ចព្រមព្រៀង អ.វ.ត.ក. និងច្បាប់បង្កើត អ.វ.ត.ក.។ *តាមសេចក្តីបញ្ជាក់ដំបូង* ដោយសារជាភាគីដែលមានចំណាប់អារម្មណ៍ សហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិលើកសំណើបែបនេះ។ ខ្ញុំពិចារណាឃើញថា អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ក.ត. មានសិទ្ធិអំណាចជាឆន្ទានុសិទ្ធិស្របច្បាប់ និងសីលធម៌ក្នុងការទទួលយកសំណើនេះ ហើយខ្ញុំស្នើពិចារណាលើអង្គសេចក្តីនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

## IV. អង្គសេចក្តី

### ក. សារណា

74. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា រឿងក្តី ០០៣ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[184] និងបានលើកឡើងថា៖

(១) ដីកាដំណោះស្រាយផ្ទុយគ្នា ពុំត្រូវបានចេញដោយខុសច្បាប់

(២) បើទោះបីជាការចេញដំណាលគ្នានោះខុសច្បាប់ក៏ដោយ ក៏ដីកាដំណោះស្រាយផ្ទុយគ្នានេះមានសុពលភាព

(៣) ដីកាបញ្ជូនទៅជំនុំជម្រះ ត្រូវបានរកឃើញជាឯកច្ឆន្ទថា មានសុពលភាព ដោយចៅក្រមអង្គបុរេជំនុំជម្រះ និង

(៤) ដីកាចោទប្រកានពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប[185]។

75. សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត បានសុំទទូចឱ្យអង្គជំនុំជម្រះនេះទទួលយកសារណារបស់ខ្លួនដូចគ្នាក្នុងរឿងក្តី ០០៤/២ តាមរយៈការប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការផ្តល់ការបំភ្លឺផ្នែកច្បាប់ដែលតម្រូវនៅគ្រប់ប្រព័ន្ធតុលាការ។ បន្ទាប់មក ភាគីទាំងពីរបានស្នើសុំសំណងខុសគ្នាទាំងស្រុង ប៉ុន្តែមានមូលដ្ឋានរួម គឺដើម្បីសង្គ្រោះរឿងក្តីនេះចេញពីភាពទាល់ច្រកផ្នែកនីតិវិធីបច្ចុប្បន្ន និងពុំដឹងស្ថានភាពជាក់លាក់ផ្នែកច្បាប់របស់រឿងក្តីបច្ចុប្បន្ននេះ។ ខណៈពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យអង្គជំនុំជម្រះនេះបង្គាប់ថា រឿងក្តី ០០៣ ត្រូវបញ្ជូន

---

[184] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៨៥។

[185] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៣។

ទៅអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការជំនុំជម្រះ រីឯសហមេធាវីការពារក្តីស្នើសុំថា រឿងក្តីប្រឆាំងនឹង មាស មុត នេះ ត្រូវបញ្ចប់[186]។

76. ទាក់ទងទៅនឹងសារណាពីរដំបូងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលលើកឡើងថា (១) ដីកាដំណោះស្រាយផ្ទុយគ្នា ពុំត្រូវបានចេញដោយខុសច្បាប់ និងថា (២) បើទោះបីថាការចេញក្នុងពេលតែមួយខុសច្បាប់ក៏ដោយ ក៏ដីកាដំណោះស្រាយផ្ទុយគ្នានេះ មានសុពលភាព។ អំណះអំណាងទីមួយពាក់ព័ន្ធទៅនឹងការជំទាស់មិនផ្ទាល់ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលពុំត្រូវបានអនុញ្ញាត លើកតែត្រូវបដិសេធចោល។ ពុំមានបណ្តឹងសាទុក្ខចេញពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ តាមមតិរបស់ខ្ញុំឃើញថា ប្រសិនបើការយល់ឃើញពីដំបូងលើសេចក្តីសម្រេចដែលពុំសមស្របរបស់អង្គបុរេជំនុំជម្រះ ពុំត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះតុលាការកំពូលតាមរយៈបណ្តឹងសាទុក្ខនោះទេ ដូច្នេះសេចក្តីសម្រេចនេះ នៅតែមានសុពលភាព។ នេះជាបញ្ហាចម្បង។

77. នៅពេលដែលចៅក្រមអង្គបុរេជំនុំជម្រះ បានបដិសេធភាពស្របច្បាប់នៃចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតនោះ ម្ចាស់បណ្តឹងឧទ្ធរណ៍ និងសហមេធាវីការពារក្តី មាស មុត បានព្យាយាមការពារនីត្យានុកូលភាពនៃភាពមិនប្រក្រតីនៃអ្វីដែលត្រូវហៅថាសេចក្តីសម្រេច ដែលបានគ្រោងទុកពីសំណាក់សហចៅក្រមស៊ើបអង្កេត ក្នុងការដាក់ដីកាដំណោះស្រាយដំណាលគ្នា និងផ្ទុយគ្នា។ ចំពោះខ្ញុំ ហាក់បីដូចជាថាបើទើបីជាចំណាត់ការរួមគ្នានេះ ពិតជាបានរារាំងដល់ការយកចំណេញពេលវេលាក្នុងចេញសេចក្តីសម្រេចបានលឿនជាងក្នុងការអនុវត្តតាមយន្តការស្វ័យប្រវត្តិតាមវិធាន ៧២ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ពុំបានរារាំងដល់អង្គបុរេជំនុំជម្រះ ក្នុងការមិនអើពើលើចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេត និងពិចារណាដីកាដំណោះស្រាយនីមួយៗដោយផ្អែកលើអង្គសេចក្តីនៃទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍ដាក់ដោយភាគីនោះឡើយ។ ការជម្រុញឱ្យចេញសេចក្តីសម្រេចផ្ទុយគ្នាក្នុងពេលតែមួយ គឺជាបញ្ហាពុំជាប់ពាក់ព័ន្ធ នៅពេលដែលមានសំណងអាចផ្តល់ដោយអង្គបុរេជំនុំជម្រះ។ ចៅក្រមអង្គបុរេជំនុំជម្រះមានសិទ្ធិអំណាចនៅក្នុងដៃ និងកាតព្វកិច្ចកំណត់តាមច្បាប់ និងផ្អែកតាមអង្គហេតុថា តើដីកាដំណោះស្រាយមួយណាមានសុពលភាព។ ចៅក្រមអង្គបុរេគ្មីពុំអើពើលើបញ្ហាថាតើ ដីកាដំណោះស្រាយនេះបានមកដល់ចំពោះមុខខ្លួនរបៀបណានោះទេ ប៉ុន្តែគប្បីបានដោះស្រាយតែមួយគត់លើទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍។ បើទោះបីជាចៅក្រមអង្គបុរេជំនុំជម្រះបានអនុវត្តតាមលំនាំចាស់ក្នុងការបែងចែក ផ្អែកលើមូលហេតុវប្បធម៌ក៏ដោយ ក៏គប្បីបានបង្កើតសេចក្តី

[186] The reliefs sought by the សហព្រះរាជអាជ្ញាអន្តរជាតិ និង the Co-Lawyers for YIM Tith in Case 00៤ are identical.

សម្រេចស៊ីសង្វាក់គ្នាដែលនាំទៅរកសច្ចភាពផ្លូវច្បាប់។ ទោះបីជាមានការខុសប្លែកគ្នារវាងវិធីសាស្ត្រ សេចក្តីសម្រេចស៊ីសង្វាក់គ្នានឹងអាចឱ្យវិធាននោះអនុវត្តបានដោយស្វ័យប្រវត្តិ។

78. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងបន្ថែមទៀតថា ដោយសារឋានៈស្មើគ្នា និងឯករាជ្យរបស់សហចៅក្រមស៊ើបអង្កេត និងយន្តការដំណោះស្រាយការខ្វែងយោបល់គ្នាមានអត្ថិភាព ការចេញដីកាដំណោះស្រាយពីផ្ទុយគ្នា ត្រូវបានអនុញ្ញាត និងត្រូវបានរំពឹងទុកក្នុងក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.[187]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកចំណុចនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ ដែលបានយល់ឃើញថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នា "ជៀសពុំរួច" ដោយសារការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត ដែលនៅតែមានៈជាងមួយទសវត្សរ៍ និងថា ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទំនងជាកាន់តែខ្លាំងឡើងក្នុងរឿងក្តី ០០៣[188]។

79. ចៅក្រមរូបនេះជឿជាក់ថា អាចធ្វើទៅបានយ៉ាងងាយស្រួល បើចៅក្រមស៊ើបអង្កេតទាំងពីររូបដែលមានសុចរិតភាព ទម្លាក់ចោលទស្សនៈផ្ទុយគ្នាមួយឡែកដោយស្មោះត្រង់។ ការពិភាក្សាខាងដើមរបស់ខ្ញុំស្តីពីភាពខុសគ្នាខាងវប្បធម៌អាចអនុវត្តបាន។

80. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា បើទោះបីជាការចេញដីកាដំណោះស្រាយពីរដំណាលគ្នានេះ ជាការខុសច្បាប់ក៏ដោយ ក៏កំហុសផ្នែកនីតិវិធីពុំបានធ្វើឱ្យមានភាពមិនយុត្តិធម៌ទាំងស្រុង ការប៉ះពាល់ជាសត្យានុម័ត ឬការរំលោភនីតិវិធី ដែលត្រូវឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ[189]។ ប្រសិនបើតម្រូវឱ្យផ្តល់សំណងណាមួយ អង្គបុរេជំនុំជម្រះបានធ្វើការពិចារណារួចរាល់ហើយលើដីកាដំណោះស្រាយផ្ទុយគ្នានេះ ដោយសារអង្គជំនុំជម្រះបានថ្លឹងថ្លែងលើអង្គសេចក្តីនៃដីកាដំណោះស្រាយទាំងពីរផងដែរ[190]។ សហព្រះរាជអាជ្ញាអន្តរជាតិបានទទួចសុំឱ្យអង្គជំនុំជម្រះនេះកុំចាត់ទុកការបញ្ចប់រឿងក្តីនេះជាសំណងសមស្របសម្រាប់កំហុសនីតិវិធី"ដែលមិនធ្ងន់ធ្ងរ" ដោយសារការបញ្ចប់នេះពុំមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ការប៉ះពាល់ដល់តម្លៃសង្គមយ៉ាងខ្លាំងក្នុងការរារាំងរឿងក្តីនេះមិនឱ្យបន្តដំណើរការ អត្ថប្រយោជន៍ និងសិទ្ធិរបស់ភាគីទាំងអស់ និងសមាមាត្រនៃសំណងទៅនឹងព្យសន

[187] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៣-៥៨។

[188] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៧។

[189] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦២-៦៦។

[190] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦៨។

កម្ម[191]។ អង្គជំនុំជម្រះតុលាការកំពូលបានអះអាងពីដំបូងថា ប្រសិនបើចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នានេះ គឺជាការខុសច្បាប់ហើយ ការប្រព្រឹត្តអំពើខុសច្បាប់នោះ ពុំអាចទៅជាស្របច្បាប់វិញបានឡើយ[192]។ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំយល់ស្រប និងបានទទួចសុំអង្គជំនុំនេះយល់ឃើញថា អ្វីដែលបានកើតឡើងគឺជាកំហុសនីតិវិធី[193]។ អំពើអនីត្យានុកូលភាពនោះពុំមានអានុភាពលើដីកានោះឡើយ។

81. តាមទស្សនៈរបស់ចៅក្រមរូបនេះ គឺថា ជាការពុំចាំបាច់ដែលត្រូវពិភាក្សាលើបញ្ហាកំហុសណាមួយរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងតួនាទីរៀងៗខ្លួនរបស់ពួកគាត់នោះឡើយ។ ចំណាត់ការ និងផលវិបាកនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺពុំមែនជាបញ្ហាស្នូលផ្នែកច្បាប់ក្នុងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិនេះទេ។ បញ្ហាសំខាន់គឺសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលមិនពេញលេញ ហើយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមានការយល់ឃើញពុំសមស្រប និងពុំស៊ីសង្វាក់គ្នានោះ នៅតែមានសុពលភាព លើកលែងតែអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ក្នុងនាមជាអង្គជំនុំជម្រះដែលត្រូវពិនិត្យចុងក្រោយ ខ្លួនមានយុត្តាធិការឆន្ទានុសិទ្ធិអនុវត្តក្នុងនាមជាតុលាការបណ្តឹងសាទុក្ខ។

82. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងទៅលើការអះអាងដែលថា ចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះបានយល់ស្របថា ដីកាបញ្ជូនទៅជំនុំជម្រះប្រឆាំងនឹង មាស មុត មានសុពលភាព និងដូច្នេះបង្កើតបានជាសេចក្តីសម្រេចមតិភាគច្រើនលើសលុបតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[194]។ ការយល់ឃើញនេះជាឯកច្ឆន្ទ បើទោះបីជាពុំត្រូវបានរួមបញ្ចូលក្នុង“ផ្នែកសម្រេចសេចក្តីរួម” នៃ*សេចក្តីពិចារណា* ឬថា ចៅក្រមបានទទួលការឯកច្ឆន្ទតាមរយៈសំអាងហេតុផ្សេងគ្នានោះឡើយ[195]។ សេចក្តីសម្រេចដែលមានភាពឯកច្ឆន្ទក្នុងរឿងក្តី ០០៣ គឺផ្ទុយពីការមោឃភាពលើដីកាបញ្ជូនទៅជំនុំជម្រះដោយចៅក្រមជាតិក្នុង*សេចក្តីពិចារណា*ក្នុងរឿងក្តី ០០៤/២[196]។ ការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះដោយអនុលោមតាមវិធាន

---

[191] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦៣ និង៦៧-៦៨។

[192] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ លើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារលេខ (E004/2/1/1/2) កថាខណ្ឌ ៦៧។

[193] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦៥។

[194] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦៩។

[195] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧០-៧១។

[196] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧២។

៧៧(១៣) នៃវិធានផ្ទៃក្នុង ពុំបានធ្វើឱ្យប៉ះពាល់ដល់ឋានៈស្មើគ្នារបស់សហចៅក្រមស៊ើបអង្កេត ឬសច្ចធារណ៍នៃនិរទោសរបស់ មាស មុត ឡើយ[197]។

83. មតិរបស់ចៅក្រនេះ គឺថា សេចក្តីសន្និដ្ឋានដែលថា ចៅក្រមប្រាំរូបបានពិចារណា/ផ្តល់សំអាងហេតុ ឬសម្រេចថា ដីកាបញ្ជូនទៅជំនុំជម្រះនេះមានសុពលភាពនោះ គឺជាការដកយកតែផ្នែកល្អៗដែលមានអត្ថប្រយោជន៍ផ្នែកច្បាប់គាំទ្រជំហររបស់ខ្លួនចេញពីសេចក្តីសម្រេចដែលមានវិការៈនោះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ តម្រូវឱ្យមានការសម្រេចមួយជាក់ច្បាស់ឥតព្រលាំត្រឹមត្រូវតាមច្បាប់។ នៅ អ.វ.ត.ក. សេចក្តីសម្រេចនេះត្រូវតែកើតចេញពីអានុភាពច្បាប់ច្បាស់លាស់ និងគោលជំហរស្វ័យប្រវត្តិ ឬចេញពីការយល់ឃើញដែលមានក្នុងផ្នែកសម្រេចសេចក្តី។ តាមការជាក់ស្តែង ពុំមានកង្វះភាពសមស្របនៅក្នុងសេចក្តីសម្រេចដែលចៅក្រមបីរូបនៃអង្គបុរេជំនុំជម្រះបានសម្រេចថា (១) ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺជាការខុសច្បាប់ (២) ដោយសារសហចៅក្រមស៊ើបអង្កេតមានឋានៈស្មើគ្នា ទើបដីកាសម្រេចនោះមានសុពលភាពស្មើគ្នា និង (៣) ដីកាសម្រេចនោះមានភាពស្មើគ្នា (៤) ដូច្នេះ សំណុំរឿង ០០៣ ប្រឆាំងនឹងជនត្រូវចោទ មាស មុត គប្បីត្រូវបានរក្សាទុកក្នុងបណ្ណសាររបស់ អ.វ.ត.ក. ។

84. នេះមានន័យថា ដោយសារពុំអាចធ្វើទៅរួចក្នុងការស្វែងរកភាពឯកច្ឆន្ទលើធម្មានុរូបនៃដីកាបញ្ជូនទៅជំនុំជម្រះបាន ទើបច្រានចោលមតិ ឬសំអាងហេតុដទៃទៀតដែលមានសុពលភាព។ ទស្សនៈរបស់ចៅក្រមរូបនេះនៅតែអះអាងថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះពុំមានសុពលភាពតាមផ្លូវច្បាប់ ដោយសារពុំមានតុលាការដែលធ្វើសេចក្តីសម្រេចសមហេតុផលណាមួយអាចធ្វើសេចក្តីសម្រេចដែលពុំសមស្របទាំងនោះបានឡើយ។ ជាការពុំអាចធ្វើទៅរួចដែលដកយកតែផ្នែកល្អៗចេញពីសេចក្តីសម្រេចដែលមិនល្អ ហើយមិនអើពើផ្នែកផ្សេងទៀត។

85. ទីបួន សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បើទោះបីជាត្រូវបានរកឃើញថា ពុំមានការយល់ឃើញជាឯកច្ឆន្ទ*តាមខ្លឹមសារ*នៃសុពលភាពដីកាបញ្ជូនទៅជំនុំជម្រះក៏ដោយ ក៏សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អង្គបុរេជំនុំជម្រះនៅតែតម្រូវឱ្យបញ្ជូនសំណុំរឿងទៅជំនុំជម្រះដោយសារដីកាបញ្ជូនទៅជំនុំជម្រះនោះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប[198]។ ជំហរដោយស្វ័យប្រវត្តិ"ដែលជាសារ

[197] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧៣-៧៤។

[198] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧៦។

វ័ន្ត និងឥតប្រែប្រួល"ថា កិច្ចស៊ើបសួរ គប្បីបន្តតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងនោះ គឺជាអាទិភាពគោលការណ៍ច្បាប់ពិសេសដែលគ្រប់គ្រងផ្ទាល់លើកម្មវត្ថុរឿងក្តីជាក់លាក់ និងមានឧត្តមភាពជាងវិធាន ៧៧(១៣)(ក)នៃវិធានផ្ទៃក្នុង ដូច្នេះតម្រូវថា ដីកចោទប្រកាន់ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[199]។ អង្គបុរេជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដោយសារខកខានក្នុងការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង លើកលែងតែរឿងក្តីនេះត្រូវបានបញ្ឈប់ដោយមតិភាគច្រើនលើសលុបអង្គបុរេជំនុំជម្រះ បើទោះបីជាដីកាលើកលែងចោទប្រកាន់កើតឡើងតំណាលគ្នាជាមួយនឹងដីកាបញ្ជូនទៅជំនុំជម្រះក៏ដោយ ក៏រឿងក្តីនេះនឹងត្រូវបន្តទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនទៅជំនុំជម្រះនេះ[200]។ ចុងក្រោយសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ក្រៅពីលើកលែងចោទប្រកាន់ ឬសម្រេចឱ្យរួចខ្លួនផ្អែកលើអង្គសេចក្តី ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងច្បាស់លាស់ និងបានកម្រិតលទ្ធភាពសម្រាប់ការបញ្ចប់បណ្តឹងអាជ្ញា[201] ដែលលក្ខខណ្ឌទាំងនោះពុំអាចអនុវត្តបានចំពោះរឿងក្តី ០០៣ និងថា អង្គជំនុំជម្រះតុលាការកំពូលពុំគប្បីយកតាមការអនុវត្តន៍របស់ខ្លួនក្នុងរឿងក្តី ០០៤/២ ដែលបានបង្គាប់ឱ្យបញ្ចប់សំណុំរឿងនេះ[202]។

86. ចំណុចភាគច្រើនដែលបានទទួចសុំដោយម្ចាស់បណ្តឹងសាទុក្ខ តាមទស្សនៈរបស់ខ្ញុំ គឺជារឿងសុពលភាព។ ទោះជាយ៉ាងណាក្តី ការលើកឡើងដែលថា យន្តការស្វ័យប្រវត្តិអាចអនុវត្តបាន ក្នុងករណីដែលគ្មានមតិភាគច្រើនលើសលុបគាំទ្រដីកាលើកលែងចោទប្រកាន់ បានសន្មតទុកជាមុននូវអត្ថិភាពនៃសេចក្តីសម្រេចមានសុពលភាព និងអាចអនុវត្តបានរបស់អង្គបុរេជំនុំជម្រះ។ ការពិតជាក់ស្តែង គឺថា អង្គជំនុំជម្រះនេះបានជៀសវាងការកំណត់ថា ដីកាដំណោះស្រាយណាមួយ មានសុពលភាព និងការផ្តល់ធម្មានុរូបនៃការពិនិត្យណាមួយ និងការយល់ឃើញ បើទោះបីមានការប្រកាសជាឯកច្ឆន្ទក្នុងផ្នែកសម្រេចសេចក្តីថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់។

87. យោងតាមសំអាងហេតុទាំងនេះ មតិរបស់ចៅក្រមរូបនេះបញ្ជាក់ថា ពុំមានការសន្និដ្ឋានផ្នែកច្បាប់គ្រប់គ្រាន់ក្នុងការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ អាចត្រូវបានធ្វើឡើងចេញពី *សេចក្តីពិចារណា* របស់អង្គបុរេជំនុំជម្រះ ដែលបានបង្កើតសេចក្តីសម្រេចពុំមានសុពលភាព។ បដិសេធសំណើរបស់សហព្រះរាជអាជ្ញា

---

[199] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧៧-៧៩។

[200] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៨០-៨១។

[201] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៨២។

[202] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៨២។

អន្តរជាតិសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា រឿងក្តី ០០៣ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងក្នុងកាលៈទេសៈនេះ។

## V. <u>សេចក្តីសន្និដ្ឋាន</u>

88. ច្បាប់ជាធរមាន មានការបង្ហាញច្បាស់លាស់ត្រឹមត្រូវ និងត្រូវបានពិភាក្សានៅគ្រប់ពេលដែលមានការខ្វែងយោបល់គ្នាក្នុងរឿងក្តីនេះ និងរឿងក្តីដទៃទៀតដែលពាក់ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីមួយ និងទីពីរដែលមានវិវាទ នៅចំពោះអង្គបុរេជំនុំជម្រះ។ ប្រវត្តិនៃការខ្វែងយោបល់គ្នានោះបានបង្ហាញថា ការវិវឌ្ឍន៍នៃរឿងក្តីទាំងនោះកើតមានតាមរយៈយន្តការស្វ័យប្រវត្តិតែប៉ុណ្ណោះ។ វិធានទាំងនេះបានដាក់សម្ពាធមកលើចំណាត់ការ និងបរិយាកាសជាតិ និងចុងក្រោយមុខតែជួបភាពទាល់ច្រកជាពុំខានដែលបានកើតឡើងគ្រប់រឿងក្តីដែលបានបញ្ជូនទៅមុខអង្គបុរេជំនុំជម្រះ។ ជាការពិបាកក្នុងការនិយាយពីមូលហេតុដែលនាំឱ្យមានការខកខានក្នុងការសេចកសេចក្តីសម្រេចមួយដែលផ្តល់ការបំភ្លឺច្បាស់លាស់តម្រូវនោះ។ ការប្រកាន់គោលជំហរឥតប្រែប្រួលរបស់សហចៅក្រមស៊ើបអង្កេតបានរួមចំណែកយ៉ាងច្រើន និងជាកត្តាតែមួយគត់ដែលរារាំងដល់សច្ចភាពផ្នែកច្បាប់។ ទស្សនៈរបស់ខ្ញុំបង្ហាញថា លើកលែងតែចំណុចដែលពុំអាចយល់បាន ភាពផ្សេងគ្នានៃវប្បធម៌ក៏មានតួនាទីរួមចំណែកផងដែរ។ បុគ្គលិកជាតិទទួលយកទស្សនៈនៃយុត្តាធិការលើរូបបុគ្គលផ្អែកលើគោលនយោបាយជាតិយ៉ាងងាយ ខណៈពេលបុគ្គលិកអន្តរជាតិ ផ្អែកច្រើនទៅលើច្បាប់បង្កើត អ.វ.ត.ក. កិច្ចព្រមព្រៀង អ.វ.ត.ក. និងវិធានផ្ទៃក្នុង។ ថាតើត្រូវពន្យល់យ៉ាងណាអំពីការវាយតម្លៃផ្សេងគ្នានូវអ្វីដែលហៅថា អ្នក“*ទទួលខុសត្រូវខ្ពស់បំផុត*”សម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅពេលតួនាទីកម្មាភិបាលខ្មែរក្រហមតាមភូមិភាគ និងមេបញ្ជាការយោធានោះត្រូវបានកម្រិតជាអប្បបរមា និងត្រូវបានកាត់បន្ថយស្មើទៅនឹងអ្នកដែលមានតួនាទីតូចតាចឆ្ងាយពីឧក្រិដ្ឋកម្ម មានអំណាចតិចតួច និងការចូលរួមដោយឥតសកម្ម និងនៅពេលដែលចរិតលក្ខណៈចាំបាច់របស់អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនោះ“គឺជាការផ្តោតចម្បងនៃការចូលរួមផ្ទាល់ដោយពុំគិតពីតួនាទីនោះឡើយ”។

89. នៅមានវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពសម្រាប់ដោះស្រាយបញ្ហាដែលពិបាកគ្រប់គ្រងស្តីពីយុត្តាធិការលើរូបបុគ្គល និងអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរពីដំបូង។ ដូចបានលើកឡើងសង្ខេបខាងលើប្រសិនបើបញ្ហានេះ គឺជាចំណុចស្នូលនៃការខ្វែងយោបល់គ្នា សហចៅក្រមស៊ើបអង្កេតគប្បីបានជ្រើសរើសបញ្ជូនការខ្វែងយោបល់គ្នានេះទៅអង្គបុរេជំនុំជម្រះ។ ប៉ុន្តែពុំបានធ្វើដូច្នេះទេ ដែលនេះជាសិទ្ធិរបស់ពួក

គាត់។ ទោះជាយ៉ាងណាក្តី ដីកាដំណោះស្រាយផ្ទុយគ្នានេះ បង្ហាញពីការខ្វែងយោបល់គ្នា[203]ដែលត្រូវបានប្តឹងឧទ្ធរណ៍ និងតវ៉ាដោយភាគីជំទាស់នៅមុខអង្គបុរេជំនុំជម្រះ។ បញ្ហាដែលផ្ទុយគ្នានេះ មានលក្ខណៈជាក់លាក់ និងគប្បីត្រូវបានចាត់ទុកជាបញ្ហាបឋមនៅចំពោះមុខអង្គជំនុំជម្រះនោះ។ ពិតណាស់ មានការប្រែប្រួលតិចតួចតាមការជាក់ស្តែង ឬជាគោលការណ៍ ប្រសិនបើការខ្វែងយោបល់គ្នាកើតចេញពីដីកាដំណោះស្រាយផ្ទុយគ្នា ឬការខ្វែងយោបល់គ្នាសម្ងាត់។ ទោះក្នុងករណីមួយណាក៏ដោយ អង្គសេចក្តីនៃការខ្វែងយោបល់គ្នាត្រូវតែបានពិចារណាដោយអង្គបុរេជំនុំជម្រះ។ ប្រសិនបើអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរដំបូងត្រូវបានពិនិត្យពេញលេញថា ជាបញ្ហាបឋមហើយ ប៉ុន្តែខកខានក្នុងការទទួលបានមតិភាគច្រើនលើសលុបតម្រូវពីចៅក្រមបួនរូប ដូចនេះ យន្តការស្វ័យប្រវត្តិនេះអាចកំណត់បាននូវការខ្វែងយោបល់គ្នាជាស្ថូលនោះ។ បញ្ហាអាចត្រូវបានដោះស្រាយសម្រាប់គោលបំណងនៃនីតិវិធីមុនដំណាក់កាលជំនុំជម្រះ ហើយកិច្ចស៊ើបសួរនោះអាចត្រូវបានបញ្ឈប់ដោយសារអនីត្យានុកូលភាព ឬអាចបន្តទៅមុខទៀតដោយផ្អែកលើមូលដ្ឋានថា កិច្ចស៊ើបសួរដំបូងមានសុពលភាព និងពុំអាចត្រូវបានលើកឡើងម្តងទៀត ដែលនេះជាមូលហេតុក្នុងការរារាំងការបញ្ជូនរឿងក្តីណាមួយទៅជំនុំជម្រះ។ ពុំមានអញ្ញត្រកម្មបឋមបែបនេះ ត្រូវបានលើកឡើងតាមការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាំងពីឆ្នាំ ២០០៩ និងត្រូវបានយោងទៅលើដោយចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឡើយ។ បញ្ហានៃអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋមបានបន្តធ្វើឱ្យខូច និងរាំងស្ទះការអនុវត្តន៍ច្បាប់។ បញ្ហាទាំងនេះពុំដែលត្រូវបានដោះស្រាយ។ បញ្ហាមួយទៀត គឺយុត្តាធិការលើរូបបុគ្គល។ បញ្ហានេះផងដែរគប្បីត្រូវបានចាត់ទុកថាជាបញ្ហាបឋមដាច់ដោយឡែកបន្ទាប់ពីមានការណែនាំបំភ្លឺផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងបណ្តឹងសាទុក្ខលើអង្គសេចក្តីក្នុងសំណុំរឿង ០០១ ស្តីពីបញ្ហាយុត្តាធិការ[204]។ សាជាថ្មីម្តងទៀតបញ្ហានេះត្រូវបានទុកឱ្យមានអត្ថិភាពរហូតដល់សព្វថ្ងៃ។

90. តាមរយៈការចង្អុលដាក់ និងប្រកាសថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតថា ខុសច្បាប់ និងក្នុងរឿងក្តីនេះ បានផ្តល់ការយល់ឃើញពុំស៊ីសង្វាក់គ្នាទាំងស្រុងជាមួយនឹងផ្នែកសម្រេចសេចក្តី អង្គបុរេជំនុំជម្រះបានបង្កើតសេចក្តីសម្រេចមួយដែលពុំបានផ្តល់ការបំភ្លឺ និងការបញ្ជាក់ចុងក្រោយ និងតាមធម្មតា

[203] ដោយសារបានជំទាស់ទៅនឹងការខ្វែងយោបល់គ្នា ដែលជាលក្ខណៈសំម្ងាត់ និងពុំត្រូវបានដាក់ចូលក្នុងសំណុំរឿង អនុលោមតាមវិធាន ៧២(២) នៃវិធានផ្ទៃក្នុង។

[204] *សូមមើល* សាលដីកាសំណុំរឿង ០០១ ឯកសារលេខ F28 ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ២៧-៤៣។

ពុំអាចយកជាការបាន។ សេចក្តីសម្រេចនេះត្រូវតែបដិសេធចោល ដោយសារភាពពុំសមស្រប និងពុំអាចអនុវត្តបាន។

91. ដូចបានលើកឡើងខាងលើ ក្នុងកាលៈទេសៈធម្មតា នៅពេលសេចក្តីសម្រេចមួយត្រូវបានបដិសេធចោល សំណុំរឿងត្រូវបង្វិលទៅស្ថាប័នដើមដែលបង្កើតនោះ ដែលក្នុងករណីនេះ គឺអង្គបុរេជំនុំជម្រះត្រូវចាប់ផ្តើមសាជាថ្មីម្តងទៀត និងពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួនដោយផ្អែកលើការណែនាំរបស់អង្គជំនុំជម្រះតុលាការបណ្តឹងសាទុក្ខ។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះលែងមានលក្ខណៈពេញលេញ និងអាចដំណើរការបានដែរ។ បើទោះបីត្រូវកោះហៅឡើងវិញ ក៏ពុំមានហេតុដែលអាចជឿបានថា ចៅក្រមនឹងមិនប្រកាន់ទស្សនៈរបស់ខ្លួនដើមដែលថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតគឺជាការខុសច្បាប់ និងក៏ពុំមានហេតុផលណាមួយជឿបានថា ភាពខុសគ្នានៃគោលនយោបាយស្តីពីយុត្តាធិការលើរូបបុគ្គល ឬអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរដំបូងក្នុងឆ្នាំ ២០០៨ នឹងប្រែប្រួលនោះដែរ។ បន្ថែមលើនេះ ក៏ពុំមានហេតុផលណាមួយជឿបានថា សមាសភាពជាតិនៃអង្គជំនុំជម្រះសាលាដំបូងនឹងទទួលយកទៅជំនុំជម្រះដែរ[205]។ ហើយក៏នៅមានសុទិដ្ឋិនិយមថា សហព្រះរាជអាជ្ញាជាតិ នឹងធ្វើការចោទប្រកាន់ដែរ។ ប្រសិនបើដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវបានបដិសេធចោល មានដីកាដំណោះស្រាយពីរផ្ទុយគ្នាដែលនៅសេសសល់ មួយចោទប្រកាន់ជនត្រូវចោទ មាស មុត និងមួយទៀត លើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់។ វិធីសាស្ត្រ*នយោបាយសុទ្ធសាធ* ត្រូវយកមកអនុវត្ត។ តុលាការមិនត្រូវធ្វើចំណាត់ការ និងចេញដីកាសម្រេចនៅពេលដែលជាការឥតប្រយោជន៍។

92. ដោយពិចារណាលើពេលវេលាដែលបានចំណាយលើការស៊ើបអង្កេតបុគ្គលមួយរូបដែលបានទទួលអត្ថប្រយោជន៍ពីគោលនយោបាយជាតិដែលមិនឱ្យចោទប្រកាន់ជនសង្ស័យក្នុងកម្រិតនៃការទទួលត្រូវជាន់ខ្ពស់បែបនេះ ហើយការដែលបន្តធ្វើបែបនេះទៀត គឺជាការពុំសមហេតុផលឡើយ។ ពុំមានលទ្ធភាពផ្លូវច្បាប់ជាក់ស្តែងដែលបើកចំហរឱ្យកែតម្រូវការកើតឡើងដែលមិនល្អក្នុងច្បាប់នោះឡើយ។ តាមមតិរបស់ខ្ញុំ ពុំ

---

[205] *សូមមើល* អ៊ីម៉ែលរបស់លោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១ ("ប្រធានអង្គជំនុំជម្រះអង្គជំនុំជម្រះសាលាដំបូងបានសុំឱ្យខ្ញុំផ្តល់ប្រឹក្សាភាគីថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានជូនដំណឹងអំពី "សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" និងពុំបានទទួលសំណុំរឿងនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំទទួលការទំនាក់ទំនងណាមួយពីភាគី(*សូមមើលផងដែរ* វិធាន ៧៧/១៤ នៃវិធានផ្ទៃក្នុង)")។ *សូមមើលផងដែរ* អ៊ីម៉ែលពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ D359/36.8 និង D360/45.8 ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០។

មានជម្រើសដែលនៅសេសសល់នោះទេ ក្រៅតែពីទទួលយកលទ្ធផលដែលជៀសពុំរួចថា៖ រឿងក្តី ០០៣ ប្រឆាំងនឹង មាស មុត គប្បីត្រូវបញ្ចប់។ បញ្ហានេះអាស្រ័យលើចំណាត់ការអយ្យការកម្ពុជាដែលជាអ្នកចាប់ផ្តើម ប្រសិនបើគាត់មានបំណងនោះ។

## VI. សេចក្តីបញ្ជាក់បន្ថែម

93. ជឿជាក់ថា ជាការចាំបាច់ដែលត្រូវដោះស្រាយភាពអាថ៌កំបាំងដែលត្រូវបាន បន្តឥតឈប់តាមរយៈចៅក្រមអង្គបុរេជំនុំជម្រះដោយសារការចេញសំអាងហេតុបដិសេធដីកាណាមួយដែលពាក់ព័ន្ធទៅនឹងបញ្ជូនរឿងក្តីទាំងនេះ ចាប់តាំងពីជុំទីពីរនៃកិច្ចស៊ើបសួរក្នុងឆ្នាំ ២០០៧/២០០៨។ មតិជំទាស់ខាងលើបានផ្តល់ប្រវត្តិនៃការអះអាងក្នុងការពិចារណា និងការរៀបរាប់នូវការពិតយ៉ាងពេញលេញ។

94. ខ្ញុំចាត់ទុកថាមានអត្ថប្រយោជន៍ខ្លាំងក្នុងការពិនិត្យលើឯកសារដែលបានដាក់ដោយសហព្រះរាជអាជ្ញាជាតិ នៅមុខអង្គបុរេជំនុំជម្រះនៅថ្ងៃទី ២៧ ខែ កុម្ភៈ[206] និង ២២ ខែ ឧសភា[207] ឆ្នាំ ២០០៩ ដើម្បីគាំទ្រជំហររបស់ខ្លួនដែលថា ចំណាត់ការកិច្ចស៊ើបសួរបន្ថែមលើជនសង្ស័យបន្ថែមអាចនឹងប៉ះពាល់ដល់សន្តិសុខជាតិ និងថា សុខ អាន ឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់នៅសភាជាតិថា ពុំមានការចោទប្រកាន់បន្ថែមទៀតកើតឡើងក្រៅតែពីជនសង្ស័យប្រាំនាក់ដែលបានកំណត់អត្តសញ្ញាណប៉ុណ្ណោះ។ ឯកសារភ្ជាប់ទៅនឹងមតិជំទាស់នេះ ដែលត្រូវបានសំអាងដោយសហព្រះរាជអាជ្ញាជាតិ ក្នុងសារណាដែលបានលើកឡើងខាងលើ គឺជាប់ពាក់ព័ន្ធជាទូទៅទៅនឹងការចរចាដែលនាំទៅរកកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជា ដើម្បីបង្កើត អ.វ.ត.ក.៖

(១) អត្ថបទបីបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី *ការស្វែងរកការពិត* និពន្ធដោយ Thomas HAMMARBERG ដែលមានការជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងការចរចាចាប់តាំងពីដំបូង[208]

---

[206] សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ អោយដាក់សារណាបន្ថែម ឯកសារលេខ ១០ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ (No. 10)") ។

[207] សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការបង្គាប់របស់អង្គបុរេជំនុំជម្រះឱ្យដាក់ការបញ្ជាក់បន្ថែម ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ និង សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ឯកសារលេខ ១៧ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩។

[208] អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្សរណៈរបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបោះពុម្ពផ្សាយ ក្នុងទស្សនាវដ្តី *ការស្វែងរកការពិត* លេខ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០១ ឧបសម្ព័ន្ធទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ (ឯកសារលេខ ១០) ឯកសារលេខ ១០.២ ("អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្ស

*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.*

(២) កំណត់ហេតុនៃសម័យប្រជុំសភាជាតិពេញអង្គនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០០០៖ បទបង្ហាញ និងសេចក្ដីអធិប្បាយ ស្ដីពីសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ("សេចក្ដីព្រាងច្បាប់") ក្នុងឆ្នាំ ២០០០[209]

(៣) កំណត់ហេតុនៃសម័យប្រជុំសភាជាតិពេញអង្គនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០០៤៖ ការពិភាក្សា និងឯកភាពលើកិច្ចព្រមព្រៀង អ.វ.ត.ក. និងវិសោធនកម្មលើសេចក្ដីព្រាងច្បាប់ឆ្នាំ ២០០១[210]

ឯកសារទាំងនេះ ជាសាធារណៈ ហើយការយោងចេញពីប្រតិចារឹកសម័យប្រជុំសភាជាតិពេញអង្គត្រូវបានធ្វើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរស្ដាពររបស់សហព្រះរាជអាជ្ញាជាតិក្នុងសំណុំរឿង ០០៣ ០០៤ និង ០០៤/២[211] ដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំ

រណៈរបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា(ឯកសារលេខ ១០.៤)")។ លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣)។ អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិ(ឯកសារលេខ ១០.៤)។

[209] សុន្ទរកថារបស់អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជាក្នុងសម័យប្រជុំសភាពេញអង្គ ត្រូវបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីការស្វែងរកការពិត លេខ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ឧបសម្ព័ន្ធទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ(ឯកសារលេខ ១០) ឯកសារលេខ ១០.៥ ("កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គ ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥)")។

[210] សម័យប្រជុំពេញអង្គលើកទីមួយ នីតិកាលទីបីនៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ៤-៥ ខែ តុលា ឆ្នាំ ២០០៤។

[211] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ដាពរពាក់ព័ន្ធ មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ឯកសារលេខ D256/6 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ កថាខណ្ឌ ២៦-៣០។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ដាពរ ពាក់ព័ន្ធទៅនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ឯកសារលេខ D378/1 ថ្ងៃទី ០៣១ ខែ ឧសភា ឆ្នាំ ២០១៨ កថាខណ្ឌ ២៤-២៨។ សំណុំរឿង ០០៤/២ ដីកាសន្និដ្ឋានស្ដាពរពាក់ព័ន្ធនឹង អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ឯកសារលេខ D351/4 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ កថាខណ្ឌ ២៨-៣២។

រឿង ០០៣ ០០៤ និង ០០៤/២[212] និងមតិរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះក្នុងសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ និង ០០៤/២[213]។

95. ជាការចាំបាច់សម្រាប់ខ្ញុំត្រូវពិនិត្យដោយយកចិត្តទុកដាក់លើឯកសារដែលបានដាក់ដោយសហព្រះរាជអាជ្ញាជាតិចំពោះមុខអង្គបុរេជំនុំជម្រះក្នុងឆ្នាំ ២០០៩ ដើម្បីកំណត់ពីភាពពិតប្រាកដនៃអ្វីដែលត្រូវបានអះអាងបញ្ជាក់ និងលើកដដែលៗក្នុងកម្រិតមួយខុសប្រក្រតីដោយសហព្រះរាជអាជ្ញាជាតិ សហចៅក្រមស៊ើបអង្កេតជាតិ និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ។ នេះគឺជាប្រភពខុសពីធម្មតាសម្រាប់តុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិ ដែលឯកសារយុត្តាធិការរបស់តុលាការនេះ គឺជាច្បាប់បង្កើត អ.វ.ត.ក. និង កិច្ចព្រមព្រៀង អ.វ.ត.ក. ដែលសំអាងទៅលើអ្វីដែលបានបញ្ជាក់ដោយអ្នកនយោបាយ ក្នុងអំឡុងពេលពិភាក្សាក្នុងសភា។ អ្វីដែលបានលើកឡើងក្នុងសភានោះ គឺពុំមែនប្រភពនៃច្បាប់ដែលកំណត់នោះទេ។ មានសំណួរចោទសួរថា ប្រសិនបើអ្វីដែលបានអះអាងនោះ <u>ពិតជាបានលើកឡើងមែន</u>។ មន្ត្រីតុលាការត្រូវតែអនុវត្តតាមច្បាប់ មិនមែនតាមអ្វីដែលខ្លួនគិតថាជាច្បាប់នោះទេ។ ក្នុងការអនុវត្តន៍ច្បាប់ គេរំពឹងថា ឯកសារនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ត្រូវបានចាត់ទុកថាពិសិដ្ឋបំផុត។ កិច្ចព្រមព្រៀងទាំងនេះ និងវិធានផ្ទៃក្នុងក្រោយៗ ត្រូវបានបង្កើតឡើងតាមរយៈការចរចា ពិភាក្សា និងការធ្វើសច្ចាប័ន ដោយសភាជាតិ ឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ និងចុងក្រោយត្រូវបានប្រកាស់ឱ្យប្រើប្រាស់ជាផ្លូវការ។ ឯកសារទាំងនេះបានក្លាយជា ឬគប្បីជាមូលដ្ឋាននៃច្បាប់ដែលបានអនុវត្តដោយ អ.វ.ត.ក.។

96. ខ្ញុំបានអានដោយយកចិត្តទុកដាក់នូវប្រតិចារឹកនៃការពិភាក្សា និងរកពុំឃើញមានភស្តុតាងអ្វីគាំទ្រមូលដ្ឋានដែលថា បុព្វកថាចំពោះច្បាប់បង្កើត អ.វ.ត.ក. និងកិច្ចព្រមព្រៀង អ.វ.ត.ក. បានកំណត់ការចោទ

[212] សំណុំរឿង ០០៣ ដីកាលើកលែងចោទប្រកាន់ប្រឆាំងនឹង មាស មុត ឯកសារលេខ D266 ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ កថាខណ្ឌ ៣៩៨។ សំណុំរឿង ០០៤ ដីកាលើកលែងចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ឯកសារលេខ D381 ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ កថាខណ្ឌ ៦៣៦-៦៣៨។ សំណុំរឿង ០០៤/២ ដីកាលើកលែងចោទប្រកាន់ប្រឆាំងនឹង អោ អាន ឯកសារលេខ D359 ថ្ងៃទី ១៦ ខែ សីហា ២០១៨ កថាខណ្ឌ ៥៤០-៥៤២។

[213] សំណុំរឿង ០០៤ សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឯកសារលេខ D381/45 & D382/43 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ចុល និង ហួត វុទ្ធី កថាខណ្ឌ ១២៣ និង ១២៦-១២៨។ សំណុំរឿង *០០៤/២* សេចក្តីពិចារណាស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ D359/24 & D360/33 ("សេចក្តីពិចារណាសំណុំរឿង ០០៤/២ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (D359/24 & D360/33)") មតិរបស់ចៅក្រម ប្រាក់ គឹមសាន ន័យ ចុល និង ហួត វុទ្ធី កថាខណ្ឌ ២៤០-២៥០។

ប្រកាន់គប្បីត្រូវចាប់ផ្តើមនោះឡើយ។ បុព្វកថាច្បាប់ តាមធម្មតា ពុំមែនជាផ្នែកនៃច្បាប់សម្រាប់គោលបំណងបកស្រាយ ប៉ុន្តែសម្រាប់ធ្វើជាសវតារសម្រាប់ច្បាប់បន្តបន្ទាប់។ ជាការធម្មតាក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ដែលមានបុព្វកថាខ្លី ផ្តល់ជាហេតុផលសម្រាប់ច្បាប់ ឬវិសោធនកម្ម ដល់លក្ខន្តិកៈពាក់ព័ន្ធ ហើយជានិច្ចកាលបញ្ជាក់ថា បុព្វកថា ឬសេចក្តីផ្តើម ពុំមែនជាផ្នែកនៃច្បាប់ឡើយ។ ឯកសារប៉ែកអឺរ៉ុប ដែលគួរឱ្យសរសើរដោយសារភាពច្បាស់លាស់ រៀបរាប់ហេតុផលថា សម្រាប់វិសោធនកម្ម ដោយប្រើប្រាស់ពាក្យពេចន៍ *ដោយហេតុ* ដែលពីប្រយោគមួយទៅមួយនាំអ្នកអានឆ្លងកាត់ច្បាប់អត្ថិភាព តម្រូវការកែប្រែ វិធីសាស្ត្រកែប្រែដែលបានសម្រេច និងរៀបរាប់ការកែប្រែដែលមានបន្ទាប់។ រូបមន្ត *ដោយហេតុ* ដូចគ្នានេះ ត្រូវបានប្រើប្រាស់សម្រាប់ច្បាប់បង្កើត អ.វ.ត.ក. និងកិច្ចព្រមព្រៀង អ.វ.ត.ក.។

97. មានវិធានច្រើននៃការបកស្រាយដែលអ្នកអនុវត្តច្បាប់បានដឹង។ ការផ្អែកលើទៅលើការពិភាក្សាផ្លូវការរបស់សភា គឺជាវិធីសាស្ត្របកស្រាយមួយ នៅពេលដែលខ្លឹមសារសាមញ្ញធម្មតារបស់ពាក្យ និងគោលបំណងនៃវិធាន ពុំបានបំភ្លឺច្បាប់លាស់។ ចៅក្រម និងអយ្យការ ពុំអាចដកយកផ្នែកនៃលក្ខន្តិកៈដែលសក្តិសម ហើយមិនអើពើផ្នែកដទៃទៀតដោយសេរីនោះទេ។ ប្រសិនបើមានបញ្ហានេះកើតឡើង មូលដ្ឋាននៃនីតិរដ្ឋ ត្រូវបានបំផ្លាញដល់ចំណុចដែលលែងមានអាទិភាព។

98. អត្ថបទជាច្រើនដែលបាននិពន្ធដោយ Thomas HAMMARBERG ក្នុងទស្សនាវដ្តី *ការស្វែងរកការពិត* ការបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១៩ និងបន្តបន្ទាប់ពី ចាប់តាំងពី ខែ កក្កដា ឆ្នាំ ២០០១ ត្រូវបានពិនិត្យ។ Thomas HAMMARBERG បានយោងទៅលើក្រុមអ្នកជំនាញដែលបានតែងតាំងដោយអង្គការសហប្រជាជាតិ ដែលបានប្រគល់កាតព្វកិច្ចស៊ើបអង្កេត និងផ្តល់ប្រឹក្សាលើបញ្ហាថា តើគប្បីមានការចោទប្រកាន់ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ដែរ ឬយ៉ាងណា។ ក្រុមអ្នកជំនាញបានផ្តល់ប្រឹក្សាដល់អគ្គលេខាធិការ Kofi ANNAN ថា៖

> ផ្អែកតាមគោលនយោបាយនៃការចោទប្រកាន់ ព្រះរាជអាជ្ញាបានកម្រិតកិច្ចស៊ើបសួររបស់ខ្លួនត្រឹមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ។ នេះបានរួមបញ្ចូលមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវសម្រាប់ការរំលោភបំពានព្រមទាំងអ្នកដែលនៅកម្រិតទាបជាងដែលបានពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត[214]។

[214] អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្សរណៈរបស់អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជា (ឯកសារលេខ ១០.២) លេខ ERN ០០២៩៥០១៥។

99. គាត់បានសរសេរថា អ្នកជំនាញបានសង្កត់ធ្ងន់ថា បញ្ជីឈ្មោះកម្មាភិបាលជាន់ខ្ពស់នៃរដ្ឋាភិបាល និងបក្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យអាចពុំឆ្លើយតបជាមួយនឹងបញ្ជីឈ្មោះបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ការរំលោភបំពានលើច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក[215]។ មេដឹកនាំរដ្ឋាភិបាលមួយចំនួននៃរបបកម្ពុជាប្រជាធិបតេយ្យ អាចត្រូវបានដកចេញដោយពុំបានដឹង និងចេញពីការសម្រេច ខណៈពេលមេដឹកនាំដទៃទៀត ដែលពុំស្ថិតក្នុងបញ្ជីនៃមេដឹកនាំជាន់ខ្ពស់ បែរជាមានតួនាទីសំខាន់[216]។ នេះហាក់បីដូចជាការពិតទាក់ទងទៅនឹងមេដឹកនាំមួយចំនួននៅតាមភូមិ ព្រមទាំងកម្មាភិបាលមន្ទីរសួរយកចម្លើយ និងធ្វើទារុណកម្ម ដូចជាទួលស្លែង[217]។ ក្រុមអ្នកជំនាញបានផ្តល់ប្រឹក្សាថា គោលបំណងពីររបស់តុលាការ គឺការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងការផ្សះផ្សាជាតិក្នុងកម្ពុជា[218]។

100. នៅក្នុងផ្នែកបន្តរបស់គាត់អត្ថបទលេខ ២០ *ការស្វែងរកការពិត* Thomas HAMMARBERG បានរៀបរាប់ពីកិច្ចប្រជុំជាមួយនឹងនាយករដ្ឋមន្ត្រីក្នុងខែ មីនា ឆ្នាំ ១៩៩៩[219]។ នៅដំណាក់កាលនោះ មេដឹកនាំសំខាន់ៗនៃខ្មែរក្រហមបានចូលសារភាព ស្ថិតក្រោមការចាប់ខ្លួន ឬបានទទួលមរណភាព[220]។ ជាឧទាហរណ៍ តា ម៉ុក ត្រូវបានចាប់ខ្លួន[221] ត្រូវបានប្រកាសថា ការជំនុំជម្រះរបស់គាត់នឹងចាប់ផ្តើមនៅមុខតុលាការព្រហ្មទណ្ឌជាតិ[222]។ Thomas HAMMARBERG បានកត់សម្គាល់ថា មានការប្រែប្រួលឥរិយាបទ

---

[215] អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្សរណៈរបស់អ្នកតំណាង រាជរដ្ឋាភិបាលកម្ពុជា (ឯកសារលេខ ១០.២) លេខ ERN 00២៩៥០១៥។

[216] អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្សរណៈរបស់អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជា (ឯកសារលេខ ១០.២) លេខ ERN 00២៩៥០១៥។

[217] អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្សរណៈរបស់អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជា (ឯកសារលេខ ១០.២) លេខ ERN 00២៩៥០១៥។

[218] អនុសាសន៍របស់ក្រុមអ្នកជំនាញ និងអនុស្សរណៈរបស់អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជា (ឯកសារលេខ ១០.២) លេខ ERN 00២៩៥០១៥។

[219] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣)។

[220] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN 00២៩៥០១៨។

[221] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN 00២៩៥០១៨។

[222] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN 00២៩៥០១៧។

របស់មេដឹកនាំរាជរដ្ឋាភិបាលកម្ពុជាដែលលែងត្រូវការជំនួយអន្តរជាតិ អយ្យការបរទេស ឬចៅក្រមបរទេស[223]។ ទោះជាយ៉ាងណាក្តី ក្រុមអ្នកជំនាញបានរកឃើញថា អានុភាពនៃជម្លោះដែលអូសបន្លាយ និងគោលនយោបាយរបស់ខ្មែរក្រហមដែលមានការសម្លាប់អ្នកចេះដឹងក្នុងទ្រង់ទ្រាយធំ បានបន្សល់ទុក ចៅក្រម អ្នកស៊ើបអង្កេត មេធាវី ដែលពុំបានទទួលនូវការអនុវត្តន៍ទាក់ទងទៅនឹងនីតិវិធីត្រឹមត្រូវ[224]។ ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍ថា បទដ្ឋានអន្តរជាតិត្រូវបានតម្រូវ[225]។

101. ឯកសារទាំងនោះបានបង្ហាញច្បាស់ថា ភាពល្ងឹងជូរចត់មានអត្ថិភាពជាមួយនឹងអ្នកនយោបាយជាន់ខ្ពស់កម្ពុជាទាក់ទងទៅនឹងការប្រព្រឹត្តស្មោះត្រង់ស្លូតបូតរបស់សហគមន៍អន្តរជាតិលើខ្មែរក្រហមបន្ទាប់ពីពួកគេត្រូវបានផ្តួលរំលំ រួមទាំងការរក្សាអាសនៈនៅអង្គការសហប្រជាជាតិ និងការទទូចចង់បានរបស់សហគមន៍អន្តរជាតិពាក់ព័ន្ធទៅនឹងការចរចារកសន្តិភាព[226]។ Thomas HAMMARBERG បានសំដៅទៅលើបរិកាសនយោបាយថា "បច្ចុប្បន្ន កម្ពុជាបានទទួលសន្តិភាព និងការផ្សះផ្សា និងអំពាវនាវឱ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។ តើយើងគួរជឿពួកគេបានទេ?"[227]

102. ហាក់បីដូចជាថា មេដឹកនាំកម្ពុជាលែងដើរតួនាទីសកម្មបច្ចុប្បន្ន ដែលអ្វីៗបានផ្លាស់ប្តូរត្រង់ថា ជាតិនិយម និងការស្វែងរកអធិបតេយ្យភាព បានមកជំនួសការក្តីអស់សង្ឃឹម និងប្រហែលជាលែងត្រូវការការជួយពីខាងក្រៅ[228]។ រាជរដ្ឋាភិបាលកម្ពុជាអាចនឹងសម្រេចថា ត្រូវចោទប្រកាន់តាមរបៀបណា ប្រសិនបើ

---

[223] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN ០០២៩៥០១៨។

[224] អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០១៩។

[225] អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០១៩។

[226] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN ០០២៩៥០១៨។ អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០១៩។

[227] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN ០០២៩៥០១៨។

[228] លិខិតឆ្លើយតបចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ទៅអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៣) លេខ ERN ០០២៩៥០១៨។ អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០១៩, ០០២៩៥០២៤។

ខ្លួនត្រូវចោទប្រកាន់នោះ[229]។ មានអ្នកខ្លះបានលើកឡើងថា ការចោទប្រកាន់លើខ្មែរក្រហមនឹងនាំទៅរកសង្គ្រាមស៊ីវិលថ្មីមួយ[230]។ ការពិភាក្សាសំខាន់គឺលើអធិបតេយ្យភាព[231]។ យុត្តិធម៌សម្រាប់ជនរងគ្រោះលែងជាបញ្ហាសត្យានុម័ត ហើយការពិភាក្សាអំពីតុលាការព្រហ្មទណ្ឌខ្មែរក្រហម ត្រូវបញ្ចប់[232]។ យោងតាមឯកសារដែលបានបង្ហាញដោយសហព្រះរាជអាជ្ញាជាតិថា នឹងមានប្រតិកម្មអវិជ្ជមានយ៉ាងខ្លាំងពីប្រជាជនកម្ពុជា បន្ទាប់ពីការបញ្ឈប់ការជជែកថា តុលាការព្រហ្មទណ្ឌអន្តរជាតិលែងមានតទៅទៀត[233]។ នេះបង្ហាញថា នៅមានការស្រេកឃ្លាននូវតុលាការព្រហ្មទណ្ឌឯករាជ្យផ្អែកលើបទដ្ឋានអន្តរជាតិ[234]។

103. ជាយថាហេតុ ក្រោមការណែនាំរបស់ សុខ អាន តំណាងឱ្យក្រុមចរចាកម្ពុជា គំនិតនៃតុលាការរួមគ្នាមួយបានចាប់ផ្តើមពិភាក្សា[235]។ អាចជាតុលាការមួយដែលមានចៅក្រមកម្ពុជា ប៉ុន្តែជាតុលាការដែលអនុវត្តបទដ្ឋានអន្តរជាតិពាក់ព័ន្ធ[236]។ ក្រុមការងារត្រូវបានបង្កើតឡើងដោយ សុខ អាន[237]។ អត្ថបទដែលបង្ហាញនេះ កើតឡើងក្រោយដំណើរការយឺតយ៉ាវ និងយឺតចាប់ ទស្សនៈផ្ទុយគ្នាអំពីវិធីសាស្ត្រ ឬថាតើតុលាការកម្រិតអន្តរជាតិនេះត្រូវប្រតិបត្តិការយ៉ាងដូចម្តេច។

---

229 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២៥។

230 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០១៩។

231 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០១៩។

232 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២០។

233 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២០។

234 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២០។

235 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២០, ០០២៩៥០២១, ០០២៩៥០២៣។

236 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២១។

237 អនុសាសន៍របស់ក្រុមអ្នកជំនាញក្នុងការពិភាក្សារវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ឯកសារលេខ ១០.៤) លេខ ERN ០០២៩៥០២៣។

104. សេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានដាក់នៅចំពោះមុខសភាជាតិ ក្នុងឆ្នាំ ២០០០[238] និងសេចក្តីព្រាងច្បាប់វិសោធនកម្មសេចក្តីព្រាងច្បាស់ ឆ្នាំ ២០០១[239]។ សេចក្តីព្រាងច្បាប់ត្រូវបានបញ្ចប់ ដោយមានការគាំទ្រពីគ្រប់ភាគីដែលតំណាងក្នុងសភា ឆ្នាំ ២០០០[240]។ ប្រតិចារឹកបានបង្ហាញថា សុខ អាន បានពន្យល់យ៉ាងទូលំទូលាយថា អធិបតេយ្យភាពកម្ពុជា ពុំត្រូវបានធ្វើឱ្យខូចតាមរយៈការអនុញ្ញាតឱ្យមាន ការចូលរួមរបស់ចៅក្រមបរទេសឡើយ[241]។ គាត់បានលើកឧទាហរណ៍តុលាការយោធាអន្តរជាតិក្រោយ សង្គ្រាមលោក តុលាករព្រហ្មទណ្ឌអន្តរជាតិ ICTY និងតុលាការ ICTR[242] និងលទ្ធភាពនៃតុលាការអ ចិន្ត្រៃយ៍អន្តរជាតិដែលឱ្យអ្នកឈ្នះចោទប្រកាន់អ្នកចាញ់ ហើយមានតែតុលាការអចិន្ត្រៃយ៍ ទើបធ្វើដូច្នោះ[243]។ គាត់បានជូនដំណឹងទៅសភាជាតិអំពីគោលគំនិតនៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់ការ ប្រព្រឹត្តឧក្រិដ្ឋកម្ម[244] និងដំណើរការនីតិវិធី ដែលឧក្រិដ្ឋកម្មចម្បងត្រូវបានជំនុំជម្រះដោយតុលាការនោះ ដែលពុំស្ថិតក្នុងប្រទេសរបស់ខ្លួនផ្ទាល់ ប៉ុន្តែថា ជនល្មើសកម្រិតទាបត្រូវបានជំនុំជម្រះដោយតុលាការក្នុង ស្រុក[245]។ ជាមួយកំណត់សម្គាល់ដែលថា គោលគំនិតរបស់ចៅក្រមបរទេសត្រូវជាប់ពាក់ព័ន្ធនោះ ពុំមែន ជារឿងថ្មីទេ ប៉ុន្តែថា តុលាការដែលបានស្នើឡើងមួយនេះដែលកម្ពុជាគឺជាម្ចាស់ប្រទេស ហើយអង្គការ សហប្រជាជាតិ ជាអ្នកជួយ ជារឿងថ្មី[246] គាត់បានស្នើឡើងប្រព័ន្ធកូនកាត់មួយ ដែលមានសហព្រះរាជ អាជ្ញា ភាពពិសេសរបស់សភាស៊ើបសួរ សហចៅក្រម និងគោលគំនិតនៃមតិភាគច្រើនលើសលុប[247]។ គាត់បានកត់សម្គាល់ថា ប្រសិនបើសេចក្តីព្រាងច្បាប់ត្រូវបានអនុម័តដោយសភាជាតិ អ.វ.ត.ក. នឹងដំណើរ ការទៅមុខ[248]។

[238] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥)។

[239] សម័យប្រជុំពេញអង្គលើកទីមួយនីតិកាលទីបីនៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ៤-៥ ខែ តុលា ឆ្នាំ ២០០៤។

[240] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ៣-៤, ៩-១០។

[241] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤-១៥, ១៨-១៩។

[242] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១១-១២។

[243] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១២។

[244] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១២។

[245] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១២។

[246] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤, ១៥, ១៧។

[247] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤-១៥, ១៨-២០។

[248] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ៦៣។

105. គោលការណ៍ណែនាំនៃសេចក្តីព្រាងច្បាប់ ដែលគាត់បានលើកឡើងមាន៖ (១) ទាក់ទងទៅនឹង និងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងសហគមន៍អន្តរជាតិ[249] (២) ការរក្សាសន្តិភាព ស្ថិរភាពនយោបាយ ឯកភាពជាតិកម្ពុជាដែលមានការអភិវឌ្ឍន៍តិចតួចដោយសារសង្គ្រាមស៊ីវិល[250] និង (៣) ទាក់ទងទៅនឹងអធិបតេយ្យជាតិ រួមទាំងបូរណភាពទឹកដី[251]។ ពាក់ព័ន្ធទៅនឹងគោលការណ៍នៃអធិបតេយ្យភាពជាតិ គាត់បានពន្យល់ថា ការទទួលយកការចូលរួមពីចៅក្រមបរទេស គឺជាការសម្របសម្រួលមួយ ដើម្បីធានានូវការគាំទ្រពីសហគមន៍អន្តរជាតិ ជាពិសេស អង្គការសហប្រជាជាតិ និងដើម្បីផ្តល់ភាពជឿជាក់បាន[252] និងថា អ្វីដែលបានទទួលក្នុងការចរចា គឺថា រាល់ចៅក្រមនឹងត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សាអង្គចៅក្រម បន្ទាប់ពីការជ្រើសតាំងដោយចៅក្រមអន្តរជាតិដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ[253]។ គាត់បានបន្ថែមថា នឹងមានចៅក្រមជាតិមតិភាគច្រើន ប៉ុន្តែសេចក្តីសម្រេចត្រូវផ្អែកលើរូបមន្តថ្មីមួយ គឺវិធានមតិភាគច្រើនលើសលុប ដែលអាចបំបែកភាពទាល់ច្រកនៅពេលមានចៅក្រមអន្តរជាតិមួយរូបគាំទ្រចៅក្រមជាតិ[254]។ គាត់បញ្ជាក់ថា គោលការណ៍ទាំងអស់នេះឆ្លុះបញ្ចាំងការគោរពរបស់អង្គការសហប្រជាជាតិចំពោះអធិបតេយ្យភាពជាតិរបស់កម្ពុជា និងថា រយៈពេលដ៏យូរនៃការចរចាចាប់តាំងពី ឆ្នាំ ១៩៩៧ បានខិតខំប្រឹងប្រែងទទួលបានតុលាការព្រហ្មទណ្ឌមួយដែលមានចរិតលក្ខណៈអន្តរជាតិ[255]។

106. បញ្ហាយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ត្រូវបានដោះស្រាយក្នុងឆ្នាំ ២០០៤។ ជាការឆ្លើយតបទៅនឹងសំណួរចោទសួរថាតើ នរណា និងវិធីសាស្ត្របៀបណាដែលត្រូវចោទប្រកាន់ សុខ អាន បានប្រាប់ ប៉ុន្តែពុំបានផ្តោតថា ចំនួនកម្រិតនៃជនសង្ស័យត្រូវធ្វើការចោទប្រកាន់នោះទេ[256]។

> ឯកឧត្តម សុខ អាន៖ [...] មាត្រា ២ ដោះស្រាយលើពាក្យពេចន៍មេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ យោងតាមពាក្យពេចន៍នេះ យើងអាចកំណត់អត្តសញ្ញាណបានគោលដៅពីរ។ គោលដៅទីមួយ គឺមេដឹកនាំ។ យោងតាមរចនាសម្ព័ន្ធមូលដ្ឋានតុលាការ សហព្រះរាជអាជ្ញា មានជាតិ និងអន្តរ

---

[249] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៣។

[250] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១១-១២។

[251] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤-១៥។

[252] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤។

[253] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤។

[254] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៤-១៥។

[255] កំណត់ហេតុសម័យប្រជុំសភាជាតិពេញអង្គថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ (ឯកសារលេខ ១០.៥) ទំព័រ ១៥។

[256] សម័យប្រជុំពេញអង្គលើកទីមួយនីតិកាលទីបីនៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ៤-៥ ខែ តុលា ២០០៤។

ជាតិ គឺជាអ្នកដែលមានសិទ្ធិកំណត់អត្តសញ្ញាណនរណាត្រូវធ្វើការចោទប្រកាន់។ ប្រសិនបើយើងសួរសំណួរថា "តើនរណាត្រូវចោទប្រកាន់?" គ្មានក្រុមការងារទាំងអង្គការសហប្រជាជាតិ ឬរាជរដ្ឋាភិបាលកម្ពុជា អាចឆ្លើយតបបាន ដោយសារនេះគឺជាកិច្ចការរបស់តុលាការៈ អង្គជំនុំជម្រះវិសាមញ្ញ។ ប្រសិនបើយើងធ្វើបញ្ជីឈ្មោះបុគ្គលដែត្រូវចោទប្រកាន់ជំនួសតុលាការ យើងរំលោភអំណាចតុលាការ។ ដូច្នេះ យើងពុំអាចកំណត់អត្តសញ្ញាណ ក ខ គ ឬ ឃ ថាជាអ្នកដែលត្រូវទទួលរងការចោទប្រកាន់នោះទេ។ ជាដំណោះស្រាយ យើងបានកំណត់អត្តសញ្ញាណគោលដៅពីរៈ មេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ <u>នៅពេលពិចារណាលើមេដឹកនាំជាន់ខ្ពស់ យើងសំដៅលើបុគ្គលមិនលើសពី១០នាក់ ប៉ុន្តែ យើងពុំបានកំណត់ជាក់លាក់ថា អ្នកទាំងនោះត្រូវតែជាសមាជិកគណៈអចិន្ត្រៃយ៍។ នេះគឺជាកិច្ចការរបស់សហព្រះរាជអាជ្ញា។</u> មូលហេតុអ្វីបានយើងសម្រេចកំណត់អត្តសញ្ញាណបុគ្គលមួយចំនួនតូចបែបនេះ? ពីព្រោះអ្នកជំនាញក្នុងការរៀបចំតុលាការអន្តរជាតិ ដឹងថា ការចោទប្រកាន់បុគ្គលដប់ទៅម្ភៃនាក់ ឬរាប់ពាន់អ្នក ពុំមែនជាកិច្ចការដែលបង្កើតឱ្យមានលទ្ធផលល្អនោះទេ។ នេះគឺជាមូលហេតុដែលយើងបានយល់ព្រមគ្នាថា មិនឱ្យមានការជ្រើសរើសមនុស្សលើសពីដប់នាក់ ដែលជាមេដឹកនាំជាន់ខ្ពស់។ ទោះជាយ៉ាងណាក្តី <u>នៅមានគោលដៅទីពីរទៀត។ អ្នកទាំងនេះពុំមែនជាមេដឹកនាំ ប៉ុន្តែបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅ។ នេះជាមូលហេតុដែលប្រើពាក្យពេចន៍ថា អ្នកទទួលខុសត្រូវខ្ពស់បំផុត។ ពុំមានការកំណត់ពីចំនួនជាក់លាក់នៃអ្នកដែលត្រូវធ្វើការចោទប្រកាន់ចេញពីក្រុមទីពីរឡើយ។ អ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ នឹងត្រូវធ្វើការចោទប្រកាន់[257]។</u>

107. ប្រតិចារឹកនៃកិច្ចពិភាក្សា បានផ្តល់ព័ត៌មានទូលំទូលាយ។ គ្រប់ពាក្យត្រូវបានអានដោយយកចិត្តទុកដាក់ក្នុងការខិតខំប្រឹងប្រែងស្វែងរកការគាំទ្រសម្រាប់ការអះអាងដដែលៗដែលថា សុខ អាន បានបញ្ជាក់នៅសភាជាតិថា មានតែបុគ្គលប្រាំនាក់ត្រូវធ្វើការស៊ើបអង្កេតនោះ។ <u>ប្រតិចារឹកបានបង្ហាញផ្ទុយទៅវិញ។</u> ដូចគ្នាដែរ ពុំមានការគាំទ្រសម្រាប់មូលដ្ឋានដែលថា ការស៊ើបអង្កេតលើអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ត្រូវបានកម្រិតតាមរយៈតាមរយៈតួនាទីរបស់ជនសង្ស័យនៅក្នុងសង្គមកម្ពុជា ឬថាតើជនសង្ស័យបានចូលបម្រើយោធាក្នុងជម្លោះព្រំដែនរវាងប្រទេសថៃនោះទេ។ អ្វីដែល សុខ អាន បាននិយាយ[258] ស្របជាមួយនឹងអ្វីដែលបាននិពន្ធដោយ Thomas HAMMARBERG និងបានឆ្លុះបញ្ចាំងចេតនាតែងតាំងចៅក្រមឯករាជ្យដែលទទួលបានការបណ្តុះបណ្តាល និងស្របតាមកិច្ចព្រមព្រៀង អ.វ.ត.ក. និងច្បាប់បង្កើត អ.វ.ត.ក. ដែលបង្កើតក្នុងគោលបំណងអនុវត្តទៅលើមុខនាទីរបស់តុលាការព្រហ្មទណ្ឌកូនកាត់នេះ។

[257] សម័យប្រជុំពេញអង្គលើកទីមួយនីតិកាលទីបីនៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ៥ ខែ តុលា ២០០៤។

[258] ក្រោយពីកាធ្វើសច្ចាប័នច្បាប់តាមពាក្យរបស់ សុខ អាន ផ្ទាល់។

ទោះជាយ៉ាងណាក្តី អ្វីដែលបានវិវឌ្ឍន៍កន្លងមក បានបង្ហាញពីវិធីសាស្ត្រដែលត្រូវបានកំណត់ទុកជាមុន និងមិនអាចបត់បែនបាន ដើម្បីរារាំងកិច្ចស៊ើបអង្កេត និងការចោទប្រកាន់លើសពីជនសង្ស័យប្រាំនាក់ដំបូង[259]។

108. ផ្អែកលើលទ្ធផលក្រោយព្រឹត្តិការណ៍ បានបង្ហាញកាន់តែច្បាស់ឡើង និងមានកាតម្ពាភាព និងការបង្ហាញច្បាស់លាស់ពីចេតនាបិទដំណើរការចោទប្រកាន់ និងស៊ើបអង្កេត នៅពេលដែលមានដីកាដំណោះស្រាយទាក់ទងទៅនឹងជនសង្ស័យទីមួយត្រូវបានបង្កើតឡើង។ ជម្រើសបន្តទៀតសម្រាប់សហព្រះរាជអាជ្ញាជាតិ គឺការស្វែងរកការមោឃភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងទីបី ប្រសិនបើអ្វីដែលគាត់បានអះអាងក្នុងខែ ឧសភា ឆ្នាំ ២០០៩ គឺជាការពិត។ ផ្ទុយទៅវិញ យើងមានការស៊ើបអង្កេតយ៉ាងទូលំទូលាយលើជនត្រូវចោទបីនាក់ដែលមានវ័យចំណាស់ និងពុំអាចរៀបចំជីវិតរបស់ខ្លួនបានក្រៅតែពីការភ័យខ្លាចការជំនុំជម្រះ។ ជនសង្ស័យ បើទោះបីជាបានលទ្ធភាពស្របច្បាប់ដែលបើកចំហរឱ្យគាត់ជៀសផុតពីការជំនុំជម្រះក៏ដោយ ក៏មានសិទ្ធិដឹងថា គាត់នឹងត្រូវបញ្ជូនទៅជំនុំជម្រះ ឬ រឿងក្តីនោះត្រូវបានលើកលែងចោទប្រកាន់ដោយសារហេតុផលផ្លូវច្បាប់។ ពួកគាត់ពុំអាចត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ជារៀងរហូតនោះបានឡើយ។ នៅម្ខាងទៀត គឺជាជនរងគ្រោះខ្មែរក្រោមរាប់ពាន់នាក់ ដែលត្រូវបាននិរទេសដោយបង្ខំ និងការស្លាប់ពុំដែលត្រូវបានពិចារណាដោយតុលាការ។ មានសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជារាប់ពាន់នាក់ត្រូវបានបោសសម្អាតក្នុងអំឡុងពេលនៃការគ្រប់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលគ្រួសាររបស់ពួកគេពុំអាចដឹងពីមូលហេតុ ឬអ្នកណាជាអ្នកបញ្ជាឱ្យសម្លាប់។ ប្រហាក់ប្រហែលគ្នានេះដែរ កម្មាភិបាលរាប់ពាន់នាក់នៃបក្សកុម្មុយនីស្តកម្ពុជាពីភូមិភាគពាយ័ព្យ ត្រូវបានធ្វើទារុណកម្ម និងសម្លាប់ក្នុងទួលស្លែង និងតាមមន្ទីរសន្តិសុខដទៃទៀត ដោយគ្មានលទ្ធភាពរកឃើញអត្តសញ្ញាណពួកគេ នរណាបញ្ជា នរណាអនុវត្ត និងមូលហេតុអ្វីឡើយ។

109. ជាការងាយយល់ចំពោះការខកចិត្តរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពីមូលហេតុដែលដីកាបើកការស៊ើបសួរ និងបញ្ជូនទៅជំនុំជម្រះជាច្រើនត្រូវបានធ្វើឱ្យរាំងស្ទះដោយចៅក្រមជាតិ ដែលដាក់ឱ្យអនុវត្តក្រោមច្បាប់តែមួយដូចគ្នា កិច្ចព្រមព្រៀងដូចគ្នា និងវិធានស្តីពីនីតិវិធីដូចគ្នា[260]។ សកម្មភាពទាំងនោះអំពាវនាវឱ្យមានការពិនិត្យឡើងវិញដោយតុលាការ ដោយសារសំអាងហេតុដែលផ្តល់សម្រាប់រារាំងដំណើរការ

[259] *សូមមើល ឧ.*សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. “សេចក្តីថ្លែងការដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ [Laurent KASPER-ANSERMET]” ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge gov.kh/en/articles/press-release-international-reserve-co-investigating-judge។

[260] មតិជំទាស់នេះពុំសំដៅលើសហសេវិកនៅក្នុងអង្គជំនុំជម្រះរបស់ខ្ញុំឡើយ។

នោះ បានផ្អែកលើមូលដ្ឋានផ្នែកអង្គហេតុដែលពុំរឹងមាំជាក់ស្ដែង និងពុំមានការគាំទ្រដោយច្បាប់ដែល (១) ថា កិច្ចស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាម្នាក់ គឺជាការខុសច្បាប់ និង (២) ថាតើ សុខ អាន ពិតជាបានអះអាងនៅមុខសភាជាតិថា មានតែជនសង្ស័យប្រាំនាក់ប៉ុណ្ណោះដែលត្រូវទទួលរងការចោទប្រកាន់នោះ។

ទីក្រុង Cork ប្រទេសអៀរឡង់ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**



ចៅក្រម **Maureen HARDING CLARK**